# ព្រះធម៌

# ចំពូកទី ១
# ការដាក់ធងហេតុនិងផល

## I
## សេចក្តីពិតថ្លៃថ្នូរបួនប្រការ

1. *លោកនេះ ពោរពេញទៅដោយទុក្ខវេទនា។ កើតមកក៏ទុក្ខ ជរាក៏ទុក្ខ ឈឺក៏ទុក្ខ ស្លាប់ក៏ទុក្ខ។ ជួបនឹងមនុស្សជាទីសម្អប់ក៏ទុក្ខ បែកពីអ្នកជាទីស្រឡាញ់ក៏ទុក្ខ មិនអាចបំពេញបំណងក៏ទុក្ខ។ ដោយសរុបទៅ ជីវិតដែលជាប់ក្នុងចំណង់តណ្ហានេះជាទុក្ខ។ នេះហើយដែលហៅថា សេចក្តីពិតបំផុតអំពីទុក្ខវេទនា។*

*ហេតុនៃទុក្ខទាំងឡាយរបស់មនុស្សលោក គឺពិតជាមកអំពីតណ្ហាទាំងឡាយ ដែលញាំញីបេះដូងមនុស្សលោក។ បើគេរាវរកឲ្យដល់ឫសគល់នៃតណ្ហាទាំងនេះ គេនឹងឃើញថាតណ្ហាទាំងនេះ វាមានឫសនៅក្នុងចំណង់យ៉ាងងប់ងល់ ដែលបុគ្គលរាល់រូបមានតាំងពីកំណើតមក។ ចំណង់ងប់ងុលទាំងនេះ*

ក្នុងបំណងយ៉ាងមាំថា ត្រូវតែរស់ជាមូលហេតុ ក៏ខំប្រឹងឈោង ចាប់យកអ្វីៗទាំងអស់ដែលឃើញ និងអ្វីៗទាំងអស់ដែលឮ ដូន កាលសូម្បីសេចក្តីមរណៈ ក៏ចំណង់ទាំងនោះឈោងចាប់យក ដែរៗ នេះហើយគឺសេចក្តីពិតបំផុតអំពីឫសគល់នៃទុក្ខវេទនាៗ

បើបុគ្គលណាអាចដកឫសតណ្ហាចេញឲ្យអស់បាន ហើយ បំផ្លាញចោលនូវចំណង់តណ្ហាទាំងអស់បាន បុគ្គលនោះនឹង បានផុតទុក្ខវេទនាៗ នេះហើយគឺជាសេចក្តីពិតបំផុត អំពីការ បំបាត់ចោលលែងមានទុក្ខវេទនាៗ

ដើម្បីនឹងបានដល់នូវភាពគ្មានចំណង់ និងគ្មានទុក្ខ ត្រូវ តែដើរតាមផ្លូវដែលមានប្រាំបីសង្កាត់ ពោលគឺៈ ឃើញត្រូវ១ គិតត្រូវ១ ស្រដីត្រូវ១ ប្រព្រឹត្តត្រូវ១ រស់នៅត្រឹមត្រូវ១ ប្រឹង ប្រែងត្រូវ១ ប្រុងប្រយ័ត្នត្រូវ១ និងសង្រួមចិត្តត្រូវ១ៗ នេះ ហើយគឺជាសេចក្តីពិតបំផុត អំពីផ្លូវទៅកាន់ការវៀរចាកទុក្ខ វេទនាៗ

ត្រូវតែចាំទុកឲ្យច្បាស់ក្នុងចិត្តអំពីសេចក្តីពិតថ្លៃថ្នូរទាំង នេះ ពីព្រោះលោកនេះពោរពេញទៅដោយទុក្ខវេទនា ហើយបើបុគ្គលណាចង់ឲ្យរួចផុតអំពីទុក្ខវេទនា បុគ្គលនោះ

តោងតែផ្ដាច់ចំណងតណ្ហាលោកិយ។ គឺមានតែការបាន ត្រាស់ដឹងតែមួយគត់ ដែលអាចឲ្យបុគ្គលបានដល់ភាពរួចផុត ពីតណ្ហា និងទុក្ខវេទនា។ រីឯនឹងបានទៅដល់ការបានត្រាស់ ដឹង មានតែដើរតាមផ្លូវប្រាំបីថ្នាក់ ឬវិន័យប្រាំបីដ៏ប្រសើរនេះ ទេ ទើបអាចទៅដល់។

2. អ្នកដែលស្វែងរកការត្រាស់ដឹង ត្រូវតែយល់សេចក្ដីពិត ថ្លៃថ្នូរទាំងបួននេះ។ បើមិនយល់សេចក្ដីពិតទាំងនេះទេ មុខតែ វង្វេងវិលវល់មិនចេះចប់នៅក្នុងបណ្ដាញយ៉ាងចាក់ស្រែះ នៃ ការភាន់ច្រឡំនៃលោកនេះជាប្រាកដ។ បុគ្គលណាយល់សេចក្ដី ពិតថ្លៃថ្នូរទាំងបួននេះ ឈ្មោះថាបុគ្គលនោះបានចក្ខុសម្ពោធិ-ញ្ញាណ។

ដូច្នេះ ត្រូវតែទទួលយកការប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយចិត្តស្មោះស្ម័គ្រ ហើយយល់ឲ្យច្បាស់អំពីន័យនៃសេចក្ដី ពិតថ្លៃថ្នូរទាំងបួននេះ។ ក្នុងកាលសម័យណាក៏ដោយ សន្ត-បុគ្គលណាចង់បានទៅជាសន្តបុគ្គលពិតប្រាកដ ឬអ្នកដែល គួរដល់នូវការបូជាមែនទែន សន្តបុគ្គលនោះត្រូវតែយល់ឲ្យ

ច្បាស់អំពីសេចក្ដីពិតថ្លៃថ្នូរទាំងបួននេះ ហើយពន្យល់ប្រាប់ទៅអ្នកឯទៀតៗ ជាបន្តបន្ទាប់។

បើគេយល់សេចក្ដីពិតថ្លៃថ្នូរទាំងបួននេះច្បាស់ហើយ គេអាចចាកផុតពីតណ្ហាទាំងឡាយ។ ហើយបើគេបានចាកផុតពីតណ្ហាហើយ គេមិនឈ្មោះប្រកែក គេមិនសម្លាប់ គេមិនលួចប្លន់ គេមិនប្រព្រឹត្តអំពើផិតក្បត់ គេមិនកុហកបោក គេមិននិយាយដើមអ្នកឯទៀត គេមិនអួតខ្លួន គេមិនលោភលន់ គេមិនខឹងច្រឡោត គេមិនភ្លេចឡើយអំពីជីវិតមិនទៀង និងមិនឋិតថេរ ហើយគេមិនឃ្លាតចាកពីផ្លូវសុចរិតឡើយ។

3. ដើរតាមផ្លូវប្រសើរថ្លៃថ្នូរ ដូចជាគេកាន់ប្រទីបដើរចូលទៅក្នុងបន្ទប់ងងឹតមួយ។ ភាពងងឹតក៏បាត់ទៅ ហើយពន្លឺនៃប្រទីបក៏បំភ្លឺបន្ទប់នោះឡើង។

បុគ្គលណាយល់ន័យនៃសេចក្ដីពិតថ្លៃថ្នូរទាំងនេះ ហើយដើរតាមផ្លូវប្រសើរថ្លៃថ្នូរនេះ ឈ្មោះថាបុគ្គលនោះមានពន្លឺគតិបណ្ឌិតដែលបណ្ដេញអន្ធភាពងងឹតស្លុងនៃសេចក្ដីល្ងង់ខ្លៅ។

ព្រះពុទ្ធដឹកនាំសត្វលោក ដោយពន្យល់បង្ហាញតែអំពី

សេចក្តីពិតថ្លៃថ្នូរទាំងបួននេះ។ បុគ្គលទាំងឡាយណាយល់ច្បាស់ប្រាកដអំពីសេចក្តីពិតទាំងនេះ នឹងបានសម្រេចការត្រាស់ដឹង។ គឺសេចក្តីពិតថ្លៃថ្នូរទាំងបួននេះហើយ ដែលអាចជួយជ្រោមជ្រែងដឹកនាំបុគ្គលទាំងឡាយក្នុងលោក ដែលប្រកបទៅដោយការវង្វេងវិលវល់នេះបាន។ សេចក្តីពិតថ្លៃថ្នូរទាំងបួននេះសមរម្យណាស់គួរតែជឿតាម។ កាលណាសេចក្តីពិតថ្លៃថ្នូរទាំងបួននេះត្រូវបានយល់ប្រាកដហើយ ប្រកពតណ្ហាទាំងអស់ នឹងវិនាសអស់ជាពុំខាន។

ដោយសារសេចក្តីពិតថ្លៃថ្នូរទាំងបួននេះ ជាគោលមូលដ្ឋាន សាវ័កទាំងឡាយរបស់ព្រះពុទ្ធជាម្ចាស់ អាចយល់គ្រប់ការប្រៀនប្រដៅ និងសេចក្តីពិតផ្សេងៗទៀត ហើយបានដល់នូវគតិបណ្ឌិត ដែលបណ្តាលឲ្យគេអាចដកស្រង់យកបាននូវន័យដ៏ជ្រៅនៃគ្រប់វត្ថុជាតុ ហើយអាចនឹងពន្យល់ប្រៀនប្រដៅគ្រប់សត្វក្នុងលោកនេះជាបន្តទៅទៀតបានដោយសេរី។

## II

## ការទាក់ទងរវាងហេតុ និងផល

1. ចំពោះទុក្ខនីមួយៗ សុទ្ធតែមានហេតុ ហើយក៏មានមធ្យោបាយមួយដើម្បីនឹងរំលត់ទុក្ខនោះបានដែរ។ ព្រោះហេតុអ្វី? ពីព្រោះនៅក្នុងលោកនេះ អ្វីៗទាំងអស់សុទ្ធតែជាលទ្ធផលនៃការប្រកួតប្រជែងដ៏ធំធេងរវាងហេតុនិងល័ក្ខខ័ណ្ឌ។ អ្វីៗទាំងនោះនឹងវិនាសបាត់ទៅវិញ បើកាលណាហេតុ និងល័ក្ខខ័ណ្ឌនោះផ្លាស់ប្ដូរហើយបាត់ទៅវិញ។

ភ្លៀងធ្លាក់ ខ្យល់បក់ ផ្កាឈើរីកឡើង ស្លឹកឈើជ្រុះ ក៏សុទ្ធតែមានហេតុ ពោលគឺ កើតឡើងហើយស្លាប់ទៅវិញ។

ទារកកើតឡើងតាមល័ក្ខខ័ណ្ឌរបស់មាតាបិតា វាបានធំធាត់ឡើងដោយសារចំណីអាហារ ហើយសតិប្រាជ្ញាវាលូតលាស់ឡើងដោយសារចំណេះវិជ្ជា និងការពិសោធន៍។

រូបកាយ និងសតិប្រាជ្ញាទាំងពីរនេះ ទៅតាមហេតុ ហើយវិវដ្តប្រួលប្រែដោយសារហេតុផ្សេងៗ។

ក្រឡាសំណាញ់ចាក់ស្រេះឡើងបាន ដោយសារកំនួចចំណង។ យ៉ាងណាមិញ អ្វីៗទាំងអស់ក្នុងលោកនេះ ជាប់ទាក់ទងគ្នាបាន ដោយសារតែចំណងដូច្នេះដែរ។ ការគិតថាក្រឡាញសំណាញ់វាគង់នៅដោយឯកឯងនោះ ជាការយល់ច្រឡំមួយដ៏ធំ។

សំណាញ់កើតឡើងបាន ដោយសារក្រឡាជាច្រើនទាក់ទងជាប់គ្នា ហើយក្រឡានីមួយៗនៃសំណាញ់ ត្រូវការទាក់ទងនឹងក្រឡាឯទៀតៗ ជាចាំបាច់។

2. ផ្កាឈើរីកឡើងដោយសារហេតុច្រើនប្រការ ស្លឹកឈើជ្រុះក៏ដោយសារតែហេតុច្រើនប្រការដែរ។ បើគ្មានហេតុទាំងនោះទេ ផ្កាក៏មិនរីក ស្លឹកក៏មិនជ្រុះដែរ។ ផ្កាឈើរីកដោយសារមានហេតុផ្សេងៗ ស្លឹកឈើជ្រុះក៏ដោយសារមានហេតុផ្សេងៗដែរ។ អ្វីៗទាំងអស់សុទ្ធតែត្រូវទទួលការប្រែប្រួល។ គ្មានអ្វីដែលអាចឋិតនៅដោយឯកឯង ហើយគ្មានអ្វីដែលអាចគង់នៅបានដោយឥតប្រែប្រួលនោះទេ។

រឿងតែមួយគត់ ដែលអាចឋិតថេរជានិច្ចដោយឥតប្រែប្រួលនៅក្នុងលោកនេះ គឺអ្វីៗទាំងអស់កើតឡើងដោយមានហេតុមួយ ហើយវិនាសទៅវិញដោយមានហេតុមួយ។

III

## ការទាក់ទងគ្នារវាងហេតុផ្សេងៗ

1. តើឫសគល់នៃទុក្ខ ព្រួយ បារម្ភ និងកង្វល់ នៅកន្លែងណា

ទៅ? បើគិតឲ្យល្អិតល្អន់ទៅ ឫសគល់នោះវានៅនឹងមនុស្ស លោក ដែលលូងខ្លៅ ហើយមានតណ្ហាជាច្រើនលើសលុប។

មនុស្សលោកជំពាក់ចិត្តនឹងជីវិតសម្បូណ៌ដោយធនធាន និងកិត្តិយស ជីវិតសុខុមាលភាពនិងសប្បាយរីករាយ ជីវិតរំដើប រំជួលប្រកបដោយអត្តទត្ថភាព។ មនុស្សលោកគ្មានបានគិតដល់ ថា ចំណង់ចំពោះវត្ថុទាំងនោះវាជាឫសគល់នៃទុក្ខនោះទេ។

តាំងពីលោកនេះកកើតឡើងមក មនុស្សលោកត្រូវបាន ទទួលរងនូវវិបត្តិភ័យព្រួយគ្រប់ប្រការ។ ជាបន្ថែមលើនេះទៀត មនុស្សលោកមិនអាចចៀសឲ្យផុតបានពីឈឺ ជរា និងស្លាប់ ដែលជាហេតុ៣ ប្រការនៃទុក្ខនោះបានទេ។

តែបើគេរិះគិតឲ្យដល់ជម្រៅទៅ គេនឹងឃើញថា គឺ ដោយសារតែការជំពាក់ចិត្តនេះឯង ដែលនាំឲ្យមានទុក្ខព្រួយ។ បើសិនជាអាចបំបាត់ការជំពាក់ចិត្តនេះបាន សេចក្តីទុក្ខព្រួយ នឹងវិនាសអស់ជាពុំខាន។

ហេតុដែលបណ្តាលឲ្យមានការជំពាក់ចិត្តទាំងនេះ គឺមក អំពីសេចក្តីលូងខ្លៅ ហើយនិងការយល់ខុសទាំងឡាយ ដែល ស្ថិតនៅពេញក្នុងបេះដូងសត្វលោក។

សេចក្ដីល្ងង់ខ្លៅនិងការយល់ខុសទាំងនេះ មកអំពីមនុស្សលោកមិនយល់ច្បាស់ពិត ដែលគ្រប់គ្រងដំណើរបន្តគ្នាគ្មានបេះដាច់នៃវត្ថុធាតុទាំងឡាយ។

ដោយសារតែសេចក្ដីល្ងង់ខ្លៅ និងការយល់ខុសទាំងនេះហើយ ដែលបណ្ដាលឲ្យមនុស្សលោកប៉ងចង់បានរបស់ដែលចាប់យកពុំបាន ហើយលង់ក្នុងការប៉ុនប៉ងចង់បាននោះ។

ធ្វើការវែកញែកចំពោះរបស់ដែលតាមពិតពុំអាចវែកញែកបាននោះ គឺដោយសារតែសេចក្ដីល្ងង់ខ្លៅ និងសេចក្ដីលោភលន់ចង់បាន។ ធ្វើការវែកញែកអំពីភាពល្អ និងភាពអាក្រក់ ដែលតាមពិតវាគ្មានសោះនោះ គឺមកតែអំពីសេចក្ដីល្ងង់ខ្លៅ និងសេចក្ដីលោភលន់។

ដោយសារតែសេចក្ដីល្ងង់ខ្លៅ មនុស្សលោកមានគំនិតយល់ខុសជានិច្ច ហើយបាត់បង់ជានិច្ចការរមិលយល់ត្រូវ។ ដោយសារតែសេចក្ដីល្ងង់ខ្លៅ មនុស្សលោកជំពាក់ចិត្តតែនឹងខ្លួនឯងផ្ទាល់ ហើយប្រព្រឹត្តអំពើខុស។ ទីបំផុតទៅ មនុស្សលោកវង្វេងវិលវល់ក្នុងផ្លូវភាន់ច្រឡំ។

មានសេចក្ដីប្រៀបធៀបមួយថា: វិស័យកម្មគឺវាលស្រែ

មួយ គំនិតវែកញែកគឺជាគ្រាប់ពូជ។ មនុស្សសាបព្រោះគ្រាប់ពូជនេះដោយល្ងិតល្ងង់ ស្រោចស្រប់បំណងអាក្រក់ និងអត្ត-ទត្ថភាពឲ្យវា ដាក់ជីសេចក្តីលោភលន់ឲ្យវា។ ដោយហេតុនេះហើយ ការភាន់ច្រឡំក៏ត្រូវបានមកជាផល។

2. ទាំងអស់នេះកើតឡើងនៅក្នុងសតិ។ ដូច្នេះ សតិជាដើមហេតុនៃការសង្ស័យមមិនសមហេតុផល ជាដើមហេតុនៃទុក្ខព្រួយលំបាកវេទនា។

លោកដែលពោរពេញទៅដោយសេចក្តីភាន់ច្រឡំនេះ គឺជាស្រមោលដែលបណ្តាលមកអំពីសតិតែប៉ុណ្ណោះ។ តែសតិក៏ជាប្រភពនៃការបានត្រាស់ដឹងនោះដែរ។

3. នៅក្នុងលោកនេះ មានការភាន់ច្រឡំបីប្រការ។ បើបុគ្គលណាប្រកាន់យ៉ាងមាំនូវការយល់ច្រឡំទាំងនោះ បុគ្គលនោះមុខតែនឹងគ្មានច្រកចេញរួចទេ នៅក្នុងលោកនេះ។

ការយល់ច្រឡំទី១ គឺជាការជឿថាអ្វីៗទាំងអស់នៅក្នុងលោកនេះ ត្រូវបានទទួលការគ្រប់គ្រងនៃវាសនា។ ការយល់

ប្រទ្បំទី២ គឺការយល់ឃើញថា អ្វីៗទាំងអស់ត្រូវបានកើតឡើង ដោយសារព្រះអាទិទេព ហើយត្រូវតែសម្រេចទៅតាមបំណង នៃព្រះអាទិទេពនោះ។ ការយល់ប្រទ្បំទី៣ គឺការដែលពោល អះអាងថា អ្វីៗទាំងអស់កើតឡើងដោយចៃដន់ គ្មានហេតុ គ្មានល័ក្ខខ័ណ្ឌអ្វីទេ។

បើអ្វីៗទាំងអស់សម្រេចទៅតាមតែវាសនានោះ អំពើល្អ និងអំពើអាក្រក់ត្រូវតែបានកំណត់ទុកមុន សុភមង្គល និង អភ័ព្វត្រូវតែបានកំណត់ទុកមុន។ គ្មានអ្វីដែលមិនត្រូវបាន កំណត់ទុកមុននោះទេ។ បើដូចនេះ គេមិនអាចពោលស្រដី បានថា: «ត្រូវធ្វើយ៉ាងនេះ មិនត្រូវធ្វើយ៉ាងនោះ» បានទេ។ សត្វលោកមុខតែអស់សេចក្ដីសង្ឃឹម ចំពោះរសជាតិនៃការ តស៊ូជាមិនខាន។ ហើយលោកនេះមុខតែនឹងគ្មានការចម្រើន លូតលាស់ទៅមុខជាពុំខាន។

ការពោលថា អ្វីៗទាំងអស់នៅក្រោមការសម្រេចរបស់ ព្រះអាទិទេព ឬថាគ្មានហេតុ និងគ្មានសម្ព័ន្ធនោះ ក៏នឹងត្រូវ បានទទួលការជំទាស់ដូចខាងលើនេះដែរ។ បើអ្វីៗទាំងអស់វា ទៅជាបែបនេះ មុខតែគ្មានសំអាងអ្វីឡើយនឹងខិតខំចៀសវាង

នូវអំពើអាក្រក់ ហើយខំតែប្រព្រឹត្តអំពើល្អនោះទេ។

ដូច្នេះ ការគិតយល់ទាំងបីប្រការនេះជាការគិតខុសពី ព្រោះអ្វីៗទាំងអស់កើតឡើងដោយសារហេតុមួយ ហើយ វិនាសទៅវិញដោយសារហេតុមួយ។

# ចំពូកទី ២

# ទ្រឹស្តីអំពីវិញ្ញាណតែមួយគត់ និងសភាពពិតនៃវត្ថុធាតុ

I

## ភាពមិនឋិតថេរ និង ភាពឥតសារជាតិ

1. *រូប និងវិញ្ញាណ កើតឡើងអំពីការប្រកួតប្រជែងគ្នារវាងហេតុនិងល័ក្ខខ័ណ្ឌ ហេតុនេះរូបគ្មានសារជាតិទេ។ រូបកកើតឡើងអំពីសាច់ និងវត្ថុធាតុផ្សេងៗផ្តុំប្រមូលគ្នារូបនោះមិនឋិតថេរទេ។*

*បើរូបជាវត្ថុមានសារជាតិ រូបនោះអាចធ្វើនេះធ្វើនោះបានតាមបំណង។*

*ព្រះមហាក្សត្រមានអំណាចនឹងឲ្យរង្វាន់ ឬដាក់ទោសបានតាមចិត្តចង់។ ប៉ុន្តែ ទោះបីព្រះអង្គគ្មានបំណង ឬចំណង់ក៏ដោយ ក៏ព្រះអង្គត្រូវតែឈឺ ជរា ជាមិនខាន ហើយភោគទ្រព្យអាចបំពេញបំណងព្រះអង្គបានដោយតិចតួចណាស់។*

វិញ្ញាណ ក៏ជារបស់ឥតសារជាតិដែរ។ វិញ្ញាណរបស់មនុស្ស ក៏ជាវត្ថុផ្គុំគ្នាអំពីហេតុ និងល័ក្ខខ័ណ្ឌដែរ។ វិញ្ញាណប្រែប្រួលជានិច្ច។

បើវិញ្ញាណជាវត្ថុមានសារជាតិ វាអាចនឹងធ្វើអ្វីៗបានតាមបំណង។ តែវិញ្ញាណមិនធ្វើអ្វីដែលយល់ថាត្រូវជានិច្ចនោះទេ វាជាប់ជំពាក់និងអ្វីៗដែលខុស ហើយដែលវាមិនចង់បានសោះ។ គ្មានអ្វីដែលផ្ដល់មកឲ្យបានសមនឹងបំណងនោះទេ។

2. បើគេសួរថា រូបឋិតថេរ ឬក៏មិនឋិតថេរទេ ន៎ុះត្រូវតែឆ្លើយថា មិនឋិតថេរទេ។

បើគេសួរថា ជីវិតមិនឋិតថេរជាសុភមង្គល ឬជាទុក្ខ ត្រូវឆ្លើយជាធម្មតាថា វាជាទុក្ខ។

ការនឹកស្មានថា វត្ថុដែលមិនឋិតថេរ ដែលប្រែប្រួលជានិច្ច ហើយដែលពោរពេញទៅដោយទុក្ខយ៉ាងនេះជាវត្ថុមានសារជាតិ ន៎ុះជាការយល់ច្រឡំធំណាស់។

វិញ្ញាណមនុស្សលោក ដែលមិនឋិតថេរហើយពោរពេញទៅដោយទុក្ខបែបនេះ គ្មានរឿងអ្វីនឹងអាចហៅវិញ្ញាណនោះ

ថា ជាវត្ថុមានសារជាតិបានទេ។

ដោយហេតុនេះ រូបនិងវិញ្ញាណដែលជាវត្ថុធាតុដើមនៃជីវិតរបស់មនុស្សជាតិ និងលោកខាងក្រៅដែលហាក់ដូចជានៅព័ទ្ធជុំវិញនោះ គ្មានអត្ថន័យថាជា «អាត្មាអញ» ឬ «ខ្លួនខ្ញុំ» ទេ។

និយាយឲ្យខ្លីទៅ គឺដោយសារតែវិញ្ញាណត្រូវឡើងងងឹតដោយចំណង់មិនបរិសុទ្ធ ហើយមិនព្រមទទួលនូវគតិបណ្ឌិតយ៉ាងនេះ ទើបបានជាបុគ្គលម្នាក់ៗ ចចេសតែគិតអំពី «អាត្មាអញ» ឬ «ខ្លួនខ្ញុំ»។

ដោយហេតុថា រូបព្រមទាំងអ្វីៗ ដែលនៅជុំវិញវាកកើតឡើងពីហេតុ និងល័ក្ខខ័ណ្ឌ វត្ថុទាំងនោះប្រែប្រួលជានិច្ច មិនព្រមឈប់ឈរទេ។

វិញ្ញាណមនុស្សលោកដែលប្រែប្រួលជានិច្ចនោះ បីដូចជាទឹកស្ទឹងដែលហូរជានិច្ច ឬបីដូចជាអណ្តាតភ្លើងទៀន ដែលឆេះទ្រលោមអញ្ចឹងដែរ អាចប្រៀបប្រដូចទៅនឹងសត្វស្វាដែលលោតមិនចេះឈប់ពីកន្លែងមួយទៅកន្លែងមួយ។

បុគ្គលជាបណ្ឌិតដែលបានសង្កេតឃើញដំណើរនេះ ត្រូវ

តែផ្តាច់ការជាប់ចិត្តចំពោះរូបកាយនិងវិញ្ញាណ បើសិនជាមានចំណង់ចង់ឲ្យបានសម្រេចការត្រាស់ដឹង។

3. នៅក្នុងលោកនេះ មានវត្ថុប្រាំប្រការ ដែលចៀសពុំផុតៈ ទី១ គឺកាលណាចាស់ហើយ មិនអាចបញ្ឈប់កុំឲ្យចាស់បានទេ ទី២ គឺកាលណាឈឺហើយ មិនអាចថាកុំឈឺបានទេ ទី៣ គឺកាលណាកំពុងតែឈានទៅរកសេចក្តីស្លាប់ហើយ មិនអាចថាកុំស្លាប់បានទេ ទី៤ គឺកាលណាដល់នូវការរលាយហើយ មិនអាចបញ្ឈប់ការរលាយនោះបានទេ ទី៥ គឺមិនអាចចៀសផុតពីការរលត់សាបសូន្យបានទេ។

នៅក្នុងលោកនេះ អ្នកណាក៏ដោយ នៅទីបំផុតត្រូវតែបានជួបប្រទះនឹងការចៀសមិនរួចទាំងប្រាំប្រការនេះ។ អ្នកដែលបានស្តាប់សេចក្តីទូន្មានរបស់ព្រះពុទ្ធ កាលណាពេលនេះមកដល់ហើយ មិនឈឺចាប់នឹងប្រការទាំងនោះទេ ព្រោះដឹងថាជាការចៀសពុំផុត។

នៅក្នុងលោកនេះ មានសេចក្តីពិតបួនប្រការៈ ទី១ គឺមនុស្សលោកកើតឡើងដោយសេចក្តីល្ងង់ខ្លៅជាហេតុ ទី២

គឺអ្វីៗដែលប៉ះប្រាថ្នាសុទ្ធតែជារបស់មិនឋិតថេរ មិនប្រាកដ ហើយពោរពេញទៅដោយទុក្ខ ទី៣ គឺអ្វីៗដែលឋិតមាននៅ សុទ្ធតែជារបស់មិនឋិតថេរ មិនប្រាកដ ហើយពោរពេញទៅដោយទុក្ខ ទី៤ គឺនៅក្នុងលោកនេះគ្មានអ្វីដែលអាចចាត់តាំងថាជា «អាត្មាអញ» ឬ «របស់អញ» បានទេ។

អ្វីៗទាំងអស់សុទ្ធតែមិនឋិតថេរ សុទ្ធតែជាបណ្តោះអាសន្ន ហើយគ្មានអត្តភាពទេ។ នេះជាសេចក្តីពិតណាស់ ទោះបីជឿថាក្នុងលោកនេះមានព្រះពុទ្ធ ឬគ្មានព្រះពុទ្ធក៏ដោយ។ នេះជាសេចក្តីពិត ដែលពុំអាចប្រកែកជំទាស់បាន។ ព្រះពុទ្ធ ដោយដឹងយល់នូវសេចក្តីនេះហើយ ទើបបានជាព្រះអង្គទេសនាពន្យល់ព្រះធម៌ដល់សត្វលោកទាំងអស់។

II

# ទ្រឹស្តីអំពីវិញ្ញាណតែមួយគត់

1. សេចក្តីល្ងង់ខ្លៅនិងការបានត្រាស់ដឹង ទាំងពីរនេះចេញមកពីវិញ្ញាណ ហើយបាតុភូតទាំងឡាយជាលទ្ធផលនៃសកម្ម

ភាពនៃវិញ្ញាណ បីដូចជាវត្ថុទាំងឡាយដែលចេញមកពីការ ប៉ិនប្រសព្វនៃគ្រូមន្តអាគមចេះប្ដឹនភ្នែក។

សកម្មភាពនៃវិញ្ញាណគ្មានព្រំដែនទេៈ គឺសកម្មភាពទាំង នោះហើយ ដែលបង្កើតពិភពនៃជីវិត។ វិញ្ញាណមិនបរិសុទ្ធ បង្កើតពិភពមិនបរិសុទ្ធ វិញ្ញាណបរិសុទ្ធបង្កើតពិភពបរិសុទ្ធ។ អ្វីៗទាំងអស់ដែលនៅព័ទ្ធជុំវិញខ្លួនយើងនេះ គ្មានវត្ថុអ្វីក្រៅពី សកម្មភាពនៃវិញ្ញាណរបស់ផងយើងនោះទេ។

ប្រៀបបានទៅនឹងផ្ទាំងគំនូរ ដែលផលិតឡើងទៅតាម ស្នាដៃនៃវិចិត្រករ អ្វីៗទាំងអស់ដែលនៅព័ទ្ធជុំវិញយើង ជា ផលិតផលដែលកើតឡើងពីវិញ្ញាណរបស់យើងផ្ទាល់។ ពិភព ដែលព្រះពុទ្ធបង្កើត ជាពិភពបរិសុទ្ធ តែពិភពដែលមនុស្ស លោកបង្កើត ជាពិភពមិនបរិសុទ្ធទេ។

នៅក្នុងរូបគំនូរតែមួយគត់នោះ មានសេចក្ដីពិពណ៌នា ផ្សេងៗជាច្រើនរាប់មិនអស់។ វិញ្ញាណមនុស្សលោកក៏ដូច្នោះ ដែរ វាបង្កើតពិភពរបស់វាផ្ទាល់ ដែលពោរពេញទៅដោយ សកម្មភាពរាប់មិនអស់។ នៅក្នុងលោកនេះ គ្មានអ្វីដែលមិន ផលិតឡើងដោយសារវិញ្ញាណនោះទេ។

ព្រះពុទ្ធទ្រង់យល់យ៉ាងច្បាស់ថា អ្វីៗទាំងអស់ត្រូវបានកើតឡើងដោយសារវិញ្ញាណ។ ហេតុនេះហើយ បើបុគ្គលណាយល់សេចក្តីនេះ បុគ្គលនោះអាចនឹងមើលឃើញព្រះពុទ្ធពិតប្រាកដ។

2. វិញ្ញាណដែលបង្កើតពិភពរបស់ខ្លួនផ្ទាល់នោះ មិនអាចចេញឲ្យផុតពីស្រមោលរបស់ខ្លួនបានជាដាច់ខាត: វិញ្ញាណស្តាយនូវអតីតកាល ខ្លាចអនាគតកាល ហើយត្អូញត្អែរនឹងបច្ចុប្បន្នកាល ដោយសារតែសេចក្តីល្ងង់ខ្លៅ ព្រមនិងតណ្ហាលោភលន់របស់ខ្លួន។

លោកដែលពេញទៅដោយការយល់ច្រឡំនេះ កើតឡើងពីក្តីល្ងង់ខ្លៅ និងសេចក្តីលោភលន់។ ការប្រមូលផ្តុំគ្នាដ៏ធំទូលាយនៃហេតុនិងល័ក្ខខ័ណ្ឌ ដែលត្រូវការគ្នាទៅវិញទៅមកនោះ ស្ថិតនៅក្នុងវិញ្ញាណនោះឯង គ្មាននៅទីណាផ្សេងទៀតទេ។

ការរស់នៅនិងការស្លាប់ កើតឡើងពីវិញ្ញាណ ហើយឋិតនៅក្នុងវិញ្ញាណនោះ។ កាលណាវិញ្ញាណបាត់បង់ទៅពិភព

នៃការរស់នៅ និងការស្លាប់ក៏បាត់បង់ទៅតាមវិញ្ញាណនោះដែរ។

ជីវិតល្ងីតល្ងង់និងវង្វេងវង្វាន់ មកពីវិញ្ញាណល្ងីតល្ងង់និងវង្វេងវង្វាន់។ បើយើងបានយល់ថា ពិភពនៃការយល់ច្រឡំវាមិនឋិតនៅទីណាក្រៅអំពីវិញ្ញាណទេនោះ យើងនឹងអាចធ្វើឲ្យវិញ្ញាណយើងបានភ្លឺថ្លា ហើយកាលណាយើងឈប់បង្កើតពិភពមិនបរិសុទ្ធ យើងនឹងអាចដល់នូវការបានត្រាស់ដឹង។

តាមដោយសេចក្តីនេះ ឃើញថា ពិភពនៃការរស់នៅនិងការស្លាប់ ពោលគឺលោកយើងនេះ កើតឡើងដោយសារវិញ្ញាណជិះជាន់ញាំញីដោយសារវិញ្ញាណ គ្រប់គ្រងត្រួតត្រាដោយសារវិញ្ញាណ។ គឺវិញ្ញាណដែលបញ្ជាគ្រប់ស្ថានភាពទាំងអស់។ ពិភពនៃទុក្ខកើតឡើងអំពីវិញ្ញាណវង្វេងវង្វាន់។

3. ដូច្នេះ អ្វីៗទាំងអស់ ត្រូវបានគ្រប់គ្រងជាដំបូងដោយវិញ្ញាណ អ្វីៗទាំងអស់ចេញមកអំពីវិញ្ញាណ។ ដូចជាកង់រិលតាមគោដែលទាញរទេះ ទុក្ខរត់តាមវិញ្ញាណដែលព័ទ្ធជំពាក់

និងគំនិតអសុចិ ហើយនិងតណ្ហាលោកិយ។

បើបុគ្គលណានិយាយហើយប្រព្រឹត្តតាមដោយវិញ្ញាណល្អបរិសុទ្ធ សុភមង្គលនឹងរត់តាមបុគ្គលនោះ ដូចជាស្រមោលអន្ទោលតាមប្រាណដូច្នេះដែរ។ អ្នកប្រព្រឹត្តអាក្រក់នឹងនឹកឃើញជាខាងក្រោយ ថាខ្លួនបានប្រព្រឹត្តអាក្រក់ ហើយការនឹកឃើញនេះត្រូវបានកំណត់ទុកក្នុងខ្លួន ដើម្បីជារង្វាន់ចៀសមិនរួចដល់ខ្លួនវិញ ក្នុងជីវិតជាបន្តៗទៅទៀត។ អ្នកដែលប្រព្រឹត្តអំពើល្អ សប្បាយនឹងអំពើល្អដែលខ្លួនបានធ្វើ ហើយសប្បាយច្រើនទៅទៀត នៅពេលគិតឃើញដល់សុភមង្គលដែលនឹងត្រូវបានអំពីអំពើល្អនេះ ក្នុងជីវិតខាងមុខទៀត។

បើវិញ្ញាណមិនបរិសុទ្ធទេនោះ ផ្លូវនឹងឡើងជាអាក្រក់ពិបាកដើរ ហើយជើងនឹងភ្ទាត់ជំពប់ជាមិនខាន មុខតែប្រទះនឹងការដួលធ្លាក់និងការវេទនាជាច្រើនមិនខាន។ តែបើវិញ្ញាណនោះបរិសុទ្ធ ផ្លូវនឹងឡើងរាបស្មើល្អ ហើយការធ្វើដំណើរនឹងបានប្រកបដោយសេចក្តីសុខក្សេមក្សាន្ត។

អ្នកដែលមានរូបនិងវិញ្ញាណបរិសុទ្ធ ជាអ្នកដើរតាមផ្លូវរបស់ព្រះពុទ្ធ កំចាត់បង់នូវសំណាញ់អត្តទត្តភាព នូវគំនិតមិន

*បរិសុទ្ធ និងសេចក្តីប្រាថ្នាអាក្រក់។ អ្នកដែលមានវិញ្ញាណស្ងប់ អាចរស់ក្នុងសុខសន្តិភាព ហើយអាចរក្សាដុសខាត់វិញ្ញាណរបស់ខ្លួនបានរាល់យប់ថ្ងៃដោយការផ្ចិតផ្ចង់ច្រើនជានិច្ច។*

III

# ភាពពិតនៃវត្ថុជាតុ

1. *ដោយហេតុតែអ្វីៗទាំងអស់នៅក្នុងលោកនេះ កើតមកអំពីការប្រកួតប្រជែងរវាងហេតុនិងលក្ខខ័ណ្ឌវា មិនអាចនឹងមានការវែកញែកជាគោល រវាងវត្ថុទាំងឡាយនោះបានទេ។ ការវែកញែកដែលជាអាការខាងក្រៅនោះ មកអំពីមនុស្សលោកមានគំនិតរវើរវាយគិតវែកញែក រវាងវត្ថុទាំងនោះតែប៉ុណ្ណោះ។*

*នៅក្នុងផ្ទៃមេឃ គ្មានការសម្គាល់ឃើញថាខុសគ្នារវាងទិសខាងកើត និងទិសខាងលិចទេ។ តែមនុស្សលោកបង្កើតការវែកញែកសម្គាល់នេះ នៅក្នុងវិញ្ញាណរបស់ខ្លួនផ្ទាល់ ហើយជឿថា ការនេះជាការពិត។*

*នៅក្នុងគណិតសាស្ត្រ គ្រប់លេខពី១ដល់អសង្ខេយ្យ វា*

ពេញលេញគ្រប់គ្រាន់ក្នុងតួរបស់វានីមួយៗហើយ។ តួលេខនីមួយៗគ្មានចំនួនអ្វីខុសគ្នាទេ តែមនុស្សលោកធ្វើការវែកញែកសម្គាល់នូវចំនួនក្នុងតួលេខទាំងនោះ តាមតម្រូវចិត្តរបស់ខ្លួននោះ គឺដើម្បីអាចធ្វើលេខផ្សេងៗបានតែប៉ុណ្ណោះ។

ដើមឡើយ បើគ្មានការកើតឡើង ក៏គ្មានការវិនាសទៅវិញដែរ តែមនុស្សលោកសម្គាល់ឃើញថា ខុសគ្នារវាងការកើតនិងការស្លាប់នេះ។ នៅក្នុងអំពើនីមួយៗ បើគ្មានត្រូវក៏គ្មានខុសដែរ តែមនុស្សលោកធ្វើការវែកញែករវាងត្រូវនិងខុសនេះទៅតាមតម្រូវចិត្តរបស់ខ្លួន។

ព្រះពុទ្ធចៀសវាងការវែកញែកទាំងនេះ ហើយទុកលោកនេះដូចជាពពកដែលផាត់រសាត់ទៅ។ ចំពោះព្រះពុទ្ធវត្ថុទាំងឡាយដែលសម្គាល់ឃើញថាល្អ ឬអាក្រក់នោះ សុទ្ធតែជាការថ្លឹងថ្លែង។ ព្រះអង្គដឹងថា អ្វីៗទាំងអស់ដែលវិញ្ញាណចាប់យក ឬទាត់ចោលជារបស់គ្មានស្ថិរភាព។ ហេតុនេះ ព្រះអង្គចៀសវាងអន្ទាក់នៃអាការភាពខាងក្រៅ និងគំនិតវែកញែកវត្ថុ។

2. មនុស្សលោកតោងចាប់យករបស់ទាំងឡាយ ដោយនឹកស្មានថា របស់ទាំងនោះសមនឹងចិត្តខ្លួន។ មនុស្សលោកតោងចាប់យកសុភមង្គល សម្បត្តិទ្រព្យ កិត្តិយស ហើយប្រយុទ្ធនឹងដំណើរជីវិតដោយអស់សង្ឃឹម។

មនុស្សលោកធ្វើការវែកញែកតាមអំពើចិត្ត រវាងអត្ថិភាព ឬភាពវត្ថុដែលមាននៅ និងអនត្ថិភាព ឬភាពដែលគ្មាននៅ រវាងល្អនិងអាក្រក់ រវាងត្រូវនិងខុស។ ចំពោះមនុស្សលោក ជីវិតជាដំណើរបន្តគ្នាមិនចេះដាច់នៃបំណង និងការជំពាក់ចិត្ត ហើយដោយសារហេតុនេះ មនុស្សលោកត្រូវតែទទួលរងនូវការបំភាន់ភ្នែកនៃទុក្ខវេទនា។

កាលមួយនោះ មានបុរសម្នាក់ធ្វើដំណើរឆ្ងាយទៅៗ ដល់មាត់ស្ទឹងមួយ។ គាត់គិតតែម្នាក់ឯងថា: «មាត់ស្ទឹងម្ខាងនេះពិបាកហើយគ្រោះថ្នាក់ណាស់ តែមាត់ស្ទឹងម្ខាងនោះវិញដូចជាស្រួលដើរហើយសុខផង តែអញធ្វើដូចម្តេចនឹងឆ្លងទៅបាន ! » ។ គាត់ក៏យកមែកឈើ និងដើមបបុសចងធ្វើជាក្បូន ហើយឆ្លងរួចទៅដល់មាត់ស្ទឹងម្ខាងនោះទៅដោយសុវត្ថិភាព។ ដល់ហើយគាត់ក៏ស្រដីតែម្នាក់ឯងថា: «ក្បូននេះផ្តល់ប្រយោជន៍

ឲ្យដល់អញច្រើនណាស់ក្នុងការឆ្លងស្ទឹង អញមិនត្រូវបោះបង់វាចោលឲ្យពុករលួយនៅនឹងមាត់ស្ទឹងនេះទេ អញត្រូវតែនាំយកវាទៅជាមួយអញ»។ គិតដូច្នេះហើយគាត់ក៏សណ្ដូនយកវត្ថុធ្ងន់ឥតប្រយោជន៍នោះទៅតាមខ្លួនគាត់ទៅ។ តើគេអាចថាបុរសនោះ ប្រកបដោយគតិបណ្ឌិតបានដែរឬទេ?។

រឿងឧបមានេះបានន័យថា សូម្បីតែវត្ថុល្អក៏ដោយ តែកាលណាវាទៅជាវត្ថុធ្ងន់ឥតប្រយោជន៍ ត្រូវតែបោះបង់វាចោល ហើយជាងនេះទៅទៀត បើវាជាវត្ថុអាក្រក់នុ៎ះ រឹតតែត្រូវបោះបង់ចោលទៅទៀត។ ព្រះពុទ្ធបានប្រដៅខ្លួនព្រះអង្គ ឲ្យចៀសវាងការពិភាក្សាឥតប្រយោជន៍ និងមិនសំខាន់។

3. វត្ថុទាំងឡាយមិនមានមកឬបាត់ទៅទេ វត្ថុទាំងឡាយមិនកើតឡើងឬវិនាសទៅទេ។ ដូច្នេះ គ្មានអ្វីដែលចំណេញឬខាតទេ។

ព្រះពុទ្ធទូន្មានថា វត្ថុទាំងឡាយមិនកើតឡើង និងមិនវិនាសទៅទេ ព្រោះថា វត្ថុទាំងនោះវាហួសពីការពោល

អះអាងថា មានឋិតនៅផង និងការប្រកែកថា គ្មានឋិតនៅផង។ បានសេចក្តីថា វត្ថុនីមួយៗដោយវាជាការស្របគ្នានឹងដំណើរបន្តគ្នាមិនដាច់នៃហេតុនិងល័ក្ខខ័ណ្ឌ វាមិនមាននៅជាពិតប្រាកដទេ ហើយគេអាចថា វាមិនមានឋិតនៅយ៉ាងនេះបាន។ តែព្រមគ្នានោះ ពីព្រោះតែវាជាលទ្ធផលនៃហេតុនិងល័ក្ខខ័ណ្ឌ គេមិនអាចថាវាមិនមានឋិតនៅនោះបានទេ។

ការជាប់ចិត្តនឹងវត្ថុមួយ ដោយសារតែសម្រស់វត្ថុនោះជាឫសគល់នៃការភាន់គតិ។ បើគេមិនជាប់ចិត្តនឹងសម្រស់នោះទេ ការស្មានយល់ខុស និងការរមិលមើលឃើញមិនទំនងនឹងមិនមានទេ។ ការបានត្រាស់ដឹង គឺជាគតិបណ្ឌិតដែលនាំឲ្យមើលឃើញនូវការពិតនេះ ហើយនិងនាំឲ្យចៀសវាងនូវការរមិលយល់មិនសមហេតុសមផលនេះ។

ពិភពលោកតាមពិត វាដូចជាការយល់សប្តិ ហើយរតនសម្បត្តិក្នុងលោកនេះ សុទ្ធតែជារបស់ប្រលោមបំភាន់ភ្នែក។ បីដូចជាសភាពផ្សេងៗ ឃើញពីចម្ងាយនៅក្នុងផ្ទាំងគំនូរមួយ វត្ថុទាំងឡាយគ្មានអ្វីជាពិតប្រាកដនៅក្នុងខ្លួនឯងទេ តែវា

បីដូចជាអ័ព្ទដែលត្រូវកម្តៅ។

4. ការជឿថា វត្ថុទាំងឡាយដែលកើតអំពីហេតុផ្សេងៗ រាប់មិនអស់អាចឋិតមាននៅរហូតនោះ ជាកំហុសធំមួយ ដែលហៅថា ទ្រឹស្តីអំពីភាពឋិតថេរ។ តែក៏ជាកំហុសធំមួយទៀតដែលហៅថា ទ្រឹស្តីអំពីភាពមិនមានឋិតនៅ ក្នុងការណ៍ដែលជឿថា វត្ថុទាំងឡាយនឹងវិនាសបាត់អស់គ្មានសល់អ្វីឡើយ។

ការយល់សើៗថា រស់រហូតឬស្លាប់រហូតមានឋិតថេរនៅ ឬគ្មានឋិតថេរនៅ មិនបានន័យទៅលើសភាពជាខ្លឹមនៃវត្ថុទេ វាបានន័យទៅលើតែអាការខាងក្រៅនៃវត្ថុ ដែលមើលឃើញដោយភ្នែកស្រវាំងរបស់មនុស្សលោកតែប៉ុណ្ណោះ។ ដោយសារចំណង់មនុស្សលោក ជាប់ចិត្តទៅលើអាការខាងក្រៅនៃវត្ថុទាំងនោះ។ តែសភាពខាងក្នុងដែលជាខ្លឹមសារនៃវត្ថុទាំងឡាយវាគ្មានទាក់ទងនឹងការវែកញែកបំបែក ឬការជំពាក់ចិត្តណាមួយឡើយ។

ពីព្រោះតែអ្វីៗ ទាំងអស់កើតឡើងដោយសារ ហេតុនិងល័ក្ខខ័ណ្ឌដែលបន្តគ្នាមិនចេះចប់ អាការខាងក្រៅនៃវត្ថុផ្លាស់

ឬរជានិច្ចជាកាល។ បានសេចក្ដីថា វាគ្មានភាពឋិតថេរក្នុងខ្លួនវា ឲ្យដូចជាសារជាតិពិតប្រាកដនោះទេ។ ដោយសារតែការផ្លាស់ប្ដូរមិនចេះចប់នៃអាការខាងក្រៅនេះហើយ ដែលនាំឲ្យយើងស្រឡាញ់វត្ថុទាំងឡាយ ក្នុងការភាន់ភ្នែក ឬការយល់សប្តិ។ ប៉ុន្តែថ្វីបើមានការផ្លាស់ប្ដូរមិនចេះចប់ នៃសម្បកក្រៅយ៉ាងនេះក៏ដោយ វត្ថុជាតិទាំងឡាយ ក្នុងសភាពជាសារជាតិឋិតនៅជានិច្ច ហើយមិនប្រែប្រួលទេ។

ចំពោះមនុស្សលោក ស្ទឹងហាក់ដូចជាស្ទឹង។ តែចំពោះទមិឡអន្សុរិវ៉ៃយ៍ដែលទុកទឹកជាអណ្ដាតភ្លើង ស្ទឹងហាក់ដូចជាភ្លើង។ ហេតុនេះ និយាយថាមានស្ទឹងចំពោះមនុស្សលោក វាមានអត្ថន័យមួយ តែបើនិយាយចំពោះខ្មោចបិសាច វាគ្មានន័យទេ។

ដូចគ្នានេះ គេអាចនិយាយថាៈ «វត្ថុទាំងឡាយជារបស់ប្ដឹនភ្នែក មិនអាចថាមានឬអត់បានទេ»។

ម្យ៉ាងទៀត ជាការយល់ច្រឡំមួយទៀត ដែលវែកញែកជីវិតមិនឋិតថេរនេះ ពីជីវិតមិនចេះប្រែប្រួលនៃសេចក្ដីពិតនោះ។ គេមិនអាចសន្និដ្ឋានបានថា ក្រៅពីពិភពដែលជាអាការខាងក្រៅ ហើយដែលប្រែប្រួលនេះ វានឹងមានពិភព

លោកមួយទៀត ដែលមិនចេះប្រែប្រួលនោះបានទេ។ ទុកលោកនេះជាពិភពមិនពិតថេរក៏ខុស ហើយទុកដូចជាពិភពពិតប្រាកដក៏ខុស។

ប៉ុន្តែមនុស្សល្ងង់ខ្លៅក្នុងលោកនេះគិតថា លោកនេះវាពិតប្រាកដ ហើយខំប្រព្រឹត្តទៅតាមការយល់ឃើញមិនទំនងនេះ។ តែដោយលោកនេះជាការបំភាន់ភ្នែក អំពើទាំងឡាយរបស់មនុស្សលោក ដោយយោលទៅតាមការយល់ខុសនេះ មិនអាចនាំទៅរកអ្វីក្រៅពីទុក្ខវេទនានោះបានទេ។

បុគ្គលប្រកបដោយគតិបណ្ឌិត ដោយយល់ជាក់ថាលោកនេះគ្រាន់តែជាការប្លឹនភ្នែកនោះ មិនប្រព្រឹត្តទៅហាក់ដូចជាលោកនេះវាពិតប្រាកដនោះទេ។ ប្រព្រឹត្តយ៉ាងនេះបុគ្គលប្រកបដោយគតិបណ្ឌិតនោះ អាចចៀសផុតពីទុក្ខ។

IV

# ផ្លូវកណ្តាល

1. សម្រាប់អ្នករើសយកផ្លូវទៅកាន់ការត្រាស់ដឹង មានការហួសប្រមាណពីរប្រការ ដែលត្រូវចៀសវាង។ ទី១ គឺបណ្តោយខ្លួន

ជ្រុលហួសហេតុ ឲ្យលុះទៅតាមអំណាចចំណង់នៃរូបកាយ។ ទី២ គឺផ្ទុយពីខាងលើនេះ មានបុគ្គលខ្លះសម្រេចចិត្តផ្តាច់ការទាក់ទងនឹងជីវភាពលោកនេះ ទៅធ្វើតបធម៌ចង្រ្កមភាវនាដោយធ្វើបាបខ្លួន និងវិញ្ញាណតឹងតែងហួសហេតុ។

ផ្លូវប្រសើរបំផុត ដែលហួសពីភាពហួសហេតុទាំង២ប្រការខាងលើនេះ ហើយដែលនាំឲ្យបានដល់នូវការបានត្រាស់ដឹងបានប្រកបនូវគតិបណ្ឌិត និងបានប្រកបនូវសេចក្តីស្ងប់នៃចិត្ត សន្មត់បានថា ផ្លូវកណ្តាល។ តើផ្លូវកណ្តាលនោះជាអ្វីទៅ? គឺជាផ្លូវត្រូវ ដែលចែកចេញជាប្រាំបីផ្នែកគឺៈ ការយល់ឃើញត្រូវ១ បំណងល្អត្រឹមត្រូវ១ ពាក្យសម្តីត្រឹមត្រូវ១ ចរិយាត្រឹមត្រូវ១ របៀបរស់នៅត្រឹមត្រូវ១ ការខំប្រឹងប្រែងត្រឹមត្រូវ១ ការប្រុងប្រយ័ត្នត្រឹមត្រូវ១ និងការសង្រួមចិត្តត្រឹមត្រូវ១។

ដូចបានស្តីពីលើមកហើយ វត្ថុទាំងឡាយកើតឡើង ហើយវិនាសទៅវិញ ដោយសារតែការមកជាបន្តៗគ្នាមិនចប់នៃហេតុជាច្រើនរាប់មិនអស់។ ចំពោះជនល្ងង់ខ្លៅ អ្នកខ្លះមើលឃើញថាមានឋិតថេរនៅ អ្នកខ្លះទៀតមើលឃើញថាគ្មានឋិតនៅ។

តែចំពោះជនជាបណ្ឌិតវិញ គេមើលឃើញហួសពីការមាន ឋិតនៅ ឬគ្មានឋិតនៅនេះទៅទៀត ចំពោះវត្ថុទាំងឡាយដែល ហួសពីការទាំងពីរនេះ។ ការមើលឃើញរបៀបនេះ ក៏ជាផ្លូវក ណ្តាលមួយដែរ។

2. ដូចជាអណ្តែតឈើមួយដែលអណ្តែតក្នុងស្ទឹង បើវាមិនកៀង នឹងថ្ម មិនលិចទៅបាតស្ទឹង មិនត្រូវបានគេស្រង់វាឡើង ឬ បំផ្លាញវាចោលនោះទេ វានឹងអណ្តែតធ្លាក់ទៅក្នុងសមុទ្រជាទី បញ្ចប់។ ជីវិតក៏ដូចជាអណ្តែតឈើនៅក្នុងស្ទឹងដ៏ធំនោះដែរ។ បើ គេមិនទាក់ជាប់នឹងជីវិត ដែលលុះទាំងស្រុងទៅតាមអំណាច តណ្ហា ឬផ្តាច់ទាំងស្រុងអំពីជីវិតលោកនេះ ដោយធ្វើបាបខ្លួន ឯងហួសហេតុ បើគេមិនក្រអើតក្រអោងនឹងគុណសម្បត្តិរបស់ ខ្លួន បើគេមិនជាប់ជំពាក់នឹងអំពើអាក្រក់ ហើយបើក្នុងការ ស្វែងរកការត្រាស់ដឹង គេមិនមានកង្វល់ ឬញញើតញញើម ប្រទាក់ប្រទងនឹងការបំភាន់ភ្នែកនោះទេ បានន័យថា គេដើរ តាមផ្លូវកណ្តាល។

កាលណាគេដើរតាមផ្លូវទៅកាន់ពន្លឺត្រាស់ដឹង ការសំខាន់

គឺចៀសវាង កុំបណ្តោយខ្លួនឲ្យលុះទៅតាមការប្រកាន់ចិត្ត ហួសប្រមាណ ទាំងពីរប្រភេទនេះ បានន័យថា ត្រូវតែដើរ តាមផ្លូវកណ្តាលជានិច្ច។

បើដឹងថាវត្ថុទាំងឡាយវាឋិតមាននៅក៏មិនមែន ឬមិន ឋិតមាននៅក៏មិនមែននោះ ហើយបើនឹកឃើញថា សភាពនៃ វត្ថុជាតុវាដូចជាការយល់សប្តិនោះ ត្រូវតែចៀសវាងកុំឲ្យអភិ-មានះ ដែលទាក់ទងទៅនឹងការវាយឫកខ្ពស់តម្កើងខ្លួន ហើយ និងការចង់ឲ្យគេអួតសរសើរ អំពើល្អរបស់ខ្លួននោះវាដឹកមុខ បាន។ ត្រូវចៀសវាង កុំឲ្យអ្វីៗសព្វសារពើវាទាក់ទាញដឹកនាំ បានឡើយ។

បើបុគ្គលណាចង់ចៀសវាងការធ្លាក់ចូលទៅក្នុងចរន្តនៃ ចំណង់របស់ខ្លួន ជាដំបូងបង្អស់ បុគ្គលនោះត្រូវតែហាត់បំពត់ ចិត្តកុំឲ្យជំពាក់ទាក់ជាប់នឹងវត្ថុទាំងឡាយ ខ្វាចក្រែងវាធ្លាប់ ហើយទៅជាជាប់ចិត្តវើខ្លួនពុំរួចពីវត្ថុទាំងនោះ។ ចំពោះអត្ថិ-ភាព ឬភាពមានឋិតនៅក្តី អនត្ថិភាព ឬភាពគ្មានឋិតនៅក្តី ចំពោះអ្វីៗដែលជាខាងក្នុង ឬជាខាងក្រៅក្តី ចំពោះវត្ថុល្អ ឬ អាក្រក់ក្តី ចំពោះវត្ថុពិតឬក្លែងក្លាយក្តី គេមិនត្រូវជាប់ជំពាក់

ចិត្តជាមួយទេ។

បើគេជាប់ជំពាក់នឹងវត្ថុទាំងនោះ វាបានតែក្នុងមួយរយៈពេលដ៏ខ្លីប៉ុណ្ណោះ មិនយូរទេជីវិតក្នុងភាពភាន់គតិនឹងចាប់ផ្តើមហើយ។ អ្នកដែលដើរតាមផ្លូវប្រសើរនៃពន្លឺត្រាស់ញាណមិនត្រូវរក្សាទុកនូវការសោកស្តាយចំពោះអតីតកាល ហើយមិនខ្វាចចំពោះអនាគតទេ គេត្រូវតែចាប់យកវត្ថុតាមភាពដែលវាមកដល់ដោយសតិស្មើហើយស្ងប់។

3. ពន្លឺត្រាស់ដឹងគ្មានរូបរាងជាក់លាក់ទេ មិនអាចចេញស្តែងឡើងតាមសភាពណាមួយបានទេ។ ហេតុនេះ នៅក្នុងពន្លឺត្រាស់ដឹង គ្មានអ្វីដែលត្រូវបំភ្លឺទេ។

ពន្លឺត្រាស់ដឹងមានឡើងដោយសារតែមាន សេចក្តីល្ងង់ខ្លៅ និងការភាន់ភ្នែកតែប៉ុណ្ណោះ។ បើសេចក្តីទាំងពីរនេះវិនាសបាត់ទៅ ពន្លឺត្រាស់ដឹងក៏បាត់ទៅដែរ។ ផ្ទុយនឹងសេចក្តីនេះ ក៏ជាការពិតដែរគឺថា: មានសេចក្តីល្ងង់ខ្លៅនឹងការភាន់ភ្នែក ដោយសារមានពន្លឺត្រាស់ដឹង។ កាលណាពន្លឺត្រាស់ដឹងចប់ហើយ សេចក្តីល្ងង់ខ្លៅនិងការភាន់ភ្នែកក៏ចប់ទៅដែរ។

ហេតុដូច្នេះ បុគ្គលត្រូវតែចៀសវាងការទុកពន្លឺត្រាស់ដឹង ជាវត្ថុមួយដែលត្រូវចាប់យក ពុំនោះទេ ពន្លឺត្រាស់ដឹងនឹងទៅ ជាឧបសគ្គមួយមិនខាន។ កាលណាវិញ្ញាណដែលនៅក្នុង ភាពងងឹត បានទៅដល់ពន្លឺត្រាស់ដឹងហើយ វានឹងរលត់បាត់ ហើយព្រមជាមួយនឹងការរលត់បាត់នេះ អ្វីដែលគេហៅថា «ពន្លឺត្រាស់ដឹង» ក៏រលត់បាត់ដែរ។

ដរាបណាយើងចង់បានពន្លឺត្រាស់ដឹង ដូចជាវត្ថុមួយ ដែលត្រូវតែចាប់យក បានន័យថា យើងនៅតែមានការភាន់ ភ្នែក យល់ច្រឡំនៅឡើយ។ ហេតុដូច្នេះ ក្នុងការដើរតាមផ្លូវ ទៅកាន់ពន្លឺត្រាស់ដឹង យើងមិនត្រូវគិតតែពីឈោងចាប់យក ពន្លឺនេះទេ ហើយបើយើងបានទៅដល់ពន្លឺនេះហើយ យើង មិនត្រូវនៅបង្អែបង្អង់វិលវល់ក្នុងពន្លឺនោះទេ។

បានសម្រេចការត្រាស់ដឹងតាមរបៀបនេះ បានន័យថា វត្ថុ ទាំងឡាយវាក្លីចែងចាំងឡើងដោយខ្លួនឯង។ ហេតុដូច្នេះ យើង ត្រូវដើរតាមផ្លូវទៅកាន់ពន្លឺត្រាស់ដឹងរហូត លុះត្រាតែតណ្ហា លោកិយ និងពន្លឺត្រាស់ដឹង វាឡើងមានភាពដូចគ្នាសុទ្ធសាធ នៅក្នុងគតិអារម្មណ៍របស់យើង។

4. សេចក្តីយល់ឃើញចំពោះឯកភាពសាកលនេះ គឺថាវត្ថុទាំងឡាយក្នុងសភាពជាសារខ្លឹមរបស់វា គ្មានសញ្ញាអ្វីជាសម្គាល់ទេ: នេះគេហៅថា «ដំណើរទទេ» ឬសុញ្ញាភាព។ សុ-ញ្ញាភាព បានន័យថា គ្មានសារជាតិ ភាពគ្មានកើត គ្មានសភាពជារបស់ខ្លួន គ្មានទ្វិកភាព ឬភាពពីរខុសគ្នា។ ព្រោះតែវត្ថុទាំងឡាយគ្មានរូបរាង គ្មានលក្ខណៈនៅក្នុងខ្លួនឯងផ្ទាល់នោះហើយ គេអាចនិយាយបានថា វត្ថុទាំងនោះមិនកើតឡើង ឬវិនាសបាត់ទៅទេ។ ក្នុងភាពជាសារវន្តសំខាន់នៃវត្ថុទាំងឡាយ គ្មានអ្វីដែលអាចឲ្យធ្វើការវែកញែកបានទេ ដូច្នេះហើយបានជាយើងអាចថា វត្ថុទាំងឡាយគ្មានសារជាតិទេ។

ដូចបានដោបញ្ជាក់មកហើយ វត្ថុទាំងអស់កើតឡើងនិងវិនាសទៅ ដោយសារតែការជួបប្រទះគ្នានៃហេតុនិងល័ក្ខខ័ណ្ឌ។ គ្មានអ្វីដែលឋិតនៅដោយឯកច្ឆ័ន្ទទាំងស្រុងទេ។ វត្ថុនីមួយៗទាក់ទងនិងវត្ថុដទៃទៀតជានិច្ច។

កន្លែងណាមានពន្លឺ វាក៏មានភាពងងឹតដែរ។ កន្លែងណាមានភាពវែង វាក៏មានភាពខ្លីដែរ។ កន្លែងណាមានពណ៌ស វា

ក៏មានពណ៌ខ្មៅដែរ។ ដូចគ្នានេះ ដោយសភាពរបស់ខ្លួនផ្ទាល់នៃវត្ថុទាំងឡាយ មិនមានឋិតនៅដោយឯកឯងទេ នោះ គេអាចថា វត្ថុទាំងឡាយគ្មានសារជាតិទេ។

យោលទៅតាមការពិចារណាដូចគ្នានេះ ពន្លឺត្រាស់ដឹងមិនអាចឋិតមានបាន ដោយឥតមានសេចក្ដីល្ងង់ខ្លៅនោះទេ សេចក្ដីល្ងង់ខ្លៅ ក៏មិនឋិតមានបានដោយឥតមានពន្លឺត្រាស់ញាណនោះដែរ។ បើវត្ថុទាំងឡាយ ក្នុងសភាពជាសារវន្តរបស់វា មិនខុសគ្នាទេនោះ តើអាចមានទ្វិកភាព ឬភាពពីរខុសគ្នាដែរឬទេ?។

5. មនុស្សលោកគិតថា ខ្លួនឯងនេះ ត្រូវបានចងជាប់ជាមួយនឹងការកើតហើយនិងការស្លាប់។ តែការយល់របៀបនេះមិនអនុលោមទៅតាមសេចក្ដីពិតទេ។

កាលណាគេអាចយល់ជាក់នូវសេចក្ដីពិតនេះ គេនឹងយល់ច្បាស់អំពីដំណើរគ្មានភាពពីរខុសគ្នា ចំពោះការកើតនិងការស្លាប់នេះ។

ព្រោះតែបុគ្គលរាល់រូបរក្សាទុកនូវគំនិតជារបស់អញ

បានជាបុគ្គលទាំងនោះមានគំនិតគិតនិយមថា ជារបស់ផងខ្លួន។ ប៉ុន្តែ ដោយហេតុតែគ្មានអ្វីដែលជាអាត្មាអញទេនោះ គ្មានអ្វីដែលអាចចាត់ទុកជារបស់អាត្មាអញបានទេ។ កាលណាគេអាចយល់ជាក់នូវសេចក្តីពិតនេះ គេនឹងអាចយល់ជាក់នូវដំណើរគ្មានភាពពីរខុសគ្នា។

មនុស្សលោកជាប់ចិត្តនឹងការវែកញែកភាពបរិសុទ្ធ និងភាពមិនបរិសុទ្ធ តែក្នុងធម្មជាតិវត្ថុ ការវែកញែករបៀបនេះគ្មានទេ។ ការវែកញែកនេះ កើតមកអំពីការរមិលយល់ខុស និងមិនទំនង ដែលមាននៅក្នុងចិត្តមនុស្សលោកតែប៉ុណ្ណោះ។

របៀបដូចគ្នានេះ មនុស្សលោកវែកញែកសម្គាល់នូវភាពអាក្រក់និងភាពល្អ តែភាពអាក្រក់និងភាពល្អនេះមិនឋិតនៅដោយឯកឯងដាច់ស្រឡះពីគ្នាទេ។ បុគ្គលដែលដើរតាមផ្លូវទៅកាន់ពន្លឺត្រាស់ដឹង យល់ច្បាស់ថា ភាពពីរខុសគ្នាយ៉ាងនេះគ្មានទេ។ ហើយដោយសារហេតុនេះ បុគ្គលនោះមិនសរសើរភាពល្អ ហើយមិនដាក់ទោសភាពអាក្រក់ទេ មិនមើលងាយភាពល្អ ហើយបេះអត់ឱនចំពោះភាពអាក្រក់។

ជាធម្មតា មនុស្សលោកខ្លាចទុក្ខវេទនា ហើយប្រាថ្នាចង់បានសុភមង្គល។ តែបើពិនិត្យការវែកញែកនេះឲ្យហ្មត់ចត់ទៅ ឃើញថា ជួនកាលទុក្ខវេទនានាំឲ្យមានសុភមង្គល ហើយជួនកាលទៀត សុភមង្គលនាំឲ្យមានទុក្ខវេទនា។ បណ្ឌិតហាត់រៀនឲ្យចេះសម្របនឹងកាលៈទេសៈផ្លាស់ប្តូរនៃជីវិត ដោយសតិអារម្មណ៍ស្មើ មិនរំភើបនឹងជោគជ័យ មិនស្រយុត នឹងបរាជ័យ។ យ៉ាងនេះហើយដែលបណ្ឌិតយល់ជាក់នូវដំណើរគ្មានភាព២ ខុសគ្នា ឬទ្វិកភាព។

ហេតុដូច្នេះ ពាក្យថ្លែងអំពីភាពពីរខុសគ្នា ដូចជាបិតមាននៅ និងគ្មានបិតនៅ តណ្ហាលោកិយនិងការចេះដឹងពិតប្រាកដ បរិសុទ្ធនិងមិនបរិសុទ្ធ ល្អនិងអាក្រក់ ជាដើម សុទ្ធតែពាក្យផ្ទុយគ្នា ដែលមាននៅក្នុងគំនិតបុគ្គលម្នាក់ៗ តែប៉ុណ្ណោះវាពុំបានជាពាក្យដែលថ្លែងនូវសភាពពិតនោះទេ។ កាលណាគេផ្តាច់ផុតពីពាក្យទាំងនេះ ហើយនិងពីចិត្តរំជួលដែលកើតមានឡើងនោះបាន គេនឹងយល់ជាក់នូវដំណើរពិតជាសាកលនៃភាពទទេសូន្យ ដែលហៅថា សុញ្ញាភាព។

6. ដូចជាផ្កាឈូកដែលបរិសុទ្ធ និងប្រកបដោយក្លិនក្រអូប ឈ្ងុយឈ្ងប់ មិនដុះនៅក្នុងទីវាលរាបស្មើខ្ពស់ល្អនោះទេ វាទៅដុះនៅក្នុងទីទំនាបបឹងភក់ឯនោះទៅវិញ។ ពន្លឺត្រាស់ដឹងដ៏បរិសុទ្ធ ដែលជាសភាពព្រះពុទ្ធ ក៏សាចចេញឡើងពីពំនូកលាមកនៃតណ្ហាលោកិយយ៉ាងនេះដែរ។ សូម្បីតែការយល់ខុសនិងការភាន់ភ្នែក ដែលកើតឡើងពីតណ្ហាលោកិយ ក៏អាចទៅជាគ្រាប់ពូជនៃសភាពព្រះពុទ្ធដែរ។

បើអ្នកមុជរាវរកត្បូងគជ់ចង់រកឲ្យឃើញនូវត្បូងគជ់ អ្នកនោះត្រូវតែមុជចុះឲ្យដល់បាតសមុទ្រ ដោយមិនខ្លាចញញើតនឹងផ្កាថ្មស្រួចរលែមៗ និងសត្វធ្លាមឃោរឃៅ។ ដូច្នេះមនុស្សលោកត្រូវតែប្រឈមមុខប្រឆាំងនឹងគ្រោះថ្នាក់ នៃតណ្ហាលោកិយ បើសិនជាប្រាថ្នាចង់បានគជ់ដ៏មានតម្លៃនៃពន្លឺត្រាស់ដឹង។ ជាដំបូង បុគ្គលតែងតែវង្វេងក្នុងភ្នំដែលប្រកបដោយផ្ទាំងថ្មខ្ពស់ចោតនៃអត្តទត្តភាព និងអភិមានះ មុននឹងភ្ញាក់គំនិត គិតចង់ស្វែងរកផ្លូវទៅកាន់ពន្លឺត្រាស់ដឹង។

មានបុរាណនិទានមួយថា មានតាបសមួយអង្គ ដោយចង់រកឲ្យឃើញផ្លូវពិតប្រាកដខ្លាំងពេក តាបសនោះវារឡើង

លើភ្នំមួយ មានផ្ទាំងថ្មច្រូងច្រាង ស្រួចៗ ដូចមុខលំពែងហើយ លោតទម្លាក់ខ្លួនទៅក្នុងភ្នក់ភ្លើងឆេះសន្ធោសន្ធៅ អត់ធ្មត់នឹងគ្រោះថ្នាក់គ្រប់បែបយ៉ាង ដោយសារតែមានបំណងដ៏មុតមាំនោះៗ តាបសឥសីប្រឈមមុខតស៊ូនឹងគ្រោះថ្នាក់គ្រប់បែបយ៉ាងនៃផ្លូវ ក៏បានជួបប្រទះ នឹងខ្យល់ត្រជាក់រំភើយនៅលើភ្នំដែលពោរពេញទៅដោយថ្មស្រួចៗ មុខដូចលំពែងនៃអត្ត-ទត្តភាព ហើយនឹងភ្នក់ភ្លើងនៃទោសៈ ហើយទីបំផុតតាបសនោះក៏បានយល់ជាក់ថា អត្តទត្តភាពនិងតណ្ហាលោកិយ ដែលបានខំតស៊ូទទួលរងនោះហើយ ជាពន្លឺត្រាស់ដឹងៗ

7. សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ នាំយើងទៅកាន់ភាពគ្មានពីរខុសគ្នា ហើយនិងនាំយើងឲ្យចេញផុតពីគំនិតវែកញែកតាមភាពពីរខុសគ្នាៗ ជាកំហុសមួយដែលខំរិះរកវត្ថុដែលស្មានថាល្អនិងពិត ហើយរត់គេចពីវត្ថុ ដែលស្មានថាអាក្រក់និងមិនពិតៗ

បើខំតែទទូចថា អ្វីៗទាំងអស់វាទទេ និងមិនឋិតថេរនោះក៏ជាការយល់ច្រឡំដ៏ធំ ដូចជាទទូចគិតថា អ្វីៗទាំងអស់វាមិន

ចេះប្រែប្រួលដែរ។ បុគ្គលណាជាប់ចិត្តជឿថា មានអាត្មាអញ ជាការយល់ច្រឡំមួយ ព្រោះការជំពាក់ចិត្តលុះក្នុងជំនឿបែប នេះ និងនាំឲ្យបុគ្គលនោះចៀសពុំផុតពីសេចក្តីលោភលន់ មិនចេះឆ្អែតឆ្អន់ ហើយទីបំផុតចៀសពុំផុតពីទុក្ខវេទនានោះ បានទេ។ តែបើបុគ្គលនោះមានជំនឿថា គ្មានអាត្មាអញក៏ជា ការភាន់ច្រឡំមួយដែរ ពីព្រោះការជឿរបៀបនេះ នាំឲ្យការខំ ស្វែងប្រតិបត្តិតាមគន្លងការពិតថ្លៃថ្លានោះ ឲ្យទៅជាការឥត ប្រយោជន៍។ បើការទទូចអះអាងថា អ្វីៗទាំងអស់សុទ្ធតែជា ទុក្ខ ក៏ជាកំហុសមួយ ឬថាអ្វីៗទាំងអស់សុទ្ធតែជាសុភមង្គល ក៏ ជាកំហុសមួយដែរ។ ព្រះពុទ្ធបង្ហាត់បង្ហាញយើងឲ្យប្រកាន់ យកនូវផ្លូវកណ្តាល ដែលចាកផុតអំពីការវិនិច្ឆ័យហួសហេតុ ផ្ទុយគ្នាទាំងពីរនេះ ហើយដែលរំលាយ ទ្វិកភាពឬភាពពីរ ខុសគ្នា ឲ្យចូលគ្នាជាភាពតែមួយ៕

# ចំពូកទី ៣

# សភាពព្រះពុទ្ធ

I

## ចិត្តបរិសុទ្ធ

1. មនុស្សលោកមានចិត្តគំនិតផ្សេងៗគ្នា។ ខ្លះជាបណ្ឌិត ខ្លះជាពាល ខ្លះមានកិរិយាល្អប្រពៃ ខ្លះមានចរិតអាក្រក់ជួរជាតិ ខ្លះស្លូតសុភាព ខ្លះកាចឃោរឃៅ ខ្លះមានចិត្តបរិសុទ្ធ ខ្លះមានចិត្តប្រកបដោយមន្ទិលសៅហ្មង។ ប៉ុន្តែភាពខុសគ្នាទាំងនេះមិនជាសំខាន់ប៉ុន្មានទេ បើគិតទៅដល់ការបានសម្រេចការត្រាស់ដឹង។ លោកនេះប្រៀបបាននឹងបឹងឈូកមួយ ដែលមានរុក្ខជាតិជាច្រើនបែបយ៉ាងដុះពាលពេញ។ មានផ្កាប្រកបដោយពណ៌ផ្សេងៗគ្នា ផ្កាខ្លះមានពណ៌ស ខ្លះមានពណ៌ផ្កាឈូក ខ្លះខៀវ ខ្លះទៀតលឿង ផ្កាខ្លះរីកនៅក្នុងទឹក រុក្ខជាតិខ្លះមានស្លឹកដុះឡើងនៅព្រៀបនឹងផ្ទៃទឹក រុក្ខជាតិខ្លះទៀតមានស្លឹកដុះឡើងផុតពីទឹក។ មនុស្សជាតិរឹតតែមានភាពខុស

គ្នាច្រើនជាងនេះទៅទៀត។ មនុស្សជាតិក៏មានភេទខុសគ្នាដែរ តែនេះមិនជាសំខាន់ទេ ពីព្រោះថាតាមការហាត់ហ្វឹកហ្វឺនល្អ ស្ត្រីភេទក៏អាចទៅដល់ពន្លឺត្រាស់ដឹងបានដូចបុរស-ភេទដែរ។

ដើម្បីនឹងឲ្យបានទៅជាព្រហ្មចារីចំណានម្នាក់ ត្រូវតែមានលក្ខណៈសម្បត្តិប្រាំយ៉ាងគឺ: សុខភាពល្អ១ សេចក្តីទុកចិត្តលើខ្លួនឯង១ សេចក្តីវៀសវៃ១ បំណងស្មោះត្រង់ក្នុងខ្លួន១ និងព្រហ្មចារិភាព១។ ដើម្បីប្រតិបត្តិតាមផ្លូវប្រសើរខ្ពង់ខ្ពស់នៃពន្លឺត្រាស់ដឹង ដែលព្រះពុទ្ធបានបង្ហាញប្រាប់ ត្រូវតែមានលក្ខណៈសម្បត្តិដូចគ្នានេះដែរ។ បើមានលក្ខណៈសម្បត្តិទាំងនេះហើយ ទោះបីជាបុរសភេទក្តី ឬស្ត្រីភេទក្តី ក៏អាចទៅដល់ពន្លឺត្រាស់ដឹងបានដែរ។ ជាចាំបាច់ ត្រូវតែហាត់រៀនតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធកុំបង្អែបង្អង់ឡើយ ពីព្រោះមនុស្សលោកមានសភាពមួយ ដែលអាចនាំឲ្យបានសម្រេចនូវពន្លឺត្រាស់ដឹង។

2. កាលណាគេប្រតិបត្តិតាមផ្លូវពន្លឺត្រាស់ដឹង គេនឹងឃើញព្រះពុទ្ធយ៉ាងប្រាកដនឹងភ្នែករបស់គេ ហើយគេនឹងជឿប្រាកដ

លើព្រះអង្គនៅក្នុងចិត្តរបស់គេផ្ទាល់។ ភ្នែកដែលមើលឃើញព្រះពុទ្ធ និងចិត្តដែលជឿលើព្រះអង្គ គឺពិតជាភ្នែក និងចិត្តរបស់បុគ្គលដែលកំពុងវង្វេងវិលវល់នឹងការកើត និងការស្លាប់នៃលោកនេះឯង។

បើព្រះមហាក្សត្រមួយព្រះអង្គត្រូវមានកង្វល់នឹងចោរខ្មួយ ព្រះមហាក្សត្រនោះ ត្រូវតែរកឲ្យឃើញជំរំនៃពពួកចោរខ្មួយទាំងនោះ មុននឹងវាយប្រហារវា។ យ៉ាងណាមិញ បើបុគ្គលណាត្រូវឡោមព័ទ្ធដោយតណ្ហាលោកិយ បុគ្គលនោះជាដំបូងបង្អស់ ត្រូវតែរិះគិតសម្គាល់រកឲ្យឃើញច្បាស់នូវឫសគល់នៃតណ្ហាទាំងនោះដូច្នោះដែរ។

ជនម្នាក់នៅក្នុងផ្ទះមួយ កាលណាបើកភ្នែកឡើងជាដំបូង ជននោះសម្គាល់ឃើញអ្វីៗ ដែលមាននៅក្នុងបន្ទប់ មុននឹងក្រឡេកទៅតាមបង្អួច ហើយសម្គាល់មើលអ្វីៗ ដែលមាននៅខាងក្រៅ។ ដូចគ្នានេះ យើងមិនត្រូវបើកភ្នែកទៅក្រឡេកមើលអ្វីៗ ដែលនៅខាងក្រៅ មុននឹងយើងបានក្រឡេកមើលអ្វីៗ ដែលមាននៅក្នុងខ្លួនយើងនោះឡើយ។

បើប្រសិនជាមានវិញ្ញាណនៅក្នុងរូបកាយ វិញ្ញាណត្រូវ

តែស្គាល់ជាបឋម អ្វីៗដែលមាននៅក្នុងរូបកាយ។ ប៉ុន្តែជាធម្មតា មនុស្សលោករវល់តែនឹងអ្វីៗ ដែលមាននៅជាខាងក្រៅ ហើយយកចិត្តទុកដាក់ដោយតិចតួចស្តួចស្តើងណាស់នឹងអ្វីៗ ដែលមាននៅក្នុងរូបកាយរបស់ខ្លួន។

បើប្រសិនជាវិញ្ញាណវាស្ថិតនៅខាងក្រៅរូបកាយតើវិញ្ញាណនោះ អាចរក្សាការទាក់ទងជាមួយនឹងសេចក្តីត្រូវការនៃរូបកាយបានយ៉ាងដូចម្តេចទៅ? តែតាមពិតរូបកាយយល់នូវអ្វីៗ ដែលវិញ្ញាណដឹង ហើយវិញ្ញាណក៏ដឹងនូវអ្វីៗ ដែលរូបកាយយល់ដែរ។ ដូច្នេះ គេមិនអាចថា វិញ្ញាណនៅខាងក្រៅរូបកាយបានទេ។ តើសារជាតិនៃវិញ្ញាណ វាស្ថិតនៅកន្លែងណាទៅ ? ។

3. តាំងពីអតីតកាលដ៏យូរអង្វែងរកថាមិនបានមកហើយ សត្វលោកត្រូវបានវង្វេងវិលវល់នៅក្នុងសេចក្តីល្ងង់ខ្លៅ ដោយសារតែការសម្រុបទៅតាមអំពើផ្ទាល់របស់ខ្លួន ហើយនិងយល់ច្រឡំចំពោះសេចក្តីជាគោលពីរប្រការ ដូចតទៅនេះ។

ជាបឋម សត្វលោកជឿថា គំនិតវែកញែក ដែលជាឫស

គល់នៃជីវិតកើតនិងស្លាប់នេះ ជាសភាពពិតរបស់ខ្លួន។ ទីពីរ សត្វលោកមិនបានដឹងថា គឺនៅក្នុងគំនិតវែកញែកនោះហើយ ដែលវិញ្ញាណបរិសុទ្ធនៃពន្លឺត្រាស់ដឹង ដែលជាសភាពពិតរបស់ខ្លួនពួននៅ។

កាលណាគេក្តាប់ដៃហើយលើឡើង ភ្នែករបស់គេមើលឃើញការក្តាប់ដៃនេះ ហើយវិញ្ញាណរបស់គេសម្គាល់ឃើញការក្តាប់ដៃនេះ។ តែវិញ្ញាណដែលធ្វើការវែកញែកសម្គាល់ឃើញការក្តាប់ដៃនេះ មិនមែនជាវិញ្ញាណពិតប្រាកដទេ។

គំនិតវែកញែក គឺសម្រាប់សម្គាល់មើលភាពខុសគ្នាតាមការស្រមៃឃើញ ដែលចំណង់លោកលន់ហើយនិងតណ្ហាឯទៀតៗ ដែលទាក់ទងនឹងអាត្មាអញនិយមបានបង្កបង្កើតឡើងតែប៉ុណ្ណោះ។ គំនិតវែកញែក សម្រេចទៅតាមហេតុ និងល័ក្ខ-ខ័ណ្ឌ វាគ្មានអ្វីជាសារជាតិទេ វាប្រែប្រួលជានិច្ច។ តែដោយមនុស្សលោកជឿថា នេះហើយជាវិញ្ញាណពិតរបស់ខ្លួនសេចក្តីយល់ខុស ក៏នាំឲ្យមនុស្សលោកលុះក្នុងអំណាចនៃហេតុ និងល័ក្ខខ័ណ្ឌដែលនាំទៅរកក្តីទុក្ខ។

បុគ្គលម្នាក់លាដៃឡើង ហើយវិញ្ញាណរបស់គេដឹងនូវ

ការលាដៃនេះ។ តែអ្វីដែលកម្រើក? វិញ្ញាណឬដៃ? ឬក៏អត់កម្រើកទាំងពីរ? បើថា ដៃវាកម្រើក វិញ្ញាណក៏វាកម្រើកទៅតាមនោះដែរ។ ប៉ុន្តែបើថាវាអត់កម្រើកទាំងពីរក៏ត្រូវដែរ។ ប៉ុន្តែ វិញ្ញាណដែលកម្រើក គឺជាភាពសើខាងក្រៅនៃវិញ្ញាណតែប៉ុណ្ណោះ មិនមែនជាវិញ្ញាណពិតប្រាកដជាគ្រឹះនោះទេ។

4. ជាគ្រឹះសំខាន់ វិញ្ញាណរបស់បុគ្គលរាល់រូបវាបរិសុទ្ធ ប៉ុន្តែជាធម្មតា វិញ្ញាណនោះប្រឡាក់ជាប់ដោយល្អងធូលីតណ្ហាលោកិយ ដែលកកើតឡើងដោយទំនើងពីទេសកាលផ្សេងៗរបស់ខ្លួន។ វិញ្ញាណមិនបរិសុទ្ធ មិនមែនជាធម្មជាតិសំខាន់នៃបុគ្គលម្នាក់ៗទេ: ពិតជាមានវត្ថុអ្វីមួយជាបន្ថែមនៅក្នុងវិញ្ញាណនោះ ប្រៀបដូចជាអ្នកដែលចូលទៅក្នុងផ្ទះគេដោយបំពាន ឬភ្ញៀវដែលចូលទៅក្នុងផ្ទះមួយ អ្នកនោះមិនមែនជាម្ចាស់ផ្ទះនោះទេ។

ព្រះចន្ទត្រូវបានគ្របដណ្តប់ទៅដោយពពក ជាញឹកញយ តែមិនបានប្រែក្លាយដោយសារពពកនោះទេ: ភាពបរិសុទ្ធ

របស់ព្រះចន្ទនៅតែដដែល។ ដូច្នេះ មិនត្រូវយល់ច្រឡំ ដោយគិតថា វិញ្ញាណមិនបរិសុទ្ធនោះជាវិញ្ញាណពិតប្រាកដរបស់ខ្លួនផ្ទាល់នោះឡើយ។

បុគ្គលត្រូវតែរំលឹករឿងនេះឡើងកុំបីឈប់ឈរ ហើយដាស់តឿនបំភ្លឺសតិរបស់ខ្លួនជានិច្ច ព្រោះទៅរកពន្លឺត្រាស់ដឹងដែលបរិសុទ្ធ និងដែលមិនចេះប្រែប្រួល។ ដោយហេតុតែទទួលរងនូវវិញ្ញាណមិនបរិសុទ្ធនិងប្រែប្រួល ដោយហេតុតែយល់ច្រឡំតាមដោយគំនិតខុសរបស់ខ្លួន បានជាបុគ្គលវង្វេងវិលវល់ទៅក្នុងលោកដែលប្រកបទៅដោយការថ្លឹនភ្លេកនេះ។

សេចក្ដីខ្វល់ និងសេចក្ដីសៅហ្មងនៃវិញ្ញាណមនុស្សលោកមកអំពីចំណង់លោកលន់ ហើយនិងប្រតិកម្មចំពោះទេស-កាលដែលប្រែប្រួលជានិច្ច។

វិញ្ញាណដែលមិនរឹករវនឹងវត្ថុទាំងឡាយ ដែលកើតមានឡើងចំពោះមុខ វិញ្ញាណដែលនៅបរិសុទ្ធ និងស្ងប់ចំពោះគ្រប់ទេសកាល គឺវិញ្ញាណនោះហើយដែលពិត ដែលជាម្ចាស់។

គេមិនអាចនិយាយថា ភោជនីយដ្ឋានបាត់រូបទៅដោយសារតែលែងមានអ្នកដំណើរ នោះបានទេ។ ដូចគ្នានេះ គេមិន

អាចថា អាត្មันពិតប្រាកដ បាត់រូបទៅដោយសារតែវិញ្ញាណប្រឡាក់ជាប់ដោយមន្ទិល ដែលកើតឡើងអំពីទេសៈកាលៈប្រែប្រួលនៃជីវិត វិនាសបាត់ទៅនោះបានទេ។ វិញ្ញាណមនុស្សលោក ដែលប្រែប្រួលទៅតាមដំណើរប្រែប្រួលនៃទេសកាល មិនមែនជាសភាពពិតប្រាកដនៃវិញ្ញាណមែនទែនទេ។

5. បើយើងគិតទៅដល់រោងជំនុំមួយ ដែលភ្លឺព្រោងព្រាតឡើងនៅពេលព្រះអាទិត្យរះ ហើយងងឹតទៅវិញនៅពេលព្រះអាទិត្យលិចបាត់ទៅ។

យើងអាចគិតឃើញថា ពន្លឺដើរតាមព្រះអាទិត្យ ហើយភាពងងឹតមកតាមរាត្រីកាល តែយើងមិនអាចថា កម្លាំងដែលបណ្តាលឲ្យយល់នូវភាពភ្លឺ និងភាពងងឹតនោះ វាដើរទៅតាមអ្វី ឬវិលត្រឡប់ទៅកាន់កន្លែងណាមួយនោះបានទេ។ ញាណសតិ ឬកម្លាំងសតិអារម្មណ៍ ដែលនាំឲ្យយល់នូវភាពភ្លឺ និងភាពងងឹតនេះ មិនត្រឡប់ទៅទីណាក្រៅពីស្ថិតនៅក្នុងសភាពពិតរបស់វា គឺសភាពជាគ្រឹះសំខាន់នៃវិញ្ញាណនោះទេ។

ការសម្គាល់ឃើញថា ពេលថ្ងៃកាលណាព្រះអាទិត្យរះ

ឡើង ហើយនិងពេលយប់កាលណាព្រះអាទិត្យលិចបាត់ទៅ នេះជាការកត់សម្គាល់ក្នុងរយៈពេលនៃវិញ្ញាណ ជាបណ្ដោះអាសន្នតែប៉ុណ្ណោះ។

គឺស្ថានភាពវិញ្ញាណជាបណ្ដោះអាសន្ននេះហើយ ដែលផ្លាស់ប្ដូរប្រែប្រួលពីពេលមួយទៅមួយ តាមទេសៈកាលៈជីវិត នេះមិនមែនជាវិញ្ញាណពិតប្រាកដទេ។ វិញ្ញាណដែលជាគ្រឹះនិងពិតប្រាកដនោះ គឺជាវិញ្ញាណដែលយល់ជាក់នូវភាពភ្លឺនិងភាពងងឹត នេះហើយជាសភាពពិតនៃវិញ្ញាណ។

ការមានអារម្មណ៍ក្នុងមួយរយៈពេល ទៅលើភាពល្អនិងភាពអាក្រក់ ទៅលើការស្រឡាញ់និងការស្អប់ ដែលកើតមានឡើង និងវិនាសទៅវិញ ដោយសារហេតុផ្សេងៗជាខាងក្រៅនោះ គ្រាន់តែជាប្រតិកម្មក្នុងមួយរយៈពេល ដែលកើតមានឡើងអំពីវិញ្ញាណមនុស្សលោក ដែលប្រឡាក់ជាប់នូវល្អងធូលីនិងមន្ទិលផ្សេងៗ។

សភាពពិតរបស់វិញ្ញាណ វាបរិសុទ្ធតាំងអំពីដើមកំណើតមក។ ថ្វីបើវាត្រូវបានពាសព័ទ្ធទៅដោយធូលីនៃតណ្ហាលោកិយ សភាពពិតជាសារខ្លឹមរបស់វិញ្ញាណនោះគ្មានមន្ទិលអ្វីទេ។

បើគេដាក់ទឹកក្នុងផើងមានរាងមូល ទឹកនោះក៏ឡើងជាមូល។ បើគេដាក់ទឹកក្នុងផើងមានរាងបួនជ្រុង ទឹកនោះនឹងទៅជារាងបួនជ្រុង។ តាមពិត ទឹកមិនមានរាងមូល ឬរាងបួនជ្រុងទេ តែមនុស្សលោកភ្លេចគិតថា ទឹកឥតរាងរៅ ក៏បណ្ដោយឲ្យសតិយល់ប្រទូំទៅលើរាងរៅទឹកក្នុងផើងនោះ។

មនុស្សយល់ឃើញថា នេះល្អនោះអាក្រក់ នឹកគិតស្រឡាញ់នេះហើយស្អប់នោះ ធ្វើការវែកញែកអំពីរឿងពិតមាននៅ និងគ្មានពិតនៅ។ ដោយសារហេតុនេះ មនុស្សលោកជាប់ជំពាក់ចិត្ត នឹងសភាពជាខាងក្រៅ ហើយក៏ត្រូវតែទទួលទុក្ខដោយសារសភាពជាខាងក្រៅទាំងនេះ។

បើសិនជាមនុស្សលោកអាចរំដោះខ្លួនឲ្យផុតពីការជំពាក់ចិត្តទៅលើសភាពជាខាងក្រៅទាំងនេះបាន ហើយអាចរកឃើញវិញនូវភាពបរិសុទ្ធនៃវិញ្ញាណដើមរបស់ខ្លួន រូបកាយព្រមទាំងវិញ្ញាណនៃមនុស្សលោកទាំងនោះ នឹងបានចាកផុតអំពីមន្ទិលសៅហ្មង និងទុក្ខព្រួយ ហើយនឹងបានស្គាល់តែសេចក្ដីសុខស្ងប់ជាទីបំផុត។

II

# សភាពព្រះពុទ្ធ

1. វិញ្ញាណបរិសុទ្ធនិងពិតប្រាកដ ដែលយើងបានដាក់នាមថា វិញ្ញាណជាគ្រឹះ នោះហើយជាសភាពព្រះពុទ្ធ ជាគ្រាប់ពូជពុទ្ធសភាវៈ។

គេអាចបង្កើតភ្លើងបាន ដោយយកកែវហើមបញ្ចាំងរស្មីព្រះអាទិត្យទៅលើប៉ុយ តែភ្លើងនោះវាមកពីណា ? កែវហើមនៅឆ្ងាយក្រៃលែងពីព្រះអាទិត្យ តែប៉ុយអាចឆេះឡើងបានដោយសារកែវហើមនោះ។ ប៉ុន្តែបើប៉ុយនោះមិនមានភាពងាយឆេះទេ ប៉ុយនោះក៏មិនអាចនឹងឆេះបានដែរ។

ដូចគ្នានេះ ពន្លឺពុទ្ធញ្ញាណចាំងផ្តុំទៅលើចិត្តបុគ្គល ហើយសភាពពិតនៃបុគ្គលនោះ ដែលជាពុទ្ធសភាវៈ នឹងមានពន្លឺចែងចាំងឡើង។ យ៉ាងនេះហើយ ដែលពន្លឺនោះចែងចាំងនៅក្នុងចិត្តសត្វលោក ហើយដាស់តឿនសត្វលោកទាំងនោះឲ្យមានជំនឿទៅលើព្រះពុទ្ធ។ ព្រះពុទ្ធកាន់កែវព្រហ្មចារិភាពបញ្ចាំងទៅគ្រប់នរជន ដូច្នេះ ជំនឿទុកចិត្តនៃគ្រប់នរជននឹងអាចភ្លឺរន្ទាលឡើងបាន។

2. មនុស្សលោកធ្វេសប្រហែសនឹងពុទ្ធញ្ញាណ ដែលជាសភាពពិតប្រាកដរបស់ខ្លួន បានជាមនុស្សលោកធ្លាក់ទៅក្នុងមណ្ឌលជាទីទុក្ខ ដោយសារតែត្រូវបានចងជាប់នឹងភាពល្អនិងភាពអាក្រក់ ដែលជាសម្បកក្រៅ ហើយត្រូវបានគ្របដណ្តប់ជិតជុំទៅដោយធូលីតណ្ហា។

ចុះហេតុដូចម្តេចបានជាមនុស្សលោក ដែលមានវិញ្ញាណជាសារៈខ្ទឹមនិងពិតប្រាកដយ៉ាងនេះហើយ នៅតែប្រតោងយិតយោងជាប់ជានិច្ចនឹងការមិលឃើញខុស ហើយធ្វើទុក្ខទោសខ្លួនឯង ដោយបណ្តោយខ្លួនឲ្យវង្វេងនៅក្នុងលោកដែលពោរពេញទៅដោយការថ្លើនភ្នែក និងក្តីទុក្ខ ទុកណាជានៅជិតខ្លួននោះមានពន្លឺព្រះពុទ្ធញ្ញាណក៏ដោយយ៉ាងនេះ?

កាលមួយនោះ មានបុរសម្នាក់ឆ្លុះពីខាងក្រោយកញ្ចក់ ហើយពុំបានឃើញក្បាលនិងមុខរបស់ខ្លួន ក៏ទៅជាឆ្កួតលេលា។ តើវាចាំបាច់ត្រូវតែបុរសម្នាក់នោះទៅជាឆ្កួតលេលា ដោយសារតែឆ្លុះកញ្ចក់ខុសទំនងតែប៉ុណ្ណោះដែរឬទេ?។

គឺពិតជាភ្លើ និងជាការឥតអំពើ ចំពោះបុគ្គលណាដែលកើតទុក្ខ នឹងការពុំបានទទួលពន្លឺការត្រាស់ញ្ញាណ ដែលខ្លួន

សង្ឃឹមថានឹងបានសម្រេច។ កំហុសមិននៅលើពន្លឺញាណដឹង នោះទេ។ កំហុសវានៅត្រង់បុគ្គលទាំងឡាយតាំងពីយូរយារមក ហើយ បានខំស្វះស្វែងរកពន្លឺត្រាស់ដឹងនោះ តាមដោយគំនិត ប្រកាន់ការវែកញែក ដោយពុំបានគិតយល់ថា ការនេះវាពុំមែន ជាវិញ្ញាណពិតប្រាកដនោះទេ គ្រាន់តែជាវិញ្ញាណថ្លឹងថ្លែងដែល កើតឡើងដោយការប្រមូលផ្តុំចំណង់លោភលន់និងការសង្ឃឹម មិនសមហេតុផលទៅលើវិញ្ញាណពិតប្រាកដតែប៉ុណ្ណោះ។

បើគំនិតយល់ខុសដែលគរឡើងជាគំនរនោះ វិនាសអស់ ទៅ ពន្លឺត្រាស់ដឹងនឹងចេញប្រាកដឡើង។ ប៉ុន្តែជាការចម្លែក មួយ កាលណាសត្វលោកបានដល់នូវពន្លឺត្រាស់ដឹងនោះ ហើយទើបបានដឹងថា បើអត់គំនិតយល់ខុសទាំងនោះទេ ពន្លឺ ត្រាស់ដឹងក៏នឹងគ្មានដែរ។

3. ពុទ្ធសភាវៈ មិនចេះវិនាសបាត់បង់ទេ។ ទោះបីមនុស្ស ឃោរឃៅទៅកើតជាសត្វធាតុ ជាអសុរកាយអត់ឃ្លាន ឬជា ប្រេតនរកក៏ដោយ បាបជនទាំងនោះមិនបាត់បង់ពុទ្ធសភាវៈ នេះទេ។

ទោះបីជាកប់បាត់ទៅក្នុងភក់ជ្រាំកាមគុណ ឬកប់បាត់ទៅក្នុងឫសគល់តណ្ហាលោកិយ ឬត្រូវបានបំភ្លេចចោលក៏ដោយ សមត្ថភាពមនុស្សដែលអាចនឹងទៅជាព្រះពុទ្ធនោះមិនបាត់អស់រលីងឆេងទេ។

4. មានរឿងនិទានថា បុរសម្នាក់ដេកលក់យ៉ាងស្កប់ស្កល់។ មិត្តរបស់គាត់ម្នាក់ ស៊ូទ្រាំនៅដេកប្រុបក្បែរគាត់ រហូតដល់ពេលត្រូវតែចេញទៅចោលគាត់ដោយខានពុំបាន។ នៅពេលនោះ ដោយខ្លាចមិត្តរបស់ខ្លួនមានសេចក្តីត្រូវការជាចាំបាច់ គាត់ក៏លាក់ត្បូងរ័តន៍មួយគ្រាប់ក្នុងជាយសំពត់បុរសដេកលក់នោះ។ នៅពេលបុរសនោះភ្ញាក់ឡើង ហើយពុំបានដឹងថាមិត្តរបស់ខ្លួនលាក់ត្បូងរ័តន៍មួយគ្រាប់ក្នុងជាយសំពត់នោះ បុរសនោះរស់នៅក្នុងជីវភាពអនាថាក្ររហេមរហាម។ យូរក្រោយមកបុរសទាំងពីររូបនោះក៏បានជួបគ្នាវិញ។ បុរសជាមិត្តក៏ប្រាប់បុរសកំសត់នោះ អំពីរឿងត្បូងរ័តន៍ដែលបានលាក់ទុកឲ្យនោះ ហើយប្រែប្រាប់ឲ្យទៅតាមរកត្បូងនោះ។

ដូចជាបុរសដេកលក់ក្នុងរឿងនេះដែរ មនុស្សលោក

វង្វេងវង្វាន់នៅកណ្ដាលទីទុក្ខនៃការវិលកើតវិលស្លាប់ ឬវដ្ដ-ទុក្ខដោយពុំបានដឹងថា នៅក្នុងជម្រៅរបស់ខ្លួនផ្ទាល់ ដែលជាសភាពពិតបរិសុទ្ធ គ្មានមន្ទិលរបស់ខ្លួននោះ មានលាក់ទុកនូវត្បូងរ័តន៍ពុទ្ធសភាវៈ ដែលកាត់ថ្លៃពុំបាន។

ទោះបីមនុស្សលោកមិនបានដឹងថា ខ្លួនឯងម្នាក់ៗមានសភាវៈដ៏ប្រសើរបំផុតនេះក៏ដោយ ទោះបីមនុស្សលោកល្ងង់ខ្លៅពុករលួយយ៉ាងណាក៏ដោយ ព្រះពុទ្ធមិនអស់សេចក្ដីទុកចិត្តលើសត្វលោកទាំងនោះម្ដងណាទេ ពីព្រោះព្រះអង្គដឹងជាក់ថា គ្រប់មនុស្សលោកមានគុណសម្បត្តិជាពុទ្ធសភាវៈនេះ។

ហេតុដូច្នេះហើយ ព្រះពុទ្ធទ្រង់មានភក្ដីភាពដល់ជនទាំងឡាយដែលវង្វេងដោយសារសេចក្ដីល្ងង់ខ្លៅ ហើយមិនអាចនឹងមើលឃើញពុទ្ធសភាវៈរបស់ខ្លួនឯង។ ព្រះអង្គទ្រង់កម្ចាត់សេចក្ដីភាន់សតិឲ្យចេញឆ្ងាយអំពីជនទាំងនោះ ហើយទូន្មាននរជនទាំងនោះថា ជាដើមកំណើតឡើង វាគ្មានភាពខុសគ្នារវាងនរជនទាំងនោះនឹងព្រះពុទ្ធទេ។

5. ព្រះពុទ្ធជាសត្វលោកមួយរូបដែលបានសម្រេចពុទ្ធញ្ញាណ

សត្វលោកជម្ពូ គឺជនដែលមានសមត្ថភាពអាចសម្រេចនូវពុទ្ធញាណ។ ភាពខុសគ្នាមានតែប៉ុណ្ណេះឯង។

ក៏ប៉ុន្តែ បើជនណានឹកស្មានថា ខ្លួនបានទៅដល់ពន្លឺត្រាស់ដឹង ជននោះយល់ច្រឡំហើយ ពីព្រោះថា ទុកណាជាជនរូបនោះតម្រង់ឆ្ពោះទៅរកពន្លឺត្រាស់ដឹងនោះក៏ដោយ ជនរូបនោះពុំទាន់បានសម្រេចជាព្រះពុទ្ធនៅឡើយទេ។

សភាពព្រះពុទ្ធមិនលេចឡើងទេ បើគ្មានការខិតខំប្រឹងប្រែងយ៉ាងស្វាហាប់ និងប្រកបដោយជំនឿស្មោះ។ កិច្ចប្រតិបត្តិនេះមិនចេះចប់ទេ ដរាបណាពុទ្ធញាណមិនទាន់លេចធ្លោឡើងនោះ។

6. មានកាលមួយនោះ ព្រះមហាក្សត្រមួយព្រះអង្គបានប្រជុំមនុស្សខ្វាក់ ឲ្យនៅជុំវិញដំរីសារមួយ។ ព្រះមហាក្សត្រសួរជនខ្វាក់ទាំងនោះថា ដំរីសារដូចជាអ្វីដែរ។ ជនខ្វាក់ទី១ដែលស្ទាបត្រូវភ្លុក ឆ្លើយថា ដំរីដូចជាមើមការ៉ុតធំមួយ។ ជនខ្វាក់ទី២ដែលស្ទាបត្រូវត្រចៀក ឆ្លើយថា ដំរីដូចជាផ្ចិតធំមួយ។ ជនខ្វាក់ទី៣ ដែលស្ទាបត្រូវប្រមោយ ឆ្លើយថា ដំរីដូចជាអង្រែ

ធំមួយ។ ជនខ្វាក់ទី២ ស្ទាបត្រូវជើង ឆ្លើយឡើងថា ដំរីដូចជា កាំភ្លើងត្បាល់។ ជនខ្វាក់ទី៥ ជាជនចុងក្រោយគេ ស្ទាបត្រូវកន្ទុយក៏ឆ្លើយថា ដំរីដូចជាខ្សែព្ួរធំមួយ។ គ្មានជនខ្វាក់ណាម្នាក់អាចទូលបញ្ជាក់ប្រាប់ព្រះមហាក្សត្រ អំពីរូបរាងពិតនៃដំរីសារនោះបានទេ។

ដូចគ្នានេះ គេអាចពិពណ៌នាអំពីធម្មជាតិមនុស្ស បានក្នុងភាគខ្លះៗ តែគ្មានជនណាម្នាក់អាចពិពណ៌នា អំពីសភាពពិតរបស់មនុស្ស ដែលជាពុទ្ធសភាវៈនោះបានទេ។

មានតែផ្លូវមួយគត់ ដែលអាចនាំឲ្យស្គាល់ភាពពិតប្រាកដរបស់មនុស្ស ដែលជាពុទ្ធសភាវៈ ដែលតណ្ហាពុំអាចរំខានបាន និងដែលការស្លាប់ពុំអាចបំផ្លាញបាន គឺតួអង្គព្រះពុទ្ធ ហើយនិងសេចក្តីប្រៀនប្រដៅដ៏ប្រសើរឧត្តមរបស់ព្រះអង្គ។

III

# ភាពព្រះពុទ្ធ និងភាពជាអនត្តា

1. ដូចបាននិយាយមកហើយ សភាពព្រះពុទ្ធមិនអាចពិពណ៌នារៀបរាប់បានទេ។ ថ្វីបើហាក់ដូចជាមានសភាពដូចគ្នានឹង

ព្រលឹងនៃលទ្ធិសាសនាឯទៀតៗ ក៏ដោយ តែជាការមិនដូចគ្នាសោះតែម្តង។

ការជឿជាក់ទៅលើអត្តភាព ឬភាពជាអាត្មាអញ គឺជាការប្រឌិតឡើងនៃគំនិតវែកញែក ដែលជាដំបូងប្រកាន់យកភាពនោះ ហើយជាប់ចិត្តនិងភាពនោះ តែត្រូវតែលះបង់ភាពនោះទីបំផុត។ ផ្ទុយទៅវិញ សភាពព្រះពុទ្ធ ជាវត្ថុមិនអាចពិពណ៌នាបាន ដែលត្រូវតែរកឲ្យឃើញជាបឋម។ ក្នុងន័យមួយសភាពព្រះពុទ្ធប្រដូចបានទៅនឹងន័យថា អត្តភាព តែមិនមានន័យដូចគ្នានឹង «អាត្មាអញ» ឬ«របស់អញ»ទេ។

ការគិតថា មានអាត្មាអញជាឋិតថេរ ជាជំនឿភាន់ច្រឡំ ពីព្រោះយល់ស្មានថា មានឋិតនៅចំពោះវត្ថុដែលគ្មានឋិតនៅ។ ផ្ទុយទៅវិញ ការបដិសេធថា គ្មានសភាពព្រះពុទ្ធ ជាការយល់ខុស ពីព្រោះយល់ទៅលើវត្ថុ ដែលមានឋិតនៅថាគ្មានឋិតនៅទៅវិញ។

មានរឿងនិទានប្រៀបធៀបមួយថា មានមាតាម្នាក់ បីកូនឈឺទៅផ្ទះលោកគ្រូពេទ្យម្នាក់។ លោកគ្រូពេទ្យបានឲ្យថ្នាំកូននោះផឹក ហើយបញ្ជាម្តាយនោះថាកុំឲ្យកូនបៅដោះ ដរាប

ណាថ្នាំមិនទាន់រលាយចូលសព្វ។

ម្តាយក៏យកជាតិល្វីងម្យ៉ាងលាបដោះ ដើម្បីឲ្យកូនចៀសចេញពីដោះនោះ។ នៅពេលថ្នាំរលាយសព្វហើយ ម្តាយក៏លាងដោះឲ្យស្អាតហើយបំបៅដោះកូននោះទៅ។ ម្តាយធ្វើយ៉ាងនេះ គឺដោយសារតែមានសេចក្តីស្នេហាចំពោះបុត្ររបស់ខ្លួនតែប៉ុណ្ណោះ។

ដូចគ្នានេះ ព្រះពុទ្ធ ដោយមានបំណងកម្ចាត់ការកាន់ប្រទាំឲ្យអស់ពីក្នុងខ្លួនយើង ហើយបំបាត់ចោលនូវការជំពាក់ចិត្តទៅលើសភាពជាអាត្មាអញ ព្រះអង្គចាប់ផ្តើមឡើងដោយបដិសេធចោលនូវអត្តភាព ឬភាពជាអាត្មាអញ។ កាលណាការយល់ប្រទាំ និងការជំពាក់ចិត្តរបស់យើងវិនាសទៅអស់ហើយ ព្រះអង្គបង្ហាញប្រាប់យើងអំពីសភាពពិតប្រាកដរបស់យើង ពោលគឺ សភាពព្រះពុទ្ធ នោះឯង។

ការជំពាក់ចិត្តលើអាត្មាអញ នាំឆ្ពោះទៅកាន់ការកាន់ប្រទាំ ប៉ុន្តែការជឿចំពោះសភាពព្រះពុទ្ធ នឹងបានដល់នូវពន្លឺត្រាស់ដឹង។

ដូចជាស្ត្រីម្នាក់ ដែលបានទទួលហិបមួយជាកេរមរតក។

ដោយមិនបានដឹងថានៅក្នុងហិបនោះមានមាស ស្ត្រីនោះរស់នៅក្រហេមរហាម រហូតដល់មានជនម្នាក់បើកហិបនោះឡើងហើយបង្ហាញមាសទៅគាត់។ ព្រះពុទ្ធក៏យ៉ាងនោះដែរ ព្រះអង្គបើកចិត្តសត្វលោក ហើយបង្ហាញប្រាប់នូវសភាពព្រះពុទ្ធដែលមាននៅក្នុងខ្លួននៃសត្វលោកទាំងនោះ។

2. បើបុគ្គលគ្រប់រូបមានសភាពព្រះពុទ្ធ ចុះហេតុម្តេចក៏បុគ្គលទាំងនោះបោកបញ្ឆោតប្រវ័ញ្ចគ្នា ប្រព្រឹត្តអំពើអាក្រក់ឃោរឃៅកាប់សម្លាប់គ្នា បណ្តាលឲ្យមានទុក្ខព្រួយច្រើនរាប់មិនអស់យ៉ាងនេះ? ហើយចុះហេតុម្តេចក៏មនុស្សលោកមានភាពខុសគ្នាច្រើនម៉្លេះ តួយ៉ាងដូចជាអ្នកខ្លះមានទ្រព្យស្តុកស្តម្ភ អ្នកខ្លះក្រហេមរហាម ?

មានរឿងនិទានមួយថា មានអ្នកលេងចំបាប់ម្នាក់ មានទម្លាប់លំអថ្ងាសខ្លួននឹងត្បូងពេជ្រមួយគ្រាប់។ ថ្ងៃមួយនោះក្នុងពេលដែលគាត់កំពុងតែប្រយុទ្ធ ត្បូងពេជ្រក៏លិចចូលទៅក្នុងសាច់បាត់ទៅ។ គាត់ស្មានថាជ្រុះបាត់ត្បូងនោះ ហើយទៅរកលោកគ្រូពេទ្យវះកាត់ម្នាក់ឲ្យព្យាបាលមុខរបួស។ លោកគ្រូ

ពេទ្យវះកាត់បានឃើញត្បូងពេជ្រនៅក្នុងសាច់ លិចកប់ទៅក្នុងឈាមនិងវត្ថុអសោច។ លោកគ្រូពេទ្យយកកញ្ចក់មកឆ្លុះ បង្ហាញអ្នកលេងចំបាប់ក៏បានយល់ត្បូងពេជ្រជាលំដាប់នោះទៅ។

សភាពព្រះពុទ្ធដូចជាត្បូងពេជ្រនោះឯង សភាពព្រះពុទ្ធនោះ ត្រូវបានកប់បាត់ទៅក្នុងសំរាមធូលីកខ្វក់នៃការមិលយល់ខុស ហើយម្នាក់ៗនឹកស្មានតែបាត់ទៅហើយ តែព្រះបរមគ្រូបានរកឃើញវិញយកមកឲ្យសត្វលោក។

សភាពព្រះពុទ្ធមាននៅក្នុងបុគ្គលរាល់រូប ទោះបីសភាពព្រះពុទ្ធនេះ ត្រូវបានកប់បាត់ទៅក្នុងជម្រៅសែនជ្រៅនៃអភិជ្ឈា ឬចំណង់លោភលន់ សេចក្ដីក្រោធខឹង និងសេចក្ដីឆ្កួតល្ងីល្ងើ ហើយជាបន្ថែមទៅទៀត ត្រូវបានចងជាប់និងកម្មផល។ ទោះបីយ៉ាងនេះក៏ដោយ ក៏សភាពព្រះពុទ្ធមិនវិនាសបាត់ទៅឯណាឡើយ។ បើគេបំបាត់ចោលឲ្យអស់នូវវត្ថុមិនបរិសុទ្ធទាំងឡាយបាន យូរនិងឆាប់គង់តែសភាពព្រះពុទ្ធនេះនឹងចេញឲ្យឃើញឡើងវិញទេ។

ដូចជាអ្នកលេងចំបាប់នៅក្នុងរឿងនិទានប្រៀបធៀបនេះ ដែលរកឃើញវិញនូវត្បូងពេជ្រ ដែលកប់បាត់ទៅក្នុងសាច់

និងឈាមដោយសារកញ្ចក់ សត្វលោករកសភាពព្រះពុទ្ធរបស់ខ្លួនដែលកប់បាត់ទៅក្នុងចំណង់លោភលន់ និងតណ្ហាឃើញវិញ ដោយសារពន្លឺត្រាស់ញាណរបស់ព្រះពុទ្ធ។

3. សភាពរបស់ព្រះ បរិសុទ្ធនិងស្ងប់ជានិច្ច ទោះបីសត្វលោកត្រូវបានលាយឡំច្របូកច្របល់នឹងទេសកាលដ៏ច្រើនរាប់មិនអស់យ៉ាងនេះក៏ដោយ។ ដូចជាទឹកដោះដែលមានពណ៌សស្គុសជានិច្ច ទោះបីគោនោះមានពណ៌ទង់ដែង ស ឬខ្មៅក៏ដោយ។ ដូចនេះហើយ សភាពព្រះពុទ្ធបរិសុទ្ធជានិច្ច ទោះបីលក្ខណៈរបស់សត្វលោក អំពើនិងផលរបស់សត្វលោក វាយ៉ាងណាក៏ដោយ។

មានរឿងមួយនិទានថា នៅក្នុងព្រៃភ្នំហិមពាន្តមានរុក្ខ-ជាតិថ្នាំពិសេសម្យ៉ាងដុះនៅកណ្ដាលល្បាស់ស្មៅខ្ពស់ៗ។ គេបានស្វែងរករុក្ខជាតិថ្នាំនោះជាយូរមកហើយ តែពុំបានជួបប្រទះសោះ។ ថ្ងៃមួយ តាបសឥសីមួយអង្គបានរកឃើញដោយសារក្លិនក្រអូបផ្សព្វផ្សាយចេញពីរុក្ខជាតិនោះ។ តាបសឥសីបានយករុក្ខជាតិនោះទៅរក្សាទុកក្នុងផើងធំមួយ។ តែដល់តាបសឥសីនោះសុគតទៅ រុក្ខជាតិថ្នាំពិសេសនោះក៏កប់បាត់

កណ្ដាលព្រៃភ្នំ នៅក្នុងផើង ដែលមានទឹកឡើងស្អុយជូរមាន
ក្លិនអាក្រក់ក្រៃពេក។

ដូចក្នុងរឿងនិទាននេះដែរ សភាពព្រះពុទ្ធកប់បាត់ក្នុង
ល្បះស្មៅតណ្ហាសែនខ្ពស់ ដែលមនុស្សធម្មតាពិបាករកឃើញ
ណាស់។ ព្រះពុទ្ធជាម្ចាស់ ព្រះអង្គបានកាប់ត្រាយល្បាស់ស្មៅ
តណ្ហាហើយដកយកសភាពព្រះពុទ្ធ ដែលមានរសជាតិផ្អែម
ស្រទន់អំពីកំណើតនោះ ចេញមកបង្ហាញសត្វលោក។ តែ
សភាពព្រះពុទ្ធដែលមានរសជាតិផ្អែមស្រទន់តែមួយគត់នោះ
ត្រូវបានផ្លាស់ប្ដូររសជាតិក្លិនផ្សេងៗ ទៅតាមចំណូលចិត្ត និង
សមត្ថភាពរបស់បុគ្គលម្នាក់ៗ ដែលទទួលយក។

4. សភាពព្រះពុទ្ធដូចជាត្បូងពេជ្រ រឹងហើយមិនចេះរលួយ
ពុកទេ។ ខ្សាច់ និងថ្មធម្មតា អាចផ្ទុះខ្ទេចខ្ទីទៅជាផង់ធូលីបាន
ចំណែកពេជ្រ នៅជាប់ជានិច្ច។

រូបនិងវិញ្ញាណអាចវិនាសបាត់បង់ តែសភាពព្រះពុទ្ធមិន
បាត់បង់ទេ។

សភាពព្រះពុទ្ធជាវត្ថុឧត្តមបំផុត ដែលមាននៅក្នុងមនុស្ស

ជាតិ។ គេទម្លាប់គិតថា ស្ត្រីទាបជាងបុរស តែតាមសាសនាព្រះពុទ្ធ មិនដូច្នោះទេ។ ជាសំខាន់គឺនៅត្រង់យល់និងស្គាល់សភាពព្រះពុទ្ធនោះឯង។

ដើម្បីបានមាសសុទ្ធ ត្រូវតែដុតរំលាយលោហធាតុ ដើមហើយចម្រាញ់ត្រង់យកជាតិមិនបរិសុទ្ធចេញ។ ដូចគ្នានេះដែរ កាលណាមនុស្សលោករំលាយតណ្ហានៃចិត្តរបស់ខ្លួន ហើយត្រង់យកវត្ថុមិនបរិសុទ្ធ ដែលនាំឲ្យសៅហ្មងនោះចេញបាន មនុស្សលោកអាចនឹងឃើញសភាពព្រះពុទ្ធ ដែលមាននៅក្នុងខ្លួនឯងផ្ទាល់នោះជាពុំខាន។

# ចំពូកទី ៤

# តណ្ហា

## I

## មន្ទិលសៅហ្មងនៃចិត្ត

1. *មានតណ្ហាពីរយ៉ាង ដែលគ្របពាសជិតជុំលើសភាពព្រះពុទ្ធ។*

*តណ្ហាទី១ គឺការទម្លាប់ធ្វើការវែកញែក ដែលជាហេតុនាំឲ្យមនុស្សវង្វេង។ តណ្ហាទី២ គឺការទាញចិត្តនាំឲ្យរំជួល ដែលជាហេតុនាំឲ្យមនុស្សវង្វេង ដោយឲ្យតម្លៃខុសចំពោះវត្ថុទាំងឡាយ។*

*តណ្ហាជាដើមឫសទាំងពីរនេះ គឺជាដើមហេតុនៃគ្រប់តណ្ហាឯទៀតៗ។ តណ្ហាដើមឫសទាំងពីរនេះ មាននិន្នាការដើមហេតុពីរជាមូលដ្ឋាន គឺសេចក្ដីល្ងង់ខ្លៅ និងចំណង់ចង់ចប់ផល់។*

*ទម្លាប់ធ្វើការវែកញែក មានសេចក្ដីល្ងង់ខ្លៅជាមូលដ្ឋាន*

ហើយការនាំចិត្តឲ្យរំជួល យោលយកចំណង់ផប់ផល់ជាបង្អែ កៗ រួមចូលគ្នាទៅ និន្នាការទាំងពីរនេះបានជាដើមហេតុនៃគ្រប់តណ្ហាឯទៀតៗ។

កាលណាល្ងង់ខ្លៅហើយ គេមិនអាចពិចារណាតាមបែបបទត្រឹមត្រូវប្រាកដបានទេ។ កាលណាបណ្តោយឲ្យធ្លាក់ក្នុងចំណង់ផប់ផល់ហើយ គេខំតោងខំចាប់យក ខំជំពាក់ចិត្តដោយមិនអាចចៀសរួច។ គឺដោយសារតែខំប្រទាញប្រតោងស្រេកឃ្លានរបស់ជាទីស្រឡាញ់ បានជាគេឃើញ ព្ទ ហើយបណ្តាលចិត្តឲ្យរំជួលឡើង។ មានពេលខ្វះ គេរហូតដល់ទៅបណ្តោយឲ្យមានចំណង់ចំពោះសេចក្តីមរណៈផងក៏មាន។

តណ្ហាទាំងនេះហើយ ជាដើមហេតុនៃតណ្ហាឯទៀតទាំងអស់ ដូចជា សេចក្តីលោភលន់ សេចក្តីក្រោធខឹង សេចក្តីល្ងីល្ងើ ការយល់ខុស ការតូចចិត្ត ការច្រណែននិន្ទា ការបញ្ចើចបញ្ចើ ការបោកប្រាស សេចក្តីឡឺត ការមើលងាយមើលថោក ការប្រព្រឹត្តហួសហេតុ ការមានអត្តទត្តភាព។

2. សេចក្តីលោភលន់ មកអំពីគំនិតខុសដែលមានចំពោះវត្ថុ

ជាទីពេញចិត្ត ហើយប្រាថ្នាចាប់យកវត្ថុនោះ។ សេចក្តីក្រោធខឹង មកអំពីគំនិតខុស ក្នុងការមិនអាចព្រមទទួលយកនូវស្ថានភាព ឬព្រឹត្តិការណ៍ ដែលមិនជាទីពេញចិត្ត។ សេចក្តីល្ងីល្ងើមកអំពីការមិនចេះកាន់មារយាទឲ្យបានត្រឹមត្រូវ។ ការយល់ខុសមកអំពីគំនិតខុស ដែលចេញមកអំពីសិក្ខាបទអាក្រក់។

សេចក្តីលោភលន់ សេចក្តីក្រោធខឹង និងសេចក្តីល្ងីល្ងើគឺជាភ្លើងទាំងបី ដែលឆេះលោកនេះ។ ភ្លើងនៃសេចក្តីលោភលន់ ឆេះបុគ្គលណាដែលបាត់បង់ការយល់ត្រូវ ដោយហេតុតែសេចក្តីលោភលន់។ ភ្លើងនៃសេចក្តីក្រោធខឹង ឆេះបុគ្គលណាដែលបាត់បង់ការយល់ត្រូវ ដោយហេតុតែក្តីក្រោធ។ ភ្លើងនៃសេចក្តីល្ងីល្ងើ ឆេះបុគ្គលណាដែលបាត់បង់ការយល់ត្រូវ ដោយហេតុតែមិនព្រមយកត្រចៀកស្តាប់ យកចិត្តទុកដាក់នឹងសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់។

តាមពិត លោកនេះត្រូវឆេះដោយអណ្តាតភ្លើង ជាច្រើនចំពូក។ មានអណ្តាតភ្លើងនៃក្តីលោភលន់ អណ្តាតភ្លើងនៃក្តីក្រោធខឹង អណ្តាតភ្លើងនៃការយល់ខុស អណ្តាភ្លើងនៃអត្ត-ទត្តភាព អណ្តាតភ្លើងនៃក្តីល្ងីល្ងើ អណ្តាតភ្លើងនៃជរាភាព

អណ្តាតភ្លើងនៃជំងឺ និងអណ្តាតភ្លើងនៃមរណភាព។ មានអណ្តាតភ្លើងនៃក្តីទុក្ខព្រួយ អណ្តាតភ្លើងនៃក្តីសោកសង្រេង អណ្តាតភ្លើងនៃក្តីវេទនា និងអណ្តាតភ្លើងនៃក្តីថប់បារម្ភ។ អណ្តាតភ្លើងអស់ទាំងនេះ ឆេះសម្បើមណាស់។ វាមិនត្រឹមតែឆេះខ្លួនឯងប៉ុណ្ណោះទេ វាបណ្តាលហេតុដល់អ្នកដទៃទៀតឲ្យមានទុក្ខវេទនា ឲ្យប្រព្រឹត្តអំពើអាក្រក់ដោយគំនិត ដោយវាចា និងដោយរូបកាយ។ របួសដែលបណ្តាលពីអណ្តាតភ្លើងទាំងនេះមានខ្ទុះហូរចេញឆ្លងទៅគេឯង បំពុលអ្នកដែលបានប៉ះពាល់ ហើយនាំអ្នកទាំងនោះឲ្យចូលទៅរកផ្លូវនរក។

3. សេចក្តីលោភលន់ កើតមានឡើងចំពោះអ្វីៗ ដែលគួរជាទីពេញចិត្ត។ សេចក្តីក្រោធខឹង កើតមានឡើងនៅចំពោះអ្វីៗ ដែលមិនជាទីពេញចិត្ត។ សេចក្តីឆ្កួតល្ងីល្ងើ មកអំពីចិត្តគំនិតមិនបរិសុទ្ធ។ សេចក្តីលោភលន់ បណ្តាលឲ្យមានមន្ទិលតូចមួយ តែពិបាកនឹងលុបបំបាត់។ សេចក្តីក្រោធខឹង បណ្តាលឲ្យមានមន្ទិលធំជាងនេះ តែស្រួលលុបបំបាត់ជាង។ ផ្ទុយពីនេះ សេចក្តីឆ្កួតល្ងីល្ងើ បណ្តាលឲ្យមានមន្ទិលធំមួយពិបាកនឹងលុបបំបាត់ណាស់។

ពេលណា ទីណាដែលមានអណ្ដាតភ្លើងទាំងនេះឆេះឡើង ហើយ ត្រូវតែពន្លត់ចោលឲ្យអស់ ដោយចេះវិនិច្ឆ័យឲ្យបាន ត្រឹមត្រូវ អំពីអ្វីៗដែលអាចផ្ដល់នូវសេចក្ដីសោមនស្សពិតប្រាកដ ដោយចេះគ្រប់គ្រងចិត្តរបស់ខ្លួនយ៉ាងប្រិតប្រៀប ចំពោះអ្វីៗ ដែលមិនជាទីពេញចិត្តនៃជីវិត និងដោយរំលឹកជាប់ជានិច្ចនូវ ពុទ្ធោវាទ។ បើចិត្តបានពោរពេញទៅដោយគំនិតបរិសុទ្ធប្រកប ដោយគតិបណ្ឌិត លែងមានអត្តទត្តភាពហើយ តណ្ហាទាំង ឡាយនឹងមិនអាចចាប់ឫសដុះឡើងបានទេ។

4. សេចក្ដីលោភលន់ សេចក្ដីក្រោធខឹង និងសេចក្ដីច្រូតភ្លីភ្លើ ប្រៀបបាននិងជំងឺគ្រុនក្ដៅ។ បើបុគ្គលណាមានជំងឺគ្រុនក្ដៅ នេះហើយ បើទុកជាដេកក្នុងវិមានយ៉ាងប្រណីតយ៉ាងណាក៏ ដោយ ក៏ពុំអាចដេកលក់ស្រួលបានដែរ។

បើគេពុំមានជំងឺគ្រុនក្ដៅនេះទេ គេងាយដេកលក់ស្រួល ទោះបីជានៅនារាត្រីសែនត្រជាក់នៃសិសិររដូវ ដោយដេកផ្ទាល់ នឹងដី ដណ្ដប់តែស្លឹកឈើក៏ដោយ ឬទោះបីជានៅនារាត្រី សែនក្ដៅនៃរដូវក្ដៅ ដោយដេកក្នុងបន្ទប់តូចមួយ ហើយបិទ

ជិតឈឺផងក៏ដោយ។

សេចក្តីលោភលន់ សេចក្តីក្រោធខឹង និងសេចក្តីច្រឡំ ល្ងង់ល្ងើ (ជា) ដើមហេតុបីនៃទុក្ខវេទនារបស់សត្វលោក។ ដើម្បីដកឫសនៃដើមហេតុទុក្ខវេទនាទាំងបីនេះ ត្រូវតែចេះរក្សាសិក្ខាបទ ចេះសង្រួមចិត្ត និងមានគតិបណ្ឌិត។ ដោយសារការរក្សាសិក្ខាបទ គេអាចកំចាត់ភាពមិនបរិសុទ្ធនៃសេចក្តីលោភលន់បាន។ ដោយសារការសង្រួមចិត្ត គេអាចកំចាត់ភាពមិនបរិសុទ្ធនៃសេចក្តីក្រោធខឹងបាន។ ដោយសារការមានគតិបណ្ឌិតគេអាចកំចាត់ភាពមិនបរិសុទ្ធនៃសេចក្តីច្រឡំល្ងង់ល្ងើបាន។

5. ចំណង់មនុស្សលោក គ្មានព្រំដែនទេ។ គឺដូចជាមនុស្សដែលស្រេកទឹក ហើយផឹកទឹកអំបិល។ មនុស្សនោះមិនបាត់ស្រេក ហើយរឹតតែស្រេកឡើងៗថែមទៀត។

បុគ្គលដែលស្វែងរកសេចក្តីពេញចិត្តនឹងចំណង់របស់ខ្លួនក៏ដូច្នេះដែរ។ ចំណង់រឹតតែមានច្រើនឡើងៗហើយបុគ្គលនោះនឹងទទួលក្តីទុក្ខកាន់តែច្រើនឡើងៗ។

ការពេញចិត្តនឹងចំណង់ មិនចេះចប់ជាដាច់ខាត វា

បណ្ដាលនូវសេចក្ដីព្រួយបារម្ភ និងសេចក្ដីក្ដៅក្រហាយ ដែលមិនចេះស្រាកស្រាន្តជាដាច់ខាត ជានិច្ចកាល។ ម្យ៉ាងទៀត បើការពេញចិត្តនឹងចំណង់នោះ វាត្រូវបានគេប្រឆាំងរាំងរា វានឹងនាំឲ្យមនុស្សទៅជាឆ្កួតលេលា ជាញឹកញយ។

ដើម្បីបំពេញចំណង់របស់ខ្លួន មនុស្សលោកប្រយុទ្ធប្រកាប់ប្រចាក់គ្នា ស្ដេចជាមួយនឹងស្ដេច ប្រទេសចំណុះជាមួយនឹងប្រទេសចំណុះ ឪពុកម្ដាយជាមួយនឹងកូនចៅ បងប្អូនប្រុសស្រីជាមួយនឹងបងប្អូនប្រុសស្រី មិត្តភក្ដិជាមួយនឹងមិត្តភក្ដិ។ ដើម្បីបំពេញចំណង់របស់ខ្លួន មនុស្សលោករហូតដល់ទៅសម្លាប់គ្នាទៀតផង។

ជាញឹកញយ មនុស្សលោករហូតដល់ទៅបំផ្លាញជីវិតរបស់ខ្លួន ដើម្បីបំពេញចំណង់ខ្លួន។ នរជនទាំងនោះ លួចប្លន់កុហកបោកប្រាស់ ប្រព្រឹត្តអំពើផិតក្បត់ ហើយនៅទីបំផុតកាលណាគេចាប់បាន ជនទាំងនោះត្រូវអស់កិត្តិយស ហើយទទួលទណ្ឌកម្មជាទម្ងន់។

មនុស្សលោកធ្វើកម្មពៀរនឹងរូបកាយរបស់ខ្លួន នឹងមាត់របស់ខ្លួន ដោយដឹងច្បាស់ហើយថា ការបំពេញចំណង់របស់ខ្លួនទាំងនោះ បណ្ដាលឲ្យមានទុក្ខទោស។ មនុស្សលោកធ្វើ

កម្មពៀរនឹងវិញ្ញាណរបស់ខ្លួន ដោយដឹងច្បាស់ហើយថា ការបំពេញបំណងចំណង់របស់ខ្លួនទាំងនោះនាំមក ជាទីបំផុតនូវទុក្ខព្រួយ។ តែកម្លាំងនៃចំណង់ វាខ្លាំងក្រៃពេកណាស់ ! ហើយទោសទុក្ខ ដែលនឹងត្រូវបានទទួលទៅជាតិមុខ វាយ៉ាងណាទៅ? កម្មផល ដែលនឹងត្រូវបានរងទៅជាតិនានាខាងមុខ វាយ៉ាងណាទៅ?

6. ក្នុងចំណោមតណ្ហាលោកិយទាំងនោះ អភិជ្ឈា ឬចំណង់ផប់ផល់ធំជាងគេ។ ចំពោះតណ្ហាឯទៀតៗ ហាក់ដូចជាក្បួនដង្ហែតាមក្រោយទេ។

អភិជ្ឈា ដូចជាការសាបព្រោះក្នុងស្រែ ដែលតណ្ហាចំណង់ឯទៀតៗ ដុះចេញឡើង។ អភិជ្ឈា ដូចជាយក្ខិនីនៅក្នុងរឿងព្រេង ដែលហែកស៊ីអំពើល្អទាំងអស់នៃលោកនេះ។ អភិជ្ឈា ដូចជាពស់វែក ដែលលាក់បំពួនខ្លួនក្នុងគុម្ពផ្កាទាំងឡាយនាសួនច្បារ វាចឹកជនទាំងឡាយដែលមកក្រេបយកសោភណភាពនៃសួន។ អភិជ្ឈា ដូចជារុក្ខជាតិចង្រៃ ដែលវាឡើងព័ទ្ធដើមព្រឹក្សា ហើយព័ទ្ធព័ន្ធរួតរឹតគ្រប់មែកធាង រហូត

ដល់ព្រឹក្សានោះសូន្យជីវិត។ មែនទែនទៅ គឺអភិជ្ឈានេះវាចាក់ឫសទៅក្នុងជម្រៅនៃចិត្តមនុស្សលោក ហើយបណ្ដេញចេញអស់នូវសុភវិនិច្ឆ័យ រហូតទាល់តែផ្កានៃវិញ្ញាណរុះរោយអស់។ អភិជ្ឈា ដូចជាអន្ទាក់ ដែលបិសាចដាក់ មនុស្សដែលឆោតភ្លើបណ្ដោយខ្លួនឲ្យជាប់អន្ទាក់នោះ ហើយត្រូវបានប្រអូសប្រទាញឲ្យចូលទៅក្នុងភពនៃទុក្ខវេទនា។

បើគេយកឈាមមកប្រឡាក់ឆ្អឹងស្ងួតក្រោះមួយ ហើយបោះទៅឲ្យឆ្កែ ឆ្កែនឹងអង្កៀមមឆ្អឹងនោះរហូតទាល់តែវាអស់កម្លាំង ឬក៏គេយកឆ្អឹងនោះចេញពីវា។ អភិជ្ឈាក៏ដូចជាឆ្អឹងនោះដែរ មនុស្សលោកជាប់ជំពាក់ចិត្តនឹងវា រហូតទាល់តែស្អប់ស្អល់ ហើយហេវហត់អស់កម្លាំងនឹងវា។

បើគេចោលដុំសាច់គំរង់សត្វទៅឲ្យសត្វសាហាវពីរ មំសាសត្វទាំងពីរនោះនឹងប្រខាំហែកហួរគ្នា ដណ្ដើមយកដុំសាច់គំរង់នោះ។ បើមនុស្សឆ្កួតភ្លីភ្លើកាន់ចន្លុះដែលឆេះទ្រលោម ហើយដើរបញ្ច្រាស់ខ្យល់ មនុស្សនោះនឹងត្រូវឆេះរលាកខ្លួនឯង។ មនុស្សលោក ដូចជាសត្វសាហាវទាំងពីរនេះ ឬដូចជាមនុស្សឆ្កួតភ្លីភ្លើនេះដែរ មនុស្សលោកបណ្ដាលឲ្យមានរបួសលើខ្លួន

ឯង បណ្ដាលឲ្យលោករលួយខ្លួនឯង ដោយសារចំណង់របស់ខ្លួនឯងផ្ទាល់។

7. ការការពារខ្លួននឹងព្រួញពិស ជាការងាយស្រួលធ្វើទេ ប៉ុន្ដែ ការការពារចិត្តនឹងព្រួញពិសដែលចេញមកអំពីក្នុងខ្លួនឯងផ្ទាល់នោះ ជាការមិនអាចធ្វើបាន។ សេចក្ដីលោភលន់ សេចក្ដីក្រោធខឹង សេចក្ដីច្រួតភ្លីភ្លើ សេចក្ដីកាន់ក្អេកនឹងអាត្មាអញ សុទ្ធតែជាព្រួញពិសដែលមានដើមហេតុនៅក្នុងវិញ្ញាណ ហើយដែលចម្លងពិសពុលខ្លាំងបំផុតទៅវិញ្ញាណ។

បើគេត្រូវច្រួងរោគលោភលន់ រោគក្រោធខឹង និងរោគច្រួតភ្លីភ្លើ ទៅក្នុងចិត្តគេហើយ គេចៀសពុំផុតអំពីនិយាយកុហក និយាយត្រឡប់ត្រឡិន និយាយប្រមាថនិយាយបង្កាច់បង្ខូច ហើយប្រព្រឹត្តឃាតកម្ម ចោរកម្ម និងអំពើផិតក្បត់។

គំនិតអាក្រក់ទាំងបី សម្ដីអាក្រក់ទាំងបួន និងអំពើអាក្រក់ទាំងបី រួមផ្ដុំគ្នាឡើងបង្កើតបានជាកម្មអាក្រក់ដប់ប្រការ។

បើគេទម្លាប់កុហក គេនឹងប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាង ដោយមិនដឹងខ្លួន។ មុននឹងប្រព្រឹត្តអំពើឃោរឃៅ គេ

តោងតែកុហក។ កាលណាគេចាប់ផ្ដើមកុហកហើយ គេនឹងប្រព្រឹត្តអំពើឃោរឃៅ ដោយឥតនឹកគិតរអែង។

សេចក្ដីលោភលន់ ចំណង់ហួសប្រមាណ សេចក្ដីខ្ជាចញ្ញើត សេចក្ដីក្រោធខឹង សេចក្ដីទោមនស្ស ការមិនពេញចិត្តទាំងអស់នេះមកអំពីសេចក្ដីឆ្កួតក្ងីក្ងើ។ ហេតុនេះ សេចក្ដីឆ្កួតក្ងីក្ងើ ជាពិសពុលខ្លាំងជាងគេបង្អស់។

8. កាលណាចំណង់លោកិយប្រាកដឡើងហើយ អំពើផ្សេងៗនឹងមកតាមចំណង់នោះ។ កាលណាអំពើប្រាកដឡើងហើយទុក្ខវេទនានឹងមកតាមអំពើនោះ។ ចំណង់ អំពើ និងទុក្ខវេទនាដូចជាកង់ដែលវិលមិនឈប់។

បើកង់វិលគ្មានទីផ្ដើម និងទីបញ្ចប់យ៉ាងនេះ តើគេអាចចៀសផុតពីការវិលរស់វិលស្លាប់យ៉ាងដូចម្ដេចទៅ? ដូច្នេះ ជីវិតគឺជាការវិលទៅវិលមកជានិច្ចនិរន្តរ៍។

បើគេប្រមូលគរផេះនិងឆ្អឹង ដែលគេទុកចោលក្នុងរយៈវេលាវិលរស់វិលស្លាប់មិនចេះចប់នេះ គេនឹងបានជាភ្នំធំមួយ។ បើគេប្រមូលទុកដំណក់ទឹកដោះទាំងអស់ ដែលគេបៅជញ្ជក់

ពីដោះមាតា ក្នុងរយៈពេលវិលរស់វិលស្លាប់មិនចេះចប់នេះដែរ គេនឹងបានជាមហាសមុទ្រយ៉ាងជ្រៅបំផុតមួយ។

ប៉ុន្តែដ្បិតតែបុគ្គលគ្រប់រូបមានសភាពព្រះពុទ្ធនៅក្នុងខ្លួនតែសភាពព្រះពុទ្ធនោះ ត្រូវបានកប់បាត់យ៉ាងជ្រៅទៅក្នុងមន្ទិលសៅហ្មងនៃតណ្ហា ដែលគ្មាននរណាម្នាក់នឹកគិតដល់តាំងពីយូររាប់កោដិឆ្នាំមកហើយ។ ហេតុនេះហើយបានជាទុក្ខវេទនាវាទៅជាសាកលទូទៅយ៉ាងនេះ ហើយជីវិតរងទុក្ខវេទនាត្រូវហូរទៅមិនចេះចប់យ៉ាងនេះ។

II

## សភាពមនុស្សលោក

1. សភាពមនុស្សលោក ប្រៀបដូចជាព្រៃក្រាស់ឥតច្រកចេញចូល ដែលពិបាកចូលទៅជាទីបំផុត។ បើប្រៀបទៅនឹងសភាពសត្វតិរច្ឆាន ឃើញថាសភាពសត្វតិរច្ឆានស្រួលយល់ជាង។ ប៉ុន្តែជាឱវ៉ាទទូទៅ យើងអាចឲ្យអត្ថន័យដល់សភាពនៃមនុស្សលោកបានតាមភាពជាខាងក្រៅបួនបែប។

ចំពូកទី១ គឺពពួកមនុស្សដែល ដោយហេតុសិក្ខាបទខុស មិនសមគន្ធង ធ្វើវត្តប្រតិបត្តិតឹងតែងហួស ហើយធ្វើទុក្ខទោសខ្លួនឯងផ្ទាល់។ ចំពូកទី២ គឺមនុស្សដែលដោយសារភាពសាហាវ លួចប្លន់ កាប់សម្លាប់ ឬអំពើកាចឃោរឃៅឯទៀតៗ ធ្វើឲ្យអ្នកឯទៀតមានសេចក្ដីឈឺចាប់។ ចំពូកទី៣ គឺពពួកមនុស្ស ដែលធ្វើឲ្យអ្នកដទៃឈឺចាប់ផង ខ្លួនឯងឈឺចាប់ផង។ ចំពូកទី៤ គឺពពួកមនុស្ស ដែលមិនធ្វើឲ្យខ្លួនឯងឲ្យឈឺចាប់ផង ហើយជួយជ្រោមជ្រែងអ្នកឯទៀតឲ្យរួចផុតពីការឈឺចាប់ផង។ មនុស្សក្នុងចំពូកខាងក្រោយនេះ ដោយជឿតាមពុទ្ធោវាទ វៀរចាកសេចក្ដីលោភលន់ សេចក្ដីក្រោធខឹង និងសេចក្ដីឆ្កួតភ្លីភ្លើ។ គេរស់នៅដោយស្ងប់ យកសេចក្ដីករុណាគតិបណ្ឌិតជាគ្រឹះហើយចៀសចេញឆ្ងាយពីការកាប់សម្លាប់លួចប្លន់។

2. មានមនុស្សបីប្រភេទ នៅក្នុងលោកនេះ។ មនុស្សមួយប្រភេទ គឺដូចជាអក្សរដែលគេចារលើថ្ម មនុស្សទាំងនោះធាប់ខឹងក្រោធណាស់ ហើយទុកគំនុំនោះជាយូរអង្វែង។ មនុស្សមួយប្រភេទទៀត ប្រៀបដូចជាអក្សរដែលគេចារលើខ្សាច់ មនុស្សប្រភេទនេះធាប់ខឹងក្រោធ តែចិត្តខឹងក្រោធនោះមិននៅយូរ

ទេ។ មនុស្សមួយប្រភេទទៀត ប្រៀបដូចអក្សរដែលគេសរសេរលើទឹកហូរ មនុស្សប្រភេទនេះមិនរក្សាគំនុំទុកក្នុងចិត្តទេ គេបណ្តោយឲ្យការប្រមាថ និងពាក្យសម្តីមិនគួរឲ្យចូលចិត្តទៅបាត់ទៅដោយគ្មានយកចិត្តទុកដាក់អំពល់រវល់ ចិត្តរបស់គេនៅបរិសុទ្ធមិនរំភើបញាប់ញ័រ។

មានមនុស្សបីប្រភេទទៀត នៅក្នុងលោកនេះ។ មនុស្សមួយប្រភេទ ឡឺតក្រអឺតក្រអោង ព្រហើនកោងកាច មិនចេះសប្បាយចិត្តនឹងអ្វីទេ សភាពមនុស្សប្រភេទនេះ ស្រួលយល់ទេ។ មនុស្សមួយប្រភេទទៀត ចេះគួរសម ហើយប្រព្រឹត្តអំពើអ្វីៗដោយគិតគូរ សភាពមនុស្សប្រភេទនេះ ពិបាកយល់ណាស់។ មនុស្សក្នុងប្រភេទទីបីគឺមនុស្សដែលចេះគ្រប់គ្រងចំណង់របស់ខ្លួនបានទាំងគ្រប់ សភាពមនុស្សប្រភេទនេះមិនអាចយល់បានទេ។

គេអាចចែកមនុស្សលោកបានជាច្រើនប្រភេទ ប៉ុន្តែ សភាពរបស់មនុស្សលោកនៅតែពិបាកយល់ជានិច្ច។ មានតែព្រះពុទ្ធជាម្ចាស់ទេ ដែលអាចយល់គ្រប់ ដោយសារព្រះបញ្ញាដ៏វៃ

វិសេសវិសាល ព្រះអង្គអាចដឹកនាំមនុស្សលោកតាមរបៀបទូន្មានផ្សេងៗគ្នា។

III

# ជីវិតមនុស្សលោក

1. មានរឿងនិទានស្តីអំពីជីវិតមនុស្សមួយថាៈ មានបុរសម្នាក់ជិះទូកលេងនៅក្នុងស្ទឹងមួយ។ មានបុរសម្នាក់ទៀតឈរនៅមាត់ច្រាំង ស្រែកព្រមានប្រាប់ទៅបុរសជិះទូកនោះថាៈ «ចូរឈប់អុំទូកលេងសប្បាយនៅតាមខ្សែទឹក ដែលហូរខ្លាំងក្លានេះទៅ នៅឆ្ងាយពីនេះបន្តិចមានខ្សែទឹកហូរធ្លាក់ខ្លាំង និងខ្សែទឹកក្ដួចប្រកបដោយគ្រោះថ្នាក់មានក្រពើ និងខ្មោចទឹកនៅក្នុងរូងថ្ម។ បើអ្នកទៅមុខបន្តិចទៀតអ្នកនឹងអស់ជីវិតជាពុំខាន!»។

ក្នុងរឿងប្រៀបធៀបនេះខ្សែទឹកក្ដួចខ្លាំង គឺជីវិតអភិជ្ឈាឬចំណង់ផប់ផល់។ អុំទូកលេងយ៉ាងសប្បាយរីករាយ គឺបណ្ដោយខ្លួនឲ្យតណ្ហាដឹកនាំបានដោយសេរី។ ខ្សែទឹកធ្លាក់ខ្លាំងគឺទុក្ខព្រួយដែលអន្ទោលតាមប្រាណ។ ខ្សែទឹកក្ដួចគឺការ

សប្បាយក្អេតក្អេន។ ក្រពើនិងខ្មោចទឹក គឺជរាភាពនិងសេចក្តីស្លាប់ដែលអន្ទោលតាមជីវិតអកិជ្ញានិងធ្វេសប្រហែស។ បុរសដែលឈរនៅមាត់ច្រាំងស្រែកព្រមានទៅនោះគឺព្រះពុទ្ធ។

មាននិទានមួយទៀតថា: «មានបុរសម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋហើយគេចរត់យ៉ាងលឿន។ ដោយមានប៉ូលិសដេញតាមចាប់ បុរសនោះក៏រត់ទៅពួនក្នុងបាតអណ្តូងប្រតោងវល្លិឈើ ដែលដុះព័ទ្ធគែមអណ្តូង។ នៅពេលដែលបុរសប្រតោងវល្លិចុះទៅបាតអណ្តូង គាត់ប្រទះនឹងពស់វែកមួយនៅបាតអណ្តូង គាត់ក៏ប្រតោងវល្លិឡើងមកផុតទីគ្រោះថ្នាក់វិញ។ ក្រោយបន្តិចមកនៅពេលដែលគាត់ចាប់ចុកស្រពន់ដៃ គាត់ប្រទះឃើញកណ្តុរពីរ មួយសមួយខ្មៅ កំពុងតែកកេរកាត់វល្លិ។

បុរសនោះនឹកគិតថា: «បើវល្លិនេះដាច់ទៅ អញនឹងធ្លាក់ទៅក្នុងដំរំពស់វែក ហើយត្រូវវាចឹកស្លាប់ពុំខាន!» ។

បុរសនោះងើបក្បាលឡើង ប្រទះនឹងសម្បុកឃ្មុំនៅប្របនឹងមុខ។ ខណៈនោះទឹកឃ្មុំមួយតំណក់ធ្លាក់មកចំមាត់គាត់ គាត់ភ្លេចអស់គ្រោះថ្នាក់ ហើយក្រេបរសជាតិផ្អែមឆ្ងាញ់នៃតំណក់ទឹកឃ្មុំនោះទៅ។

ឃើញថា មនុស្សលោកកើតមកសម្រាប់រងទុក្ខនិងស្លាប់ទៅវិញតែប៉ុណ្ណោះ។ ប៉ូលិសនិងពស់វែកសំដៅទៅលើរូបកាយនិងចំណង់គ្រប់បែបយ៉ាងនៃរូបកាយ។ រល្ងិឈើ គឺភាពតគ្នាមិនដាច់នៃជីវិតមនុស្ស។ កណ្ដុរមួយសមួយខ្មៅទាំងពីរ បានន័យចំពោះថ្ងៃ និងយប់ដែលមកដល់ជាបន្តបន្ទាប់គ្នាមិនដាច់។ ទឹកឃ្មុំប្រៀបបានទៅនឹងចំណង់នៃរូបកាយ ដែលបន្ធូបទុក្ខមួយគ្រា។

2. មានរឿងនិទានប្រៀបធៀបមួយទៀតថា: មានក្សត្រមួយព្រះអង្គយកពស់វែកបួនដាក់ក្នុងប្រអប់មួយ ហើយប្រគល់ប្រអប់នោះទៅអាមាត្យម្នាក់ឲ្យរក្សាទុក។ ព្រះមហាក្សត្រទ្រង់បញ្ជាអាមាត្យនោះរក្សាពស់វែកទាំងបួនឲ្យបានហ្មត់ចត់បើធ្វើឲ្យពស់វែកណាមួយខឹង នឹងយកទោសដល់ជីវិត។ អាមាត្យក័យខ្លាចខ្លាំងពេក ក៏គ្រវាត់ប្រអប់ចោលរួចហើយ គេចរត់ទៅ។

ព្រះមហាក្សត្របញ្ជូនកងរក្សាព្រះអង្គប្រាំនាក់ ឲ្យតាមចាប់អាមាត្យនោះ។ មុនដំបូងកងរក្សាព្រះអង្គទាំងប្រាំនោះចូលទៅជិតអាមាត្យនោះក្នុងភាពជាមិត្ត ដោយសង្ឃឹមថានឹង

ចាប់កុំឲ្យដឹងខ្លួន។ ប៉ុន្តែអាមាត្យមិនជឿសម្ដីផ្អែមល្ហែមនោះទេ ហើយក៏រត់ចូលក្នុងភូមិមួយទៀតទៅ។ ក្នុងការស្រមៃមួយប៉ប្រិចភ្នែក អាមាត្យឮសូរសំឡេងមួយមកប្រាប់ខ្លួនថា នៅក្នុងភូមិនោះមិនបានសុខទេ ពីព្រោះមានចោរប្រាំមួយនាក់បម្រុងនឹងចូលមកប្លន់។ ដោយភ័យខ្លាំងអាមាត្យក៏រត់រហូតទៅទាល់នឹងស្ទឹងមានទឹកហូរខ្លាំងមួយ។ នឹកគិតទៅដល់គ្រោះថ្នាក់ទាំងឡាយដែលតាមកិតពីក្រោយ អាមាត្យនោះក៏ធ្វើក្បូនមួយ ហើយឆ្លងខ្សែទឹកកួច បានរួចផុតពីគ្រោះថ្នាក់ដោយសុវត្ថិភាពដល់ទៅច្រាំងម្ខាងទៀត។

ពស់វែកទាំងបួនដែលជាប់នៅក្នុងប្រអប់ គឺជាតុទាំងបួន គឺៈ ដី ទឹក ភ្លើង ខ្យល់ ដែលផ្គុំគ្នាឡើងបានជារូបកាយ។ រូបកាយជាដើមហេតុនៃអភិជ្ឈា ដែលជាសត្រូវនឹងវិញ្ញាណ។ ដោយសារហេតុនេះហើយ បានជាវិញ្ញាណចេះតែខិតខំរត់ចេញឆ្ងាយពីរូបកាយ។

ក្រុមរក្សាព្រះអង្គទាំងប្រាំនាក់ ដែលចូលមកជិតក្នុងភាពជាមិត្តនោះ គឺខន្ធទាំងប្រាំ ដែលផ្គុំគ្នាបង្កើតជារូបកាយ និង

ចិត្តគឺៈ រូបរាង១ អារម្មណ៍១ ការដឹងដោយវិញ្ញាណ១ ដំណើរកកើតចិត្តគំនិត១ និងមនសិការ១។

ទីជម្រកសុខសាន្ត តំណាងញាណសក្តិទាំងប្រាំមួយដែលតាមពិតពុំមែនជាជម្រកសុខសាន្តពិតប្រាកដទេ។ ចោរប្រាំមួយនាក់នោះគឺវត្ថុនៃញាណសក្តិទាំងប្រាំមួយនេះឯង។ ហេតុនេះដោយមើលឃើញគ្រោះថ្នាក់នៅក្នុងញាណសក្តិទាំងប្រាំមួយនេះ អាមាត្យក៏រត់គេចម្តងទៀតទៅប្រទះនឹងខ្សែទឹកហូរខ្លាំងនៃចំណង់លោកិយ។

ក្បូនចម្លង គឺសេចក្តីទូន្មានប្រសើរឧត្តមរបស់ព្រះពុទ្ធ។ ដោយសារសេចក្តីទូន្មានទាំងនេះហើយ ដែលអាមាត្យអាចឆ្លងខ្សែទឹកហូរខ្លាំងនៃតណ្ហារួចទៅដល់ត្រើយម្ខាងទៀតប្រកបដោយសុវត្ថិភាព។

3. មានកាលៈទេសៈបីប្រកបដោយគ្រោះថ្នាក់ ដែលមិនអាចឲ្យកូនជួយសង្គ្រោះម្តាយបាន ឬម្តាយជួយសង្គ្រោះកូនបានគឺៈ អគ្គីភ័យ១ ទឹកជំនន់១ ចោរប្លន់១។ ប៉ុន្តែក្នុងកាលៈទេសៈប្រកបដោយគ្រោះថ្នាក់យ៉ាងនេះក៏ដោយ ក៏នៅមានភ័ព្វល្អអាចជួយគ្នាទៅវិញទៅមកបាន។

តណ្ហា

ប៉ុន្តែមានកាលៈទេសៈបីទៀត ដែលម្តាយពុំអាចជួយកូនបានឬកូនជួយម្តាយបានជាដាច់ខាត គឺៈ ឈឺ ជរា ស្លាប់។

កាលណាម្តាយជរាហើយ តើកូនអាចជរាជួសម្តាយដូចម្តេចបាន? កាលណាកូនឈឺហើយ តើម្តាយអាចឈឺជួសកូនដូចម្តេចបាន?កាលណាមរណកាលមកដល់ហើយ តើម្តាយនិងកូនអាចជួយគ្នាទៅវិញទៅមកដូចម្តេចបាន? ទោះបីគេស្រឡាញ់គ្នាយ៉ាងណាក៏ដោយ ទោះបីជាគេជិតស្និទ្ធនឹងគ្នាយ៉ាងណាក៏ដោយ ក៏គេពុំអាចជួយគ្នាបានជាដាច់ខាតក្នុងកាលៈទេសៈនេះ។

4. ថ្ងៃមួយ ព្រះយម ស្តេចមច្ចុរាជសួរទៅបុរសម្នាក់ដែលធ្លាក់ទៅក្នុងនរក ដោយសារកម្មអាក្រក់ដែលបានប្រព្រឹត្តអំពីជាតិមុនថាៈ កាលពីជាតិមុនអ្នកមានដែលបានជួបនឹងអ្នកនាំសារពីឋានសួគ៌បីនាក់ឬទេ។ បុរសនោះឆ្លើយថាៈ «អត់ទេព្រះបាទជាម្ចាស់ ខ្ញុំមិនដែលបានជួបនឹងជនបែបនេះ ម្តងណាទេ !»។ ព្រះយមបាលក៏សួរទៅទៀតថាៈ «អ្នកមានដែលបានជួបនឹងមនុស្សជរាម្នាក់ មានស្បែកជ្រីវជ្រួញ ដើរនឹងឈើច្រត់ដៃរឬ

ទេ?»។ បុរសនោះឆ្លើយថា: «ប្រាកដណាស់ ព្រះជាម្ចាស់ ខ្ញុំតែង បានជួបមនុស្សបែបនេះ ជាច្រើនដង!»។ ព្រះយមបាលក៏ប្រាប់ បុរសថា: ដែលអ្នករងទុក្ខទោសក្នុងនរកនៅពេលនេះ ព្រោះតែ អ្នកមិនបានទទួលស្គាល់ថា នៅក្នុងរូបមនុស្សជរានោះ មាន អ្នកនាំសារម្នាក់បញ្ជូនមកពីឋានសួគ៌ដើម្បីព្រមានដល់អ្នកឲ្យ ប្តូរជីវភាពរស់នៅ មុននឹងអ្នកទៅជាចាស់ជរា។

ព្រះយមបាលសួរទៅបុរសនោះទៀតថា: «អ្នកមានដែល បានជួបមនុស្សម្នាក់ឈឺគ្រាំគ្រា ក្ររហេមរហាមគ្មានមិត្តភក្តិដែរ ឬទេ?» បុរសនោះឆ្លើយថា: «ប្រាកដណាស់ព្រះជាម្ចាស់ ខ្ញុំ បានជួបមនុស្សបែបនេះជាញឹកញយ !» ។ យមបាលក៏ប្រាប់ បុរសនោះថា: អ្នកឯងត្រូវចុះមកក្នុងនរកនេះក៏ព្រោះតែអ្នក ឯងពុំបានទទួលស្គាល់ថា នៅក្នុងរូបអ្នកជំងឺអស់ទាំងនោះ មានអ្នកនាំសារបញ្ជូនមកពីឋានសួគ៌ ដើម្បីព្រមានប្រាប់ដល់ អ្នកអំពីជំងឺគ្រាំគ្រារបស់អ្នកឯងផ្ទាល់។

ព្រះយមបាលសួរបុរសនោះជាលើកទី៣ថា «ចុះអ្នកឯង មានដែលឃើញមនុស្សស្លាប់ដែរឬទេ?»។ បុរសនោះឆ្លើយថា: «ប្រាកដណាស់ព្រះជាម្ចាស់ ខ្ញុំបានជួបប្រទះនឹងមនុស្សស្លាប់

ច្រើនដង!»។ ព្រះយមបាលក៏ប្រាប់បុរសនោះថា: «ដែលអ្នកឯងចុះមកដល់ទីនេះក្នុងគ្រានេះ ក៏ព្រោះតែអ្នកឯងមិនទទួលស្គាល់ថា នៅក្នុងរូបមនុស្សស្លាប់នោះមានអ្នកនាំសារពីឋានសួគ៌បញ្ជូនមក ដើម្បីព្រមានដល់អ្នកថាថ្ងៃណាមួយអ្នកក៏ត្រូវស្លាប់ដែរ។ បើសិនជាអ្នកបានទទួលស្គាល់អ្នកនាំសារពីឋានសួគ៌ទាំងបីនេះ ស្តាប់តាមសេចក្តីព្រមាននៃអ្នកនាំសារទាំងនេះ ហើយអ្នកផ្លាស់ប្តូរជីវភាពរស់នៅ អ្នកមិនត្រូវបានចុះមកក្នុងទីប្រកបដោយទុក្ខវេទនានេះទេ»។

5. កាលមួយនោះមានក្មេងស្រីម្នាក់ឈ្មោះ **កិសគោតមី** ជាស្ត្រីមេម៉ាយប្តីអ្នកមានស្តុកស្តម្ភ។ ស្រីនោះវង្វេងសតិដោយត្រូវកូនស្លាប់។ ស្រីនោះបីកូនស្លាប់ទៅពីផ្ទះមួយទៅផ្ទះមួយដើម្បីអង្វរគេឯងឲ្យព្យាបាលកូនឲ្យបានជាឡើងវិញ។

ជាការប្រាកដណាស់ គ្មាននរណាម្នាក់អាចជួយស្រីនោះបានទេ។ ពេលនោះ ស្រីនោះបានជួបនឹងសាវ័កព្រះពុទ្ធមួយអង្គ។ ព្រះសាវ័កនោះ បានទូន្មានស្រីនោះឲ្យទៅជួបនឹង

ព្រះពុទ្ធ ដែលគង់នៅឯដែនជេតវន។ ស្រីនោះឮហើយក៏បីកូនស្លាប់ទៅរកព្រះពុទ្ធដល់ទីកន្លែង។

ព្រះបរមពិត្រទតទៅស្រីនោះ ដោយក្តីអាសូរពន់ពេក ហើយក៏មានពុទ្ធដីកាថាៈ «ដើម្បីព្យាបាលកូនរបស់នាងឲ្យបានជាឡើងវិញ តថាគតត្រូវការឫសដើមអាភៀន។ ចូរនាងទៅរកផ្ទះណាដែលសេចក្តីមរណៈមិនដែលចូលសោះ ហើយសុំឫសដើមអាភៀនគេឲ្យតថាគតបានបួនប្រាំទង»។

ស្រីវិកលចរិតនោះ ក៏ចេញទៅរកផ្ទះណាដែលសេចក្តីមរណៈមិនដែលចូលសោះ ប៉ុន្តែរកមិនប្រទះសោះ។ ទីបំផុតស្រីនោះសម្រេចចិត្តវិលមករកព្រះពុទ្ធវិញ។ មកដល់ឃើញព្រះពុទ្ធគង់ក្នុងភាពស្ងប់ជាទីបំផុត សតិស្រីនោះក៏ភ្ញឺស្វាងឡើងមួយរំពេច ហើយនាងបានយល់ន័យព្រះពុទ្ធដីកានោះភ្លាម។ នាងក៏យកសពកូននាងទៅបូជាទៅ។ បន្ទាប់មក នាងត្រឡប់មករកព្រះពុទ្ធវិញហើយជឿតាមសាសនាព្រះអង្គតរៀងទៅ។

IV

# ភាពពិតនៃជីវិតមនុស្សលោក

1. មនុស្សក្នុងលោកនេះ បាក់ចិត្តទៅលើតែអត្តទត្តភាព និងអំពើកាចឃោរឃៅ។ គេមិនដឹងថាស្រឡាញ់ និងគោរពគ្នាទៅវិញទៅមក របៀបយ៉ាងដូចម្ដេចទេ។ គេប្រកាប់ប្រចាក់គ្នាឥតប្រយោជន៍ បានតែការឈឺចាប់ទុក្ខព្រួយមកលើខ្លួនឯងផ្ទាល់តែប៉ុណ្ណោះ។ ដោយសារហេតុនេះ ជីវិតត្រូវបានព័ទ្ធជុំវិញទៅដោយទុក្ខវេទនា។

មានក្ដីឬក្រក្ដី មនុស្សលោកព្រួយបារម្ភតែនឹងមាសប្រាក់ គេរងទុក្ខព្រួយព្រោះតែក្រ តែគេរងទុក្ខព្រួយក៏ព្រោះតែមាន។ ដោយសារតែលុះទៅក្នុងចំណង់ មនុស្សលោកនេះមិនចេះសប្បាយចិត្ត និងពេញចិត្តម្ដងណាទេ។

អ្នកមានវក់ឆ្កួតនឹងស្ថានភាពខ្លួន នឹងវិមានស្ដុកស្ដម្ភប្រណីតរបស់ខ្លួន នឹងអ្វីៗគ្រប់យ៉ាងដែលខ្លួនមាន។ គេព្រួយបារម្ភដោយនឹកគិតថា ថ្ងៃណាមួយភយន្ដរាយនឹងមកដល់ខ្លួន ភ្លើងនឹងឆេះផ្ទះខ្លួន ចោរនឹងលួចប្លន់ទ្រព្យសម្បត្តិរបស់ខ្លួន។ គេព្រួយបារម្ភនឹងការស្លាប់ នឹងការចាត់ចែងទ្រព្យសម្បត្តិ

ក្រោយអំពីពេលគេស្លាប់ទៅ។ ជាការពិតគេស្លាប់ទៅតែម្នាក់ឯងគត់គ្មានអ្វីទៅតាមមនុស្សស្លាប់ទេ។

អ្នកក្រកើតទុក្ខជានិច្ចនឹងការខ្វះខាតរបស់ខ្លួន ហេតុនេះគេមានសេចក្ដីប្រាថ្នាចង់បានរបស់ជាច្រើនលើសលប់ មិនចេះឆ្អែតឆ្អន់ ដូចជាផ្ទះសម្បែងទ្រព្យសម្បត្តិជាដើម។ ដោយសារចំណង់លោភលន់វាដុតរោល គេអស់ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ហើយគេត្រូវស្លាប់មុនអាយុ។

គេឃើញហាក់ដូចជាលោកទាំងមូលជាសត្រូវ ចំពោះគេ ហើយសេចក្ដីស្លាប់ហាក់ដូចជាដំណើរមួយសែនឆ្ងាយ ដែលគេត្រូវដើរយ៉ាងកំសត់តែម្នាក់ឯង គ្មានមិត្តភក្តិទៅជាមួយ។

2. ក្នុងលោកនេះមានអំពើអាក្រក់ប្រាំប្រការគឺៈ ទី១ ភាពសាហាវឃោរឃៅ។ សត្វទាំងអស់ សូម្បីសត្វល្អិតតែងតែប្រកួតប្រឆាំងគ្នាទៅវិញទៅមក។ សត្វខ្លាំងប្រហារសត្វខ្សោយ។ សត្វខ្សោយបោកបញ្ឆោតសត្វខ្លាំង។ កន្លែងណាក៏ដោយ ក៏មានអំពើឃោរឃៅប្រកាប់ប្រចាក់គ្នាដែរ។

ទី២ គឺដំណើរគ្មានព្រំដែនកំណត់ជាក់លាក់រវាងសិទ្ធិរបស់

ឪពុក និងសិទ្ធិរបស់កូន រវាងសិទ្ធិរបស់កូនច្បង និងសិទ្ធិរបស់កូនពៅ រវាងសិទ្ធិរបស់ប្ដីនិងសិទ្ធិរបស់ប្រពន្ធ រវាងសិទ្ធិរបស់មនុស្សចាស់ និងសិទ្ធិរបស់មនុស្សក្មេង។ នៅគ្រប់កាលៈទេសៈម្នាក់ៗខំប្រឹងឲ្យបានខ្ពស់ជាងអ្នកឯទៀត ធៀតឲ្យបានលើអ្នកឯទៀត។ ម្នាក់បន្ទំម្នាក់ជាហេតុបណ្ដាលឲ្យមានការមិនទុកចិត្តគ្នា និងការលាក់ពុតរវាងគ្នានឹងគ្នា។

ទី៣ គឺដំណើរគ្មានព្រំដែនកំណត់ជាក់លាក់រវាងចរិយាមារយាទបុរស និងចរិយាមារយាទស្ត្រី។ ម្នាក់ៗលុះក្នុងបំណងអាក្រក់ ជាហេតុបណ្ដាលឲ្យមានការទាស់ទែងសម្ដីគ្នាជួនកាល រហូតដល់ទៅបណ្ដាលឲ្យមានការប្រវាយប្រតប់គ្នា ប្រព្រឹត្តអំពើអយុត្តិធម៌កាចឃោរឃៅ។

ទី៤ គឺមនុស្សលោកមានគំនិតមិនគោរពសិទ្ធិអ្នកដទៃ ធៀតរកប្រយោជន៍ផ្ទាល់ខ្លួន ដោយគ្មានគិតដល់ការខូចខាតប្រយោជន៍អ្នកដទៃ។ គេផ្ដល់គំរូអាក្រក់ដោយចរិយាអាក្រក់ ដោយពាក្យសម្ដីអាក្រក់ ដោយការបញ្ឆោតប្រវញ្ចន៍ដោយពាក្យមួលបង្កាច់ ដោយការជេរប្រមាថ។

ទី៥ គឺមនុស្សលោកមានគំនិតបំភ្លេចករណីយកិច្ចរបស់

ខ្លួនចំពោះអ្នកដទៃ។ គេគិតតែពីសុខុមាលភាពផ្ទាល់ខ្លួន គិតតែពីសេចក្ដីពេញចិត្តរបស់ខ្លួន។ គេភ្លេចអស់ហើយអំពើល្អទាំងពួងដែលគេបានទទួលពីអ្នកដទៃ ហើយគេមិនខ្វាចនឹងបង្កើតទុក្ខទោសដល់អ្នកដទៃទេ។

3. មនុស្សត្រូវតែមានមេត្រីភាពរវាងគ្នានឹងគ្នា ត្រូវចេះគោរពគ្នាទៅវិញទៅមក ហើយត្រូវចេះជួយគ្នាទៅវិញទៅមក ក្នុងគ្រាក្រលំបាក។ ប៉ុន្តែមិនអញ្ចឹងទេ មនុស្សលោកគិតតែពីខ្លួនឯង ហើយមានចិត្តរឹងរូស។ គេមើលងាយអ្នកឯទៀតដោយសារកំហុសដែលអ្នកទាំងនោះបានធ្វើ។ គេច្រណែននឹងអ្នកឯទៀតព្រោះតែអ្នកទាំងនោះបានប្រយោជន៍ច្រើនជាង។ ចិត្តអាក្រក់ទាំងនេះរីកធំឡើងៗរហូតដល់ទៅលែងចេះអត់ឱនគ្នាកើត។

ចិត្តជាសម្អប់ទាំងនេះ បណ្ដាលឲ្យកើតមានអំពើឃោរឃៅ។ ចិត្តអាក្រក់ទាំងនេះ បំពុលជីវិតដោយក្ដីស្អប់និងក្ដីខឹងក្រោធ ដែលបណ្ដាលឲ្យកើតចិត្តរបៀបនេះ។ មនោសញ្ចេតនាអាក្រក់ទាំងនេះ ផ្ដិតជាប់យ៉ាងជ្រៅនៅក្នុងបេះដូងមនុស្សក្នុង

រយៈវិលរស់វិលស្លាប់នេះៗ

ជាប្រាកដណាស់ ក្នុងលោកអភិជ្ឈានេះ មនុស្សកើតមក តែម្នាក់ឯង ហើយស្លាប់ទៅវិញតែម្នាក់ឯងៗ ការទទួលផល កម្មពីអំពើដែលខ្លួនបានប្រព្រឹត្តក្នុងរយៈវិលកើតវិលស្លាប់ ក៏ តែម្នាក់ឯងដែរៗ

ច្បាប់ស្តីអំពីហេតុ និងផលនេះ វាសកលទូទៅៗ ម្នាក់ៗ ត្រូវ តែស្ពាយសំពាយកំហុសរបស់ខ្លួនដោយខ្លួនឯង ហើយទទួល ផលកម្មតែម្នាក់ឯងៗ ច្បាប់ស្តីអំពីហេតុ និងផលនេះ ក៏គ្រប់ គ្រងលើអំពើល្អដែរៗ ការរស់នៅក្នុងសភាពល្អប្រកបដោយ ចិត្តមេត្តាប្រណី នឹងបានដល់នូវសម្បត្តិសួគ៌ា និងសុភមង្គលៗ

4. ក្នុងរយៈដែលខែនិងឆ្នាំ បេះតែកន្លងទៅមុខនេះ សត្វ លោកឃើញខ្លួនជាប់ជំពាក់នឹងចំណង់ នឹងទម្លាប់ នឹងទុក្ខ កាន់តែខ្លាំងឡើងៗ ក៏ទៅជាព្រួយចិត្ត ហើយអស់សង្ឃឹមៗ ជា ញឹកញាយ ដោយសារតែសេចក្តីអស់សង្ឃឹមនេះ សត្វលោក បង្កើតជម្លោះនឹងអ្នកឯទៀត ហើយធ្លាក់កាន់តែជ្រៅឡើងៗ ទៅក្នុងបាបកម្ម លះបង់ចោលអស់នូវការខំប្រឹងប្រែង ដើរតាម

ផ្លូវល្អ។ មនុស្សខ្លះ ត្រូវអស់ជីវិតជាបន្ទាន់ដោយសារអំពើកាចឃោរឃៅរបស់ខ្លួន ហើយជាបន្តទៅទៀត គេត្រូវរងទុក្ខទោស រងកម្មពៀរមិនចេះចប់។

ធ្លាក់ខ្លួនក្នុងការអស់សង្ឃឹម ព្រោះតែមានក្តីអភ័ព្វ មានទុក្ខព្រួយយ៉ាងនេះ មិនត្រូវតាមធម្មជាតិហើយនិងច្បាប់ឋានសួគ៌និងឋានកណ្តាលនេះជាដាច់ខាត។ ដូច្នេះបុគ្គលទាំងនេះ មិនត្រឹមតែទទួលទុក្ខនៅក្នុងជាតិនេះប៉ុណ្ណោះទេ ទៅក្នុងជាតិជាបន្តទៅទៀត ក៏ត្រូវតែទទួលទុក្ខរងកម្មពៀរទៀត។

ជាការពិតដែលថា អ្វីៗនៅក្នុងលោកនេះ មិនឋិតថេរហើយពោរពេញទៅដោយភាពមិនទៀង។ ប៉ុន្តែជាការគួរឲ្យអាណោចអាធ័មណាស់ ដែលមនុស្សលោកមិនព្រមយល់រឿងពិតនេះ ហើយខំស្វែងរកតម្រេក និងការពេញចិត្តនឹងតម្រេកនោះ។

5. បើសិនជានៅក្នុងលោកនេះ ការគិតនិងការប្រព្រឹត្តទៅតាមអត្តទត្តភាពជាការធម្មតា ការទទួលទុក្ខវេទនាពីអំពើទាំងនេះ ក៏ជាការធម្មតាដូចគ្នាដែរ។

តណ្ហា

មនុស្សលោកគិតតែអំពីខ្លួនឯងផ្ទាល់ មិនរវល់នឹងអ្នកឯទៀតក្រៅពីខ្លួនឯងទេ។ គេបណ្តោយឲ្យចំណង់របស់គេ ទៅជាការលោភលន់ ទៅជាអភិជ្ឈា ទៅជាអំពើលាមកគ្រប់បែបយ៉ាង។ នេះហើយដែលមនុស្សលោកត្រូវរងទុក្ខទោស រងកម្មពៀរមិនចេះចប់។

ពេលសប្បាយរីករាយនៅមិនយូរប៉ុន្មានទេ វានឹងវិនាសទៅវិញយ៉ាងឆាប់ ដូចកាលដែលវាមកដល់ដែរ។ ក្នុងលោកនេះ មិនអាចសប្បាយនឹងអ្វីមួយឲ្យបានយូរអង្វែងទេ។

6. ហេតុដូច្នេះ បុគ្គលត្រូវលះបង់អភិជ្ឈា ហើយនិងការជាប់ជំពាក់ចិត្តនឹងសម្បត្តិលោកនេះ ទាន់ខ្លួននៅក្មេងហើយមានសុខភាពល្អ។ បុគ្គលត្រូវខិតខំស្វែងរកផ្លូវនៃពន្លឺត្រាស់ដឹង ពីព្រោះគេមិនអាចមានសេចក្តីស្ងប់មានសុភមង្គលបានទេនៅទីណាដែលគ្មានពន្លឺត្រាស់ដឹង។

ប៉ុន្តែមនុស្សជាច្រើនជឿច្រឡំ ហើយពុំយល់នូវច្បាប់ស្តីអំពីហេតុនិងផលនេះ។ គេប្រព្រឹត្តតាមទម្លាប់អភិជ្ឈានិងអត្ត-ទត្តភាព។ គេភ្លេចថា អំពើល្អផ្តល់សុភមង្គល អំពើអាក្រក់ផ្តល់

ទុក្ខវេទនា។ គេមិនជឿប្រាកដទេថា អំពើទាំងឡាយដែលគេបានធ្វើក្នុងជាតិនេះ នឹងផ្តល់ផលកម្មទៅតាមអំពើអស់ទាំងនោះ ទៅជាតិមុខៗទៀត។ គេទម្លាក់ទុក្ខទោសដែលបណ្តាលមកពីអំពើរបស់គេទៅឲ្យអ្នកឯទៀត។

មនុស្សលោកអាណោចអាធ័មនឹងខ្លួនឯង ត្អូញត្អែរនឹងទុក្ខវេទនារបស់ខ្លួនផ្ទាល់។ គេមិនយល់ទាល់តែសោះថា អំពើដែលគេប្រព្រឹត្តក្នុងពេលបច្ចុប្បន្ននេះ នឹងផ្តល់ផលទៅក្នុងជីវិតអនាគតរបស់គេ។ គេមិនយល់ទាល់តែសោះនូវការទាក់ទងគ្នារវាងទុក្ខវេទនាក្នុងបច្ចុប្បន្នកាលរបស់គេនិងអំពើដែលគេបានប្រព្រឹត្តក្នុងជីវិតអតីតកាលរបស់គេ។ គេគិតតែអំពីចំណង់ក្នុងបច្ចុប្បន្នកាលរបស់គេតែប៉ុណ្ណោះ។ គេគិតពីទុក្ខ-វេទនាក្នុងបច្ចុប្បន្នកាលរបស់គេតែប៉ុណ្ណោះ។

នៅក្នុងលោកនេះ គ្មានអ្វីឋិតថេរទេ គ្មានអ្វីនៅជាប់ជាអង្វែងទេ។ អ្វីៗសុទ្ធតែប្រែប្រួលទាំងអស់ អ្វីៗទាំងអស់កើតឡើងតែមួយរយៈពេលប៉ុណ្ណោះ គ្មានអ្វីដែលអាចឲ្យទាយទុកមុនបានទេ។ ប៉ុន្តែមនុស្សលោកមានសេចក្តីល្ងង់ខ្លៅ ហើយនិងអត្តទត្ថភាព។ មនុស្សលោកចាប់អារម្មណ៍ទៅលើតែចំណង់

តណ្ហា

និងទុក្ខវេទនាក្នុងមួយរយៈវេលាតែប៉ុណ្ណោះ។ មនុស្សលោកមិនយកត្រចៀកស្តាប់សេចក្តីទូន្មានល្អទេ ហើយមិនខិតខំរកឲ្យយល់នូវសេចក្តីទូន្មានល្អទាំងនោះទេ។ មនុស្សលោកផ្តេកផ្តួលទៅលើអ្វីៗ ដែលខ្លួនចូលចិត្តត្រូវការក្នុងពេលភ្លាមៗ តែប៉ុណ្ណោះ ពោលគឺសម្បត្តិទ្រព្យនិងសេចក្តីសប្បាយ។

7. ជាច្រើនកោដិឆ្នាំមកហើយ មនុស្សរាប់មិនអស់បានកើតក្នុងលោកដែលពោរពេញទៅដោយការបំភាន់ភ្នែក និងទុក្ខវេទនានេះ ហើយនៅតែមានមនុស្សកើតឡើងក្នុងលោកនេះទៀត។ ប៉ុន្តែជាភ័ព្វសំណាងមួយ ដែលលោកនេះមានសាសនាព្រះពុទ្ធ ដែលមនុស្សលោកអាចជឿតាមបាន ហើយអាចទទួលការស្រោចស្រង់បានដោយសារជំនឿនេះ។

ដូចនេះមនុស្សលោកត្រូវគិតឲ្យដល់ទីជម្រៅ។ មនុស្សលោកត្រូវតែរក្សាចិត្តឲ្យបរិសុទ្ធ រក្សាខ្លួនឲ្យល្អ។ មនុស្សលោកត្រូវតែលះបង់អភិជ្ឈា ហើយនិងអំពើអាក្រក់ ហើយខំស្វែងរកសេចក្តីល្អ។

ជាសំណាងល្អ សេចក្តីទូន្មានរបស់ព្រះពុទ្ធបានមកដល់

ហើយៈ ដូច្នេះ យើងត្រូវខំជឿ និងប្រតិបត្តិតាម ហើយប្រាថ្នា ឲ្យបានទៅកើតក្នុងឋានបរិសុទ្ធរបស់ព្រះពុទ្ធ។ បើយើងដឹង ហើយយល់សេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធហើយ យើងមិន ត្រូវដើរតាមផ្លូវឯទៀត ដែលនាំយើងទៅកាន់អភិជ្ឈា និងអំពើ បាបកម្មផ្សេងៗនោះឡើយ។ យើងក៏មិនត្រូវរក្សាសេចក្តីប្រៀន ប្រដៅរបស់ព្រះពុទ្ធ ទុកសម្រាប់តែខ្លួនឯងម្នាក់នោះឡើយ យើងត្រូវតែដាក់សេចក្តីប្រៀនប្រដៅនោះ ក្នុងការប្រតិ បត្តិ ហើយផ្សាយទៅឲ្យអ្នកឯទៀតជាបន្ត។

# ចំពូកទី ៤

# ការត្រាស់ដឹងរបស់ព្រះពុទ្ធ

I

## សេចក្ដីប្រាថ្នារបស់ព្រះពុទ្ធអមិដា

1. *ដូចយើងបានរែកញែកពន្យល់មកហើយ តាំងពីរាប់កោដិឆ្នាំមកហើយ មនុស្សលោករងទុក្ខទោសនឹងទម្ងន់តណ្ហារបស់ខ្លួនដោយសន្សំប្រមូលកំហុសត្រួតលើកំហុស។ ដូច្នេះមនុស្សលោក មិនអាចយកគតិបណ្ឌិតរបស់ខ្លួនទៅរំលត់តណ្ហារបស់ខ្លួនបានឡើយ។ បើមិនអាចជម្នះតណ្ហារបស់ខ្លួនបានយ៉ាងដូច្នេះ តើធ្វើដូចម្ដេចមនុស្សលោកអាចនឹងយល់ដឹងសភាពពិតរបស់ខ្លួន ពោលគឺសភាពព្រះពុទ្ធនោះបាន?*

*ព្រះពុទ្ធទ្រង់យល់សភាពមនុស្សយ៉ាងជាក់ច្បាស់ ហើយព្រះអង្គទ្រង់មានសេចក្ដីករុណាអាសូរជាខ្លាំង។ ព្រះអង្គទ្រង់សច្ចាធិដ្ឋាន នឹងធ្វើគ្រប់អ្វីៗ ទាំងអស់ ដែលព្រះអង្គអាចធ្វើបានសូម្បីព្រះអង្គត្រូវជួបប្រទះនឹងសេចក្ដីលំបាក យ៉ាងណាក៏ដោយ*

ចុះ ដើម្បីរំដោះសត្វលោកឲ្យរួចផុតពីតណ្ហា និងទុក្ខវេទនា។ ក្នុងគោលបំណងនេះព្រះអង្គទ្រង់បញ្ចេញឲ្យឃើញក្នុងភាពជាពោធិសត្វហើយសច្ចាធិដ្ឋាន ១០ ប្រការថា:

១-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធសត្វទាំងអស់ដែលទៅកើតក្នុងដែនដីអញ នឹងយល់យ៉ាងប្រាកដអំពីសភាពព្រះពុទ្ធ។ បើពុំនោះទេ អាត្មាអញមិនចង់បានជាព្រះពុទ្ធឡើយ។

២-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ រស្មីរបស់អញនឹងចែងចាំងទៅគ្រប់ទិសទី នាសាកលលោក។ បើពុំនោះទេ អញមិនចង់បានជាព្រះពុទ្ធឡើយ។

៣-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យអញអាចរំដោះសត្វលោកឲ្យបានច្រើនបំផុត ក្នុងរយៈជីវិតអាត្មាអញ បើពុំនោះទេអាត្មាអញមិនចង់បានជាព្រះពុទ្ធឡើយ។

៤-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យព្រះពុទ្ធទាំង១០ទិស ប្រកាសឈ្មោះអញ។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

៥-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យសត្វលោកណាដែលប្រាថ្នាទៅកើតក្នុងដែនដីអញ ហើយប្រកាសឈ្មោះអញដោយសុទ្ធចិត្តតែម្តងគត់ បានទៅកើតនៅក្នុងដែនដីអញៗ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

៦-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យសត្វលោកណាដែលប្រាថ្នាពន្លឺត្រាស់ដឹង ហើយបំពេញកុសលដោយសុទ្ធចិត្តដើម្បីបានទៅកើតក្នុងដែនដីអញបានឃើញតែពពួកពោធិសត្វ នៅព័ទ្ធជុំវិញរង់ចាំទទួលយកទៅឲ្យកើតក្នុងដែនដីបរិសុទ្ធរបស់អញ នៅពេលសត្វលោកនោះស្លាប់ទៅ។ បើពុំនោះទេ អញមិនចង់បានជាព្រះពុទ្ធឡើយ។

៧-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធសូមឲ្យសត្វលោកទាំងអស់ដែលឮឈ្មោះអញ ដែលគិតដល់ផែនដីអញ ហើយបណ្តុះកុសលក្នុងសេចក្តីសង្ឃឹមយ៉ាងស្មោះថា នឹងទៅកើតក្នុងដែនដីអញបានសម្រេចដូចក្តីប្រាថ្នា។ បើពុំនោះទេ អញមិនចង់បានជាព្រះពុទ្ធឡើយ។

៨-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យសត្វលោកទាំងអស់ដែលទៅកើតក្នុងដែនដីអញ បានសម្រេចជា

ប្រាកដនូវសភាពព្រះពុទ្ធដើម្បីអាចដឹកនាំសត្វលោកទៅកាន់ពន្លឺត្រាស់ដឹងដ៏ពេញលេញ។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

៩-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យពន្លឺមហាករុណាអាសូររបស់អញ បានគ្របដណ្តប់ទៅលើសត្វលោកទាំងអស់ក្នុងពិភពលោកទាំងមូល ញ៉ាំងឲ្យវិញ្ញាណនិងកាយនៃសត្វលោកទាំងនោះបានបរិសុទ្ធ ហើយលើកសត្វលោកទាំងនោះ ឲ្យខ្ពស់ផុតពីលោកនេះ។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

១០-កាលណាអង្គអញបានត្រាស់ជាព្រះពុទ្ធ សូមឲ្យមនុស្សក្នុងលោកទាំងមូលដែលបានឮឈ្មោះអញ បានយល់នូវសេចក្តីពិតអំពីការកើត និងការស្លាប់ បានទទួលនូវមហាគតិបណ្ឌិតដែលអាចញ៉ាំងឲ្យចិត្តបានស្ងប់នាកណ្តាលទុក្ខវេទនានៃលោកនេះ។ បើពុំនោះទេអញមិនចង់បានជាព្រះពុទ្ធឡើយ។

ដូច្នេះអញសច្ចាថា នឹងមិនត្រាស់ជាព្រះពុទ្ធទេដរាបណាសេចក្តីសច្ចាធិដ្ឋានរបស់អញទាំងនេះមិនទាន់បានសម្រេច។ អញសូមប្រាថ្នាឲ្យបានជាប្រភពនៃពន្លឺគ្មានទីបំផុត ដែលបែង

ចាំងផ្សព្វផ្សាយទៅនូវកំណាប់ប្រាជ្ញាញាណនិងកុសលរបស់អញ ដើម្បីដាស់តឿនបំភ្លឺ និងសង្គ្រោះសត្វក្នុងលោកនេះ។

2. ក្រោយពីថ្ងៃសច្ចាធិដ្ឋានទាំងនេះ ហើយសន្សំកុសលជាច្រើនឥតគណនា ក្នុងកាលវេលារាប់មិនអស់ ព្រះអង្គបានបង្កើតដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ ហើយបានត្រាស់ជាព្រះពុទ្ធអាមិដា ព្រះពុទ្ធនៃពន្លឺនិងជីវិតគ្មានទីបំផុត។ សព្វថ្ងៃព្រះអង្គគង់នៅឯសុភលោក ប្រៀនប្រដៅបំភ្លឺជនទាំងឡាយដែលរស់នៅក្នុងដែនដីព្រះអង្គ។

នៅក្នុងដែនដីបរិសុទ្ធសុខស្ងប់នោះគ្មានទុក្ខព្រួយទេ។ ម្នាក់ៗអាចបានរបស់ដែលខ្លួនចង់បានដូចជាសំលៀកបំពាក់ក្តី ចំណីអាហារក្តី វត្ថុទិព្វឯទៀតៗក្តី។ ខ្យល់ត្រជាក់ស្រួលបក់រំភើយតាមដើមព្រឹក្សាប្រកបដោយផ្លែផ្កាជាត្បូងរ័តន៍។ សំឡេងតន្ត្រីព្រះធម៌សែនពីរោះ ធ្វើឲ្យចិត្តអ្នកដែលស្តាប់ឮបានឡើងបរិសុទ្ធ។

នៅក្នុងដែនដីបរិសុទ្ធនោះ មានផ្កាឈូកដែលមានស្រទាប់ស្រស់ៗ ច្រើនរាប់មិនអស់ដុះពាសពេញ។ រស្មីទិព្វនៃស្រទាប់

ផ្កាឈូកទាំងនោះ បែងចាំងឡើងនូវប្រាជ្ញាញាណរបស់ព្រះពុទ្ធ អ្នកដែលបានស្តាប់ព្យុតន្ត្រីទិព្វនៃពុទ្ធោវាទយ៉ាងពិសិដ្ឋនោះ នឹងបានដល់នូវសុភមង្គលពេញលេញឥតខ្ចោះ។

3. ឥឡូវនេះ ព្រះពុទ្ធគ្រប់ទិសទាំង ១០ ប្រកាសកុសលព្រះពុទ្ធអមិដា ដែលជាព្រះពុទ្ធនៃពន្លឺ និងជីវិតគ្មានទីបំផុត។

អ្នកដែលបានឮព្រះនាមព្រះពុទ្ធអង្គនេះជឿទុកចិត្តលើព្រះអង្គដោយទឹកចិត្តរីករាយជ្រះថ្លា ឃើញចិត្តរបស់ខ្លួនរលាយចូលទៅក្នុងចិត្តរបស់ព្រះពុទ្ធហើយ នឹងបានទៅកើតក្នុងដែនដីទិព្វបរិសុទ្ធរបស់ព្រះពុទ្ធ។

អ្នកដែលបានទៅដល់ដែនដីបរិសុទ្ធរបស់ព្រះពុទ្ធហើយ នឹងបានទទួលជីវិតគ្មានទីបញ្ចប់។ ចិត្តរបស់គេនឹងបានពោរពេញនូវសេចក្តីករុណា អាសូរចំពោះសត្វលោកដូចព្រះពុទ្ធដែរហើយគេនឹងចេញទៅផ្សាយ មធ្យោបាយសង្គ្រោះរបស់ព្រះពុទ្ធអមិដានៅគ្រប់ទីកន្លែង។

គេតាំងចិត្តលះបង់ការជំពាក់ចិត្តនឹងលោកិយនេះ ហើយគេយល់ជាក់អំពីភាពមិនឋិតថេរនៃវត្ថុទាំងឡាយ។ គេបញ្ជូន

កុសលរបស់គេ ទៅជួយសង្គ្រោះសត្វលោក។ គេបញ្ជូនជីវិតរបស់គេ ទៅក្នុងជីវិតរបស់អ្នកដែលរស់នៅក្នុងសេចក្តីទុក្ខវេទនា។ គេចែករំលែកយកនូវការបំភាន់ភ្នែកនិងទុក្ខវេទនា ហើយក្នុងពេលជាមួយគ្នានោះ គេរំដោះខ្លួនគេឲ្យផុតពីការជំពាក់ចិត្តនឹងលោកិយនេះ។

ដោយគេយល់ច្បាស់អំពីឧបសគ្គ និងសេចក្តីលំបាកផ្សេងៗនៃលោកនេះ គេដឹងថាអានុភាពនៃសេចក្តីករុណាអាសូររបស់ព្រះពុទ្ធគ្មានព្រំដែនទេ។ គេអាចដើរទៅមុខឬថយក្រោយវិញ ឬឈប់ស្ងៀមបានតាមចិត្តដែលគេយល់ថាត្រឹមត្រូវល្អ។ ប៉ុន្តែគេសម្រេចចិត្តនៅជាមួយអ្នកដែលទទួលយកសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ។

ដូច្នេះអ្នកដែលឮព្រះនាមព្រះពុទ្ធអមិដា ហើយប្រកាសព្រះនាមព្រះអង្គដោយចិត្តស្មោះត្រង់ នឹងបានទទួលនូវសេចក្តីករុណាអាសូររបស់ព្រះពុទ្ធ។ ដូច្នេះសត្វលោកទាំងអស់ត្រូវតែស្តាប់ជឿ ហើយប្រតិបត្តិតាមសេចក្តីទូន្មានរបស់ព្រះពុទ្ធ ទោះបីសម្រាប់ករណីនេះ គេត្រូវឆ្លងកាត់អណ្តាតភ្លើងនៃការកើត និងស្លាប់នៃលោកិយនេះក៏ដោយ។

អ្នកណា ដែលប្រាថ្នាដោយសុទ្ធចិត្តឲ្យបានសម្រេចនូវពន្លឺត្រាស់ដឹងត្រូវតែពឹងផ្អែកអានុភាពព្រះពុទ្ធពីព្រោះមនុស្សលោកជម្មតា មិនអាចយល់នូវសភាពព្រះពុទ្ធខ្ពង់ខ្ពស់បំផុតរបស់ខ្លួនបានទេ បើអត់ជំនួយពីព្រះពុទ្ធអមិដា។

4. ព្រះពុទ្ធអមិដា មិននៅឆ្ងាយពីយើងទេ។ ថ្វីបើដែនដីបរិសុទ្ធរបស់ព្រះអង្គត្រូវបានពិពណ៌នាថា ស្ថិតនៅសែនឆ្ងាយអំពីលោកនេះយ៉ាងណាក៏ដោយ ដែនដីនោះនៅជិតបង្កើយ នឹងចិត្តរបស់អ្នកដែលប្រាថ្នាពន្លឺត្រាស់ដឹង ហើយមានសទ្ធាមោះមុត នឹងព្រះពុទ្ធអមិដា ហើយប្រកាសព្រះនាមព្រះអង្គដោយស្មោះ។

បើគេនឹកគិតគូររូបភាពព្រះពុទ្ធអមិដា នៅក្នុងវិញ្ញាណរបស់គេ រូបភាពនោះចេញឡើងជាពណ៌មាសមានទិដ្ឋភាព ៨៤០០០ ហើយទិដ្ឋភាពនីមួយៗបញ្ចេញ៨៤០០០កាំរស្មី។ កាំរស្មីនីមួយៗសាយជះពន្លឺទៅគ្រប់ទិសទាំង១០ ក្នុងពិភពលោកបំភ្លឺជនទាំងឡាយណាដែលប្រកាសព្រះនាមព្រះពុទ្ធ។ ហេតុដូច្នេះហើយ បានជាព្រះពុទ្ធខិតខំជ្រោមជ្រែងឲ្យមនុស្សលោកទាំងអស់ ឆ្លៀតទទួលយកនូវការសង្គ្រោះ ដែលព្រះអង្គ

ទ្រង់ប្រទាន។

ការមើលឃើញរូបភាពរបស់ព្រះពុទ្ធនេះអាចនាំឲ្យយើងយល់ច្បាស់នូវព្រះទ័យព្រះពុទ្ធ។ ចិត្តរបស់ព្រះពុទ្ធពោរពេញទៅដោយមហាករុណាអាសូរ ដែលលាតសន្ធឹងរហូតទៅដល់អ្នកដែលមិននឹកនារលល់ដល់ព្រះអង្គ ហើយជាប្រាកដណាស់ដល់អ្នកមានសទ្ធាជ្រះថ្លា នឹងព្រះអង្គ។

អ្នកមានសទ្ធាជ្រះថ្លានឹងព្រះអង្គ នឹងបានជាអ្នក រួបរួមនឹងព្រះអង្គ។ ចិត្តព្រះពុទ្ធចូលទៅគ្រប់ទិសទី ដូច្នេះចិត្តព្រះពុទ្ធពិតជាចូលទៅក្នុងចិត្តអ្នកដែលជឿព្រះអង្គ។

សេចក្ដីនេះបានន័យថា បុគ្គលណាគិតដល់ព្រះពុទ្ធបុគ្គលនោះនឹងមានចិត្តបរិសុទ្ធ ចិត្តដែលបណ្ដាលឲ្យបានប្រកបនូវសេចក្ដីសុខស្ងប់ និងសុភមង្គលពេញលេញ។ បើនិយាយឲ្យខ្លីទៅចិត្តបុគ្គលនោះ គឺចិត្តព្រះពុទ្ធ។

ដូច្នេះ បុគ្គលណាដែលជឿដោយសុទ្ធចិត្តចំពោះព្រះពុទ្ធបុគ្គលនោះមានចិត្តជាព្រះពុទ្ធ។

5. ព្រះពុទ្ធមានសម្បទាអាចក្លែងភេទបានគ្រប់បែបយ៉ាង។

ព្រះអង្គ អាចបញ្ចេញឲ្យឃើញនៅចំពោះមុខមនុស្សទាំងឡាយក្នុងសភាពផ្សេងៗទៅតាមសមត្ថភាពរបស់មនុស្សម្នាក់ៗ ដែលអាចយល់បាន។

មធ្យោបាយបញ្ចេញឲ្យឃើញឡើងរបស់ព្រះពុទ្ធអមិដាជាសកលហើយគ្មានទីបំផុតទេ វាហួសផុតពីការស្មានយល់របស់មនុស្សលោក។ ព្រះអង្គអាចបញ្ចេញឲ្យឃើញឡើងនៅក្នុងលោកទាំងមូល នៅក្នុងធម្មជាតិរហូតដល់នៅក្នុងមនុស្សជាតិទៀតផងក៏មាន។

តែនៅក្នុងសភាពណាក៏ដោយ ព្រះអង្គតែងតែបញ្ចេញឲ្យឃើញឡើងជាប្រត្យក្សនៅក្នុងវិញ្ញាណ របស់អ្នកដែលប្រកាសព្រះនាមព្រះអង្គដោយសុទ្ធចិត្ត។ នៅពេលដែលព្រះអង្គយាងមក ព្រះអង្គតែងតែនាំពោធិសត្វពីរព្រះអង្គមកជាមួយគឺព្រះពោធិសត្វអវលោកិតេស្វរៈ ពោលគឺព្រះពោធិសត្វមហាករុណាអាសូរ និងព្រះពោធិសត្វមហាធម្មាប្រធាន ពោលគឺព្រះពោធិសត្វប្រាជ្ញាញាណ។ ព្រះពុទ្ធអមិដា បញ្ចេញឲ្យឃើញឡើងពាលពេញពិភពលោក សម្រាប់ឲ្យមនុស្សលោកទូទៅមើលឃើញ ប៉ុន្តែមានតែអ្នកដែលមានសទ្ធាជ្រះថ្លានឹង

ព្រះអង្គទេ ដែលសំគាល់ឃើញព្រះអង្គ។

អ្នកដែលអាចមើលឃើញរូបភាពព្រះពុទ្ធ នឹងបានប្រកបសេចក្ដីសប្បាយរីករាយនិងសុភមង្គលជាច្រើនអនេក ហើយជាងនេះទៅទៀត អ្នកដែលអាចជួបនឹងព្រះពុទ្ធដោយប្រត្យក្សនៅក្នុងដែនដីបរិសុទ្ធរបស់ព្រះអង្គ នឹងបានទទួលនូវសេចក្ដីសុខក្សេមក្សាន្តគ្មានទីចប់។

6. ព្រះពុទ្ធអមិដា ដែលមានព្រះទ័យពោរពេញនូវក្ដីករុណាអាសូរ និងព្រហ្មចារិភាព ព្រះអង្គរំដោះសត្វលោកគ្រប់ប្រភេទទាំងអស់។

បុគ្គលណា ដែលដោយសារសេចក្ដីល្ងង់ខ្លៅ ប្រព្រឹត្តកំហុសធំដូចជាបុគ្គល ដែលមានចិត្តពោរពេញទៅដោយក្ដីលោភលន់ក្ដីខឹងក្រោធ ក្ដីវក់ធ្លួត បុគ្គលដែលភូតភរកុហក ដែលនិយាយច្រើនឥតប្រយោជន៍ ដែលនិយាយអាក្រក់ពីគេ ដែលបោកបញ្ឆោតគេ បុគ្គលដែលសម្លាប់គេ លួចប្លន់គេ ប្រព្រឹត្តអំពើមេថុន មនុស្សទាំងឡាយណាដែលប្រព្រឹត្តទោសកំហុសទាំង ១០ ប្រការនេះ ដល់ស្លាប់ទៅនឹងទទួលកម្មពៀរអស់កាលដ៏

យូរអង្វែង។

ប៉ុន្តែនៅពេលហៀបនឹងអស់ជីវិតទៅ មានអ្នកប្រកបដោយគតិបណ្ឌិតជាមិត្តម្នាក់បានប្រាជកឡើង ហើយឧទានទៅកាន់មនុស្សទាំងនោះថា: «ឥឡូវនេះអ្នកជិតដល់នូវសេចក្តីមរណៈហើយ អ្នកពុំអាចលះបង់ជីវិតពុករលួយរបស់អ្នកបានទេ ។ ប៉ុន្តែអ្នកអាចទៅរកទីជម្រកក្នុងព្រហ្មវិហារធម៌របស់ព្រះពុទ្ធ ដែលជាទីជម្រកសុខសាន្តបាន បើអ្នកសូត្រព្រះនាមព្រះអង្គ»។

បើមនុស្សពុករលួយទាំងនោះ សូត្រព្រះនាមព្រះពុទ្ធអមិដាដោយចិត្តស្មោះត្រង់ មនុស្សទាំងនោះនឹងបានរួចអំពីកម្មពៀរ។

បើគ្រាន់តែសូត្រព្រះនាមព្រះពុទ្ធតែប៉ុណ្ណោះ ក៏អាចរួចផុតពីកម្មពៀរដែរនោះ ការសង្រួមចិត្តជឿទៅលើព្រះពុទ្ធដោយស្មោះត្រង់ រឹតតែប្រសើរណាស់ទៅទៀត។

អ្នកដែលអាចសូត្រព្រះនាមពិសិដ្ឋនេះបាន នៅពេលជិតអស់សង្ខារ នឹងអាចបានជួបនឹងព្រះពុទ្ធអមិដា។ ពោធិសត្វមហាករុណាអាសូរ និងពោធិសត្វព្រហ្មចារិភាព ទាំង ពីរអង្គនោះនឹងមកនាំអ្នកនោះទៅកាន់ដែនដីព្រះពុទ្ធ ហើយគេនឹង

បានទៅកើតក្នុងភាពបរិសុទ្ធ ដូចផ្កាឈូកស ក្បុស។

ហេតុដូច្នេះជនរាល់រូបត្រូវតែចាំជាប់ក្នុងចិត្តនូវធម្មសូត្រ «**នមោ អមិតា ពុទ្ធោ**» ដែលមានន័យថា «គារវកក្តីដោយសុទ្ធចិត្តចំពោះព្រះពុទ្ធនៃពន្លឺនិងជីវិតឥតទីបប់»។

II

# ដែនដីបរិសុទ្ធរបស់ព្រះពុទ្ធអមិដា

1. ព្រះពុទ្ធនៃពន្លឺនិងជីវិតឥតទីចប់ ឋិតមាននៅជានិច្ចមិនចេះចប់ទេ។ ព្រះអង្គផ្សព្វផ្សាយព្រះធម៌ជាអចិន្ត្រៃយ៍។ នៅក្នុងដែនដីបរិសុទ្ធរបស់ព្រះអង្គ គ្មានទុក្ខវេទនាគ្មានភាពងងឹតទេ។ ជីវិតរស់នៅកន្លែងនោះសប្បាយរីករាយរហូត។ ហេតុនេះហើយបានជាផែនដីនោះ ត្រូវបានហៅថា: «ដែនដីសុកមង្គល»។

នៅក្នុងដែនដីនោះ មានស្រះដែលមានទឹកភ្លឺថ្លាបរិសុទ្ធត្រជាក់ស្រួល បាញ់សាចចេញឡើង។ រលកទឹកនោះហាក់លោតទៅប៉ប្រះនឹងច្រាំងខ្សាច់មាស ដោយភាពថ្នាក់ថ្នម។ នៅទីណាក៏មានផ្កាឈូកគ្រប់ពណ៌មានទំហំប៉ុនកង់រទេះរីកស្គុស

ស្គាយដែរ។ ផ្កាឈូកពណ៌ខៀវបញ្ចេញរស្មីខៀវ ផ្កាឈូកពណ៌លឿងបញ្ចេញរស្មីលឿង ផ្កាឈូកក្រហមបញ្ចេញរស្មីក្រហម ផ្កាឈូកពណ៌ស បញ្ចេញរស្មីស។ ក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់ផ្សាយផ្សព្វទៅគ្រប់ទិសទី។

នៅជុំវិញស្រះស្រង់នោះ មានវិមានមាសវិមានប្រាក់វិមានកែវមរកត ដែលមានកាំជណ្ដើរថ្មកែវ ចុះទៅប៉ប្រះ នឹងផ្ទៃទឹក។ មានបង្កាន់ដៃលំអដោយរនាំងក្បូងត្បូងរ័តន៍ព័ទ្ធជុំវិញស្រះ។ នាកណ្ដាលបង្កាន់ដៃទាំងនោះមានរុក្ខាតូចៗ ចោលក្លិនក្រអូបឈ្ងុយឈ្ងប់ និងគុម្ពោតរុក្ខជាតិដែលមានផ្ការីកស្គុសស្គាយ។

ផ្ទៃដីបញ្ចេញសោភណភាពគ្មានពីរ ផ្ទៃមេឃបន្ទឺតន្ត្រីទិព្វយ៉ាងរងំ។ ប្រាំមួយដងក្នុងពេលថ្ងៃ និងប្រាំមួយដងក្នុងពេលយប់ស្រទាប់ផ្កាគ្រប់ពណ៌ល្អឆើត ជ្រុះសាយសព្វពីនភាល័យ។ ជនទាំងឡាយនៅឋាននោះ នាំគ្នារើសប្រមូលផ្កាជ្រុះមកនោះដាក់ក្នុងថូ យកទៅថ្វាយព្រះគ្រប់អង្គ។

2. នៅក្នុងដែនដីទិព្វនោះមានសត្វបក្សីបក្សាជាច្រើន ដូចជា

ហង្សពណ៌សដូចផ្កាទឹកក សេកសោម ក្ងោករំលេចពណ៌ភ្លឺផ្ទេកៗ បក្សីឋានសួគ៌ និងហ្វូងបក្សីតូចៗឃំតិចៗ យ៉ាងពីរោះរងំៗ នៅក្នុងដែនដីព្រះពុទ្ធ សត្វបក្សីទាំងនោះសូត្រពាក្យទូន្មានរបស់ព្រះពុទ្ធ ច្រៀងសរសើរកុសលរបស់ព្រះអង្គដោយសំឡេងផ្អែមត្រជាក់ៗ

អ្នកដែលបានស្តាប់ឮបទចម្រៀងនៃបក្សីទាំងនោះ បានឮពុទ្ធវាចា ហើយគេនឹកឃើញជាថ្មីឡើងទៀត នូវជំនឿស្មោះត្រង់របស់គេ នូវសេចក្តីសប្បាយ និងសុខសន្តិភាពរបស់គេដែលបានរស់នៅក្នុងសង្គមពុទ្ធបរិស័ទៗ

ខ្យល់រំភើយត្រជាក់ស្រួល បក់តាមចន្លោះដើមព្រឹក្សានៃដែនដីបរិសុទ្ធនោះទៅអង្រួនកួងមណ្ឌបល្អថ្លៃថ្លា ប្រគំឡើងជាតន្ត្រីយ៉ាងរងំៗ

អ្នកដែលបានឮតន្ត្រីឋានសួគ៌នោះ នឹកឃើញដល់ព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃៗ សុក្រឹតភាពទាំងអស់នេះ គឺជាពន្លឺរស្មីនៃទិដ្ឋភាពជាធម្មតាបំផុត ដែលចែងចាំងឡើង នៅក្នុងដែនដីព្រះពុទ្ធនោះៗ

3. ហេតុដូចម្តេចបានជាព្រះពុទ្ធនៃដែនដីនោះ មានព្រះនាមថា អមិដា ឬព្រះពុទ្ធនៃពន្លឺនិងជីវិតឥតទីបញ្ចប់? ព្រោះរស្មីនៃព្រហ្មចរិយធម៌របស់ព្រះអង្គ ចែងចាំងទៅគ្រប់ទិសទីនាសកលលោក ហើយព្រោះរយៈវេលានៃជីវិតមហាករុណាអាសូររបស់ព្រះអង្គមិនចេះចប់ទេ។

ហេតុដូច្នេះ ចំនួនអ្នកដែលបានទៅកើតក្នុងដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ ហើយបានសម្រេចពន្លឺត្រាស់ដឹងពេញលេញគ្រប់នោះ រាប់មិនអស់ទេ។ អ្នកទាំងនោះមិនវិលត្រឡប់មកក្នុងលោកបំភាន់ភ្នែកនៃការកើត និងការស្លាប់នេះជាដាច់ខាត។

ចំនួនអ្នកដែលបានភ្ញាក់រលឹកនឹកគិតទៅដល់ជីវិតថ្មីនោះដោយសារពន្លឺរបស់ព្រះពុទ្ធ ក៏រាប់មិនអស់ដែរ។

ហេតុនេះ សត្វលោកក៏ត្រូវតែរក្សាទុកឲ្យខ្ជាប់ខ្ជួនក្នុងចិត្តនូវព្រះនាមព្រះអង្គគឺៈ **«នមោ អមិតា ពុទ្ធោ»**។ ហើយតែមួយថ្ងៃក្តី ឬមួយអាទិត្យក្តី គួរតែសូត្រព្រះនាមរបស់ព្រះអង្គដោយជំនឿសុទ្ធចិត្ត។ ធ្វើយ៉ាងនេះដល់ពេលស្លាប់ទៅគេនឹងបានទៅកើតក្នុងដែនដីបរិសុទ្ធរបស់ព្រះពុទ្ធ ដែលមានព្រះ

ពុទ្ធអមិដា ជួបជុំ ដោយពពួកអង្គសាវ័ក ជាអ្នកដឹកនាំ។

បុគ្គលណាបានឮព្រះនាមព្រះពុទ្ធអាមិដា ជឿតាមសេចក្ដីប្រៀនប្រដៅរបស់ព្រះអង្គ  បុគ្គលនោះនឹងបានសម្រេចពន្លឺត្រាស់ដឹង ប្រសើរខ្ពង់ខ្ពស់បំផុត។